Free

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

REMEDIUM PHARMACY
ឱសថស្ថានរ៉ឺមីឌៀម
2 Vinal Square. North Chelmsford, MA 01863
ជាឱសថស្ថានបំរើការគ្រប់យ៉ាងដល់អ្នក
- ផ្ទេរឬផ្លាស់ប្ដូរសេវាកម្ម
- ការវេចខ្ចប់ឱសថ
- ការលាយផ្សំឱសថ
- បញ្ជូនឱសថដល់ផ្ទះដោយឥតគិតថ្លៃ
- ជួយធ្វើសំបុត្រទិញថ្នាំ
- ផ្លាស់ប្ដូរយោបល់ដោយរាក់ទាក់

ឱសថស្ថានយើងខ្ញុំនិយាយភាសាខ្មែរ

FREE daily delivery | Blisterpack Packaging | Compounding Medication
Friendly consultations | Easy Transfers
Tel: 978-251-7070 | Fax: 978-251-7071

Cambodia Daily

## WIN, LOSE OR SINK, RACERS REVEL IN TRADITION



by Ben Sokhean and Janelle Retka | November 14, 2016

With the return of Water Festival on Sunday, AttPhally was glad to get back in the water and paddle for the pride of his village.

"I'm happy that the boats are racing again this year," he said on Sunday afternoon. "I like it because my ancestors also celebrated with boat races from the Angkor regime until now."

It was only the second round of races for the 37-year-old. Long an annual tradition, the festival in Phnom Penh was canceled for three

Continued to Page 04

# “ពិណាបញ្ចពណ៌”សមាគមអង្គរ សម្ដែងឫទ្ធិមិនចេះឈប់



ឆាក "កូរសមុទ្រទឹកដោះ" ដែលយក្សនិងទេវតាដណ្ដើមទឹកអម្រិត (រូបកណ្ដាលអ្នកគ្រូ ចាន់ណា សាត)

**ដោយ ពិន សំខុន**

មនុស្សប្រមាណ២០០នាក់ បានមកទស្សនាសិល្បៈជាវប្បធម៌បូរាណខ្មែរ នារាត្រីទី១៨វិច្ឆិកា ក្នុងកម្មវិធីរបស់"សមាគមអង្គរ"ចូលរួមដោយសាស្ត្រាចារ្យនៃសាកលវិទ្យាល័យវិចិត្រសិល្បៈនៃទីក្រុងភ្នំពេញនឹងតន្ត្រីករសាកលវិទ្យាល័យយូម៉ាស់ឡូវែលផង។ ជាថ្មីម្ដងទៀតនាថការីនឹងនាថករបានបញ្ចេញថ្វីដៃសិល្បៈខ្មែរក៏រឹតខ្ពស់នាំអារម្មណ៍ទស្សនិកជនឱ្យចូលស្លុងក្នុងសាច់រឿងនិមួយៗដោយតាមដានយ៉ាងស្ងប់ស្ងៀមស្ទើរភ្លេចដកដង្ហើម។ លើកនេះប្លែកពីការសម្ដែងឆ្នាំមុនដោយរបាំនិមួយៗចងភ្ជាប់ដោយសម្លេងភ្លេងច្បាស់លាស់អ្នកសម្ដែងអាចចូលតួរឯកខ្លួនឯងបានយ៉ាងស៊ុបពន្លឺភ្លើងតាមចង្អុលតាមដានបង្ហាញពីកន្លែងកើតហេតុធ្វើឱ្យសាច់រឿងលេចសោភណ្ឌភាពចេញពីការសម្ដែង គួរឱ្យចាប់ចិត្តក្រៃលែង។

តាំងពីដើមទីដែលគេយករបាំបូរាណមកសម្ដែងជារឿង"រាមកេរ", បង្ហាញពីតួរកុមារ "រាមលក្សណ៍" នឹង"ជប់លក្សណ៍"ដេញចាប់សេះជិះលេងកំសាន្តតែត្រូវបាន"ហនុម៉ាន"រារាំងមិនឱ្យលេងនោះ, ទស្សនិកជនមានអារម្មណ៍រំភើបដោយឃើញការបកស្រាយរឿងទៅតាមកាយវិការក្បាច់

តទៅទំព័រទី ០២

មាតិការឿង

Issue 213 from. Nov. 18th - Dec. 1st, 2016


១-បោះឆ្នោតសាកល២០១៧............០៣
២-អ្នកអានសួរពីច្បាប់បោះឆ្នោត........០៣
៣-ព្រះរាជពិធីបុណ្យអុំទូក អកអំបុក..០៤
៤-បុណ្យឯករាជជាតិ-កំណត់.............០៦
៥-ពីតំបន់"កាណាហាមីលតុន"...........០៧
៦-ជនជាតិ"ហម៉ុង"ម្នាក់ឡើងជា........០៨
៧-ចិនដាក់ទណ្ឌកម្មលើកូរ៉េខាងជើង...១១
៨-តើប្រទេសកម្ពុជា នឹងទទួល..........១២
៩-រំលឹកព្រឹត្តិការណ៍ព័ត៌មានពីថ្ងៃ........១៤
១០-CMAA to host 32nd Annual.២៤
១១-ដាំរុក្ខជាតិទាំងនេះ....អ្នកនឹង......២៦
១២-ឧទ្យានជាតិបុទុមសាគរ.............៣២


**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

មេធាវី ល្វុយហាស្កែល
Attorney Louis S. Haskell
978-459-8359
16 Pine Street - Lowell, MA 01851
www.attorneyhaskell.com



របួសរាងកាយ
គ្រោះថ្នាក់ចរាចរ
យើងនិយាយភាសាខ្មែរ,ឡាវ,ថៃ
អាចណាត់ជួបពេលល្ងាចក៏បាន
មានកន្លែងចតរថយន្តឥតចេញថ្លៃ
មានអាជ្ញាប័ណ្ណនៅរដ្ឋ MA និង NH
បំរើសហគមន៍ខ្មែរតាំងពីឆ្នាំ១៩៨៧

PERSONAL INJURY
AUTO ACCIDENTS
We Speak Khmer, Lao, Thai
Evening Appointments Available
Free Parking
Licensed in MA & NH
Serving the Cambodian Community since 1987

## តមកទំព័រទី ០១ ពិណបញ្ចពណ៌( សមាគមអង្គរសម្ដែង...)

របាំបូរាណយ៉ាងងាយស្រួលងាយនឹងយល់របស់រាជកុមារទ្រង់គ្រឿងជាកូនស្ដេច, ពីព្រោះទាំងសិល្បករ ទាំងរបាំ ទាំងភ្លេង បានរលាយសាច់ចូលគ្នាទៅជាសាច់រឿងតែមួយសម្ដែងពីទំនាស់ដែលគ្មានបុព្វហេតុពី"កំហឹង"។ គោលដៅនៃសិល្បៈល្ខោនបានមកដល់កំរិតខ្ពស់បំផុត ដែលអ្នកមើលលែងឃើញសិល្បករលែងឃើញឆាកលែងឮភ្លេងនៅសល់តែសាច់រឿងនឹងអារម្មណ៍រំភើបជាមួយនឹងការសម្ដែងតែប៉ុណ្ណោះ។ យើងសូមសម្ដែងការកោតសសើរដល់យុវសិល្បករវិចតូរីយ៉ា ផាន់, នីណា ទូច, ចនី ខាត់ នឹង ភីទ័រជា ដែលបាននាំទស្សនីយភាពដ៏ត្រកាលនេះជូន"សហាគមន៍ឡូវែល"ដ៏មានសំណាងច្រើននេះ។


នាង វៀជីនា ប្រាក់ ក្នុងឆាកស្នេហានៃរឿង"ពិណបញ្ចពណ៌"







របាំបន្ទាប់ មានឈ្មោះថា "របាំក្រម៉ា" ដែល "ភាពធម្មតា" បានត្រូវផ្លែឱ្យទៅជា "ពិសេស"។ របាំប្រជាប្រិយមួយនេះ ប្រាកដជាបាននាំទស្សនីយភាពរីករាយរបស់យុវជននឹងយុវនារីខ្មែរដែលមានប្រភពពីសង្គមកសិករមកបង្ហាញជូន"ឡូវែល"នេះបាន្យ ប៉ុន្តែដែលសំខាន់នោះអ្នកនិពន្ធចង់បង្ហាញរបស់ម្យ៉ាងដែលខ្មែរតែងប្រើជាចាំបាច់ជាធម្មតាតែភ្លេចគិតថា "វាមានសារៈប្រយោជន៍"គ្រប់ជំហាននៃជីវិតអ្នកស្រែ។ នៅក្នុងភាពរីករាយរបស់យុវជនគេឃើញ "ក្រម៉ា" បានក្លាយជាឈ្នួតក្បាលជាកន្សែងបង់ក ជាខោខ្លីជាគ្រឿងបន្លាស់សម្រាប់ងូតទឹកកន្សែងជូតមុខឬក៏ភួយសណ្ដប់ខ្លួនផង... គឺ"ក្រម៉ា" នេះហើយដែលបានប្ដូរតួរនាទីរបស់ខ្លួនច្រើនដងក្នុង១ថ្ងៃ, ច្រើនថ្ងៃក្នុង១ឆ្នាំ កំដរជីវិត "ញញឹមនឹងទឹកភ្នែក" របស់អ្នកស្រែខ្មែរយើង, រហូតដល់ចាស់លាលោកទៅ។



របាំទី៣មានឈ្មោះថា"របាំកូរសមុទ្រទឹកដោះ" គឺរបាំនិយាយពីជម្លោះរវាងទេវត្តានឹងយក្ខដើម្បីកូរសមុទ្រទឹកដោះ ហើយដណ្ដើមយក "ទឹកអម្រឹត"ដែលគូភាគីជម្លោះជឿថា អាចការពារជីវិតឱ្យ"អមតៈ"រួចផុតពីការស្លាប់បាន។ "នាគរាជ"សិប្បនិមិត្តសម្ដែងយ៉ាងទន់ភ្លន់លូនពេញឆាកជាអ្នកការពារនាង"ភ្នំព្រះសុមេរុ" ដែលជំនឿជំនាន់ព្រហ្មញ្ញសាសនានិយាយថា "នៅបាតភ្នំមានឱសថសាកសិទ្ធម្យ៉ាងមានឈ្មោះថា ទឹកអំរឹតអាចការពារមិនឱ្យអ្នកមានជីវិតស្លាប់ទៅវិញបានទេ, បើគេបង្វិលភ្នំកូរសមុទ្រនៅទីនោះ ទឹកដោះម្យ៉ាងឈ្មោះទឹកអំរឹតនឹងចេញមកនរណាយកទឹកដោះនោះបានមុនមកប្រើនឹងទទួលបាននូវជីវិតអមតៈ"។ របាំបូរាណមួយនេះទៀត គឺជា "ថ្មអង្គរវត្តចេះនិយាយ"ឆ្លងសតវត្សមកប្រាប់យើងជំនាន់ក្រោយពីចំណង់នឹងអំណាចគ្មានទីបញ្ចប់របស់មនុស្ស តាមរយ "សិល្បៈទេវ" ដែលនាថការីនឹងនាថករសមាគមអង្គរ "ខាប" ព្រលឹងចេញពីថ្មអង្គរមកបានរៀបរាប់ពី "កំហឹង ចំណង់ អំណាច ចម្បាំង" ដែលជាមោទនភាពនៃជំនាន់អ្នកកសាងអង្គរនៅជាង១ពាន់ឆ្នាំមុន ។ នាថកម្មនៃរបាំបូរាណខ្មែរបានត្រូវយកមកប្រើយ៉ាងប្រណិតក្នុង "សិល្បទេវៈ"នេះប្រកបដោយអត្ថន័យនឹងមេរៀនគួរឱ្យចាប់អារម្មណ៍ពីអតីតកាលពិបុព្វបុរសខ្មែរ។ **តទៅទំព័រទី ២៣**



LICO WIRELESS, INC
boostmobile metroPCS T··Mobile·
ទូរស័ព្ទ & កុំព្យូទ័រ
ជួសជុល . ទូរទាត់វិក័យប័ត្រ
មិនគិតថ្លៃការពិគ្រោះពិនិត្យ

បើកថ្ងៃចន្ទ _ ថ្ងៃសៅរ៍ ១០ព្រឹក_៧យប់
978-735-4100
336 Westford Street, Unit1. Lowell, MA 01851

# អ្នកអានសួរពីច្បាប់បោះឆ្នោត នៅសហរដ្ឋអាមេរិក

បោះឆ្នោតរួចហើយប្រធានាធិបតីជាប់ឆ្នោតបានទៅលោក ឌុណល ត្រម ប៉ុន្តែ លោកស្រី ហ៊ីឡារី គ្លីងតុង បានសន្លឹកឆ្នោតច្រើនជាង -មិត្តអ្នកអានយើងសួរថាៈ ១-បើបេក្ខនារី ហ៊ីឡារី គ្លីងតុន ទទួលបានសន្លឹកឆ្នោតច្រើនជាងហេតុអ្វីក៏ទៅជាចាញ់ឆ្នោតទៅវិញ?

លោកស្រី ហ៊ីឡារី គ្លីងតុន ទទួលបានសន្លឹករួមទូទាំងប្រទេសឆ្នោតចំនួន**៦៣ ៦០០ ៤៤៧**។

លោក ឌុណល ត្រម បានសន្លឹកឆ្នោតទូទាំងប្រទេសចំនួន**៦១ ៩៣៤ ៤១១**។

ក៏ប៉ុន្តែច្បាប់បោះឆ្នោតអាមេរិកាំងគេមិនបានកំណត់យក"ឆ្នោតប្រជាប្រិយ-Popular vote" ច្រើនជាងថា "ជាអ្នកឈ្នះឆ្នោត"នោះទេ, គឺគេត្រូវឈ្នះនៅរដ្ឋនិមួយៗជាមុនសិននៅក្នុងរដ្ឋនិមួយៗនោះ គេក៏មានកំណត់ចំនួនដំណាង់របស់គេដែលគេហៅថា"ឆ្នោតដំណាង-Electoral vote" ដូចជានៅរដ្ឋម៉ាសាឈូសិតមានកំណត់ដំណាងចំនួន១១ទៅតាមចំនួនប្រជាពលរដ្ឋច្រើនឬតិចដែលរស់នៅក្នុងរដ្ឋ, អ្នកដែលឈ្នះ "ឆ្នោតប្រជាប្រិយ" នៅរដ្ឋម៉ាសាឈូសិតនឹងប្រមូលយក"តំណាងរដ្ឋ" នោះទាំងអស់ចំនួន១១នាក់។ ហើយគេកំណត់មួយទៀតថា បេក្ខជនណាដណ្តើមយកបាន "ឆ្នោតតំណាង"បានចំនួន២៧០មុនគេបេក្ខជននោះនឹងត្រូវប្រកាសថា"ជាអ្នកឈ្នះឆ្នោត"។ អ្នកដែលទទួលជ័យជំនះ គឺអ្នកដែលបានទទួលចំនួនភាគច្រើននៃ"ឆ្នោតតំណាង" ដែលចំនួនទាំងអស់មាន៥៣៨ តំណាង, ចំនួន ២៧០ គឺជាចំនួនលើសពាក់កណ្តាលនៃចំនួនតំណាងទាំងអស់នោះ។

ហេតុដែលលោកស្រី ហ៊ីឡារី គ្លីងតុន ឈ្នះ "ឆ្នោតប្រជាប្រិយ"ហើយបាន៤៧,៩៥ (ត្រមបានតែ៤៧,០៩) បែរជាមិនបាន "ជាអ្នកឈ្នះឆ្នោត"នោះ ពីព្រោះនៅរដ្ឋតូចៗមួយចំនួន ទោះជាមានប្រជាពលរដ្ឋតិចក្តី ក៏មាន "ឆ្នោតតំណាង" តិចបំផុតក៏៣រូបដែរ, ធ្វើយ៉ាងនេះ ដោយគេមិនចង់ឱ្យចាញ់ប្រៀបរដ្ឋធំៗដែលទទួលតំណាងបានចំនួនច្រើន, ក៏ប៉ុន្តែក៏បានន័យថា គេមិនត្រូវការ "ឆ្នោត ប្រជាប្រិយ"ច្រើនសម្រាប់តំណាងម្នាក់ៗនៃតំបន់តូចៗទេ។ លោក ឌុណល ត្រំ ឈ្នះ២៩០ តំណាង (ហ៊ីឡារី គ្លីងតុន បានតែ២៣២តំណាង) យកបានតំបន់នៃរដ្ឋតូចៗជាច្រើននៅទំបន់អាមេរិកកណ្តាលដែលមិនសូវមានមនុស្សរស់នៅច្រើនបន្ថែមដោយតំបន់ធំៗខ្លះមកទៀត ហេតុដូច្នេះហើយ បានជាបាន"ឆ្នោតប្រជាប្រិយ"តិចមែនតែបាន"ឆ្នោតតំណាងច្រើន"៕

538 members of the Electoral College
270 electoral votes needed to win

| Nominee | Donald Trump | Hillary Clinton |
|---|---|---|
| Party | Republican | Democratic |
| Home state | New York | New York |
| Running mate | Mike Pence | Tim Kaine |
| Projected electoral vote | 306[1] | 232[1] |
| States carried | 30 + ME-02 | 20 + DC |
| Popular vote | 61,934,411[1] | 63,600,447[1] |
| Percentage | 46.57% | 47.82% |




Presidential election results map.
Red denotes states projected for Trump/Pence;

ទស្សនៈនយោបាយ

# បោះឆ្នោតសាកល២០១៦, ហេតុអ្វីក៏"ឌុណល ត្រម"ឈ្នះ



ពិន សំខុន

**ដោយពិន សំខុន**

ខុសពីវប្បធម៌នៃការបោះឆ្នោតមុនៗ លោកបេក្ខជនប្រធានាធិបតីនៃគណបក្សសាធារណរដ្ឋ ឌុណល ត្រម បានរំលោភគ្រប់ជំហ៊ានសីលធម៌ ដើម្បីឃោសនាយកជ័យជំនះលើគូរប្រកួតម្តងមួយៗចំនួន១៦គូរ រហូតដល់ចុងបញ្ចប់នៅខែទី២០ដែលលោកត្រូវប្រកួតជាមួយនឹងបេក្ខនារីខាង **តទៅទំព័រទី ១០**



President elected

| Party | Donald Trump |
|---|---|
| | Republican |



Hillary Clinton
Democratic

Habitat for Humanity® of the North Shore



**ការដាក់ពាក្យសុំសម្រាប់ទិញផ្ទះ សម្រាប់ពីរគ្រួសារ**

ផ្ទះមាន២បន្ទប់ តម្លៃទាប នឹងត្រូវសង់នៅផ្លូវ"អាសប៊ូរី", តម្លៃផ្ទះ $១៣៥.០០០, បង់ប្រចាំខែប្រមាណ$៨០០, ផ្ទះនោះនឹងរៀបចំសម្រាប់ជនពិការក៏ចេញចូលបានដែរ

លោក-អ្នកដែលចង់ដាក់ពាក្យសុំទិញផ្ទះនោះ សុំអញ្ជើញទៅចុះឈ្មោះចូលរួម ប្រជុំផ្តល់ព័ត៌មានពីការសុំទិញផ្ទះ ឱ្យបានម្តងក្នុងការប្រជុំទាំង២ដែលរៀបចំជូន :

១- ថ្ងៃអង្គារ ទី ៦ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ១០ព្រឹក-១១ព្រឹក ឬក៏
២- ថ្ងៃអង្គារ ទី ៦ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ៦ល្ងាច - ៧ល្ងាច
អស័យដ្ឋាន: Hamilton Town Hall, 577 Bay Rd., Hamilton

**ប្រាក់ចំណូលដែលកំណត់:**

| ចំនួនមនុស្សក្នុងផ្ទះ | ប្រាក់ចំណូលតិចបំផុត ៤០% នៃមធ្យមក្នុងតំបន់ | ប្រាក់ចំណូលច្រើនបំផុត៣ ៦០% នៃមធ្យមក្នុងតំបន់ |
|---|---|---|
| 1 | $ 27,600 | $ 41,400 |
| 2 | $ 31,250 | $ 47,280 |
| 3 | $35,480 | $ 53,220 |
| 4 | $ 39,400 | $ 59,100 |

**គំរូពាក្យសុំ អាចរកបាននៅ:** http://www.habitatforhumanity-northshore.com
St. Pius V Parish Office, 215 Maple Street, Lynn, Ma
Hamilton Town Clerks Office, 577 Bay Road, Hamilton, Ma
Deadline January 10th, 2017

រួមចំណែកជាមួយ Habitat គឺប្រហែលជាដំណោះស្រាយសម្រាប់គ្រួសារអ្នក, ប្រសិនបើអ្នកកំពុងត្រូវការជម្រកដ៏មានតម្លៃទាប, មានបំណងបំពេញ "Sweat equity" ដែលគេទាមទារ, មានលទ្ធភាពចំណាយថ្លៃផ្ទះ $៨០០/ខែ ហើយនឹងជាអ្នកដែលទើបនឹងទិញផ្ទះជាលើកដំបូង (ករណីលើកលែងខ្លះអាចទទួលបាន)៕

EQUAL HOUSING OPPORTUNITY

# ព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែត ប្រទីប និងសំពះព្រះខែ ឆ្នាំ២០១៦

**ដោយ ពិទូ ពិន**

ស្ថិតក្រោមកំដៅថ្ងៃក្តៅគួរសម និងខ្យល់ទន្លេត្រសៀក១យុវជនខ្មែរចំរុះវ័យសម្បុរខ្មៅមាឌមាំប្រកបដោយទឹកមុខញញឹមរីករាយពោរពេញទៅដោយក្តីសង្ឃឹមក្នុងសន្តិភាពបានបន្លឺសំលេងជយោ១ ឈ្នះ១ និងទូងស្គរលាន់រំពង

ពេញផ្ទៃរទន្លេ យុវជននិមួយ១មានឯកសណ្ឋានអាវយឺត និងមួកដ៏ស្រស់ស្អាតចំរុះពណ៌ មានពណ៌ស ខៀវ បៃតង ក្រហម លឿង ទឹកក្រូច ត្រួយចេក គួបផ្សំនឹងសោភ័ណភាពដ៏អស្ចារ្យគ្មានពីរនៃទូកង ទូកចែវ គួរជាទីគយគន់នៅក្បាលទូក និងកន្ទុយទូកមានការសែនព្រេនយ៉ាងខ្ជាប់ខ្ជួន ដោយមានជំនឿថា ទូកនិមួយ១មានបារមីសណ្ឋិត ហេតុនេះហើយទូកនិមួយបានរៀបចំឡើងយ៉ាងហ្មត់ចត់ជាទីបំផុត ដើម្បីជៀសវាងហេតុការមិនល្អក្នុងពេលប្រណាំងទូក។ ក្រុមនិមួយ១ដែលមានឯកសណ្ឋានខុសគ្នាខ្លះឈររង់ចាំយ៉ាងត្រៀបត្រាខ្លះចុះទូករៀង១ព្រោះដល់ពេលកំណត់ដែលបានត្រៀមរៀបចំសំចតរង់ចាំគណកម្មការប្រកាសតាមមេក្រូហៅឈ្មោះដៃគូរប្រកួតរបស់ខ្លួននឹងត្រៀមចេញដំណើរទៅកាន់ទីផ្តាច់ព្រ័ត្រ។ មើលទៅទិដ្ឋភាពកណ្តាលទន្លេដូចជាសត្វនាគមួយគូរចំរុះពណ៌កំពុងហែលប្រណាំងគ្នាយ៉ាងលឿនទៅកាន់ទីផ្តាច់ព្រ័ត្រ ។

រាជរដ្ឋាភិបាលបានប្រារព្ធពិធីបុណ្យអុំទូក អកអំបុក និងសំពះព្រះខែឡើងវិញបន្ទាប់ពីអាក់ខានជាច្រើនឆ្នាំកន្លងមក ហើយប្រជាជនខ្មែរទូទាំងប្រទេសបានឈប់សំរាករយៈពេលបីថ្ងៃជិតមួយសប្តាហ៍រួមទាំងថ្ងៃសៅរ និងអាទិត្យ។ រីឯចរាចរណ៍នៅនៅតាមផ្លូវជាតិសំខាន់១មួយចំនួនតាមជាយក្រុងបានកកស្ទះ ដោយសារប្រជាជនរស់នៅរាជធានីភ្នំពេញខ្លះបានធ្វើដំណើរចាកចេញទៅលេងនៅឯជនបទទៅតាមរមនីយដ្ឋានផ្សេង១ដើម្បីផ្លាស់ប្តូរបរិយាកាសចំណែកឯប្រជាជននៅតាមបណ្តាខេត្តក៏បាននាំគ្រួសារចូលមកក្នុងទីក្រុងភ្នំពេញដើម្បីមើលការប្រកួតប្រណាំងទូកនាឱកាសដ៏កម្រនេះ ។ រដ្ឋាភិបាលក៏បានត្រៀមរៀបចំពង្រាយកម្លាំងកងរាជអាវុធហត្ថដើម្បីការពារសុវត្ថិភាពសណ្តាប់ធ្នាប់យ៉ាងយកចិត្តទុកដាក់ក្នុងពិធីបុណ្យអុំទូករយៈពេលបីថ្ងៃផងដែរ ដើម្បីជៀសវាងនូវព្រឹត្តិការអាក្រក់កើតឡើងនានា ដូចជាករណីស្លាប់គរជើងគ្នានៅលើស្ពានពេជ្រកាលពីឆ្នាំ២០១០នាឱកាសព្រះរាជពិធីបុណ្យអុំទូកកន្លងទៅ។

លោកពូ លី វេត មានវ័យខ្ទង់ហាសិបឆ្នាំដែលជាប្រធានទូកសែនសេរីមានជ័យមកពីខេត្តកំពង់ធំបានប្រាប់ឱ្យដឹងថា ទូកងបុរសរបស់ពូមានសមាជិកទាំងអស់៩៦នាក់ដើម្បីត្រៀម និងចុះទូកប្រកួតចំនួន៧៦នាក់ ។

លោកពូ បានសម្តែងនូវអារម្មណ៍រីករាយ និងមោទនៈភាពក្រៃលែងដែលបានចូលរួមអភិរក្សវប្បធមិខ្មែរយើងតាំងពីបុរាណលោកពូផ្ទាល់ព្រមទាំងសមាជិកចំណុះទូកទាំងអស់សប្បាយរីករាយខ្លាំងណាស់ដែលបានទទួលសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលស្តីពីការប្រណាំងទូកឡើងវិញ នូវឆ្នាំនេះ ក្រុមលោកពូបានត្រៀមលក្ខណៈរយៈពេលជាងពីរខែមកហើយតាំងពីបិណ្ឌទី៨មក ក្រោមជំនួយឧបត្ថម្ភផ្ទាល់ពីឯកឧត្តម ងួន ញិល ក្នុងការស្នាក់នៅនិងហូបចុក ព្រមទាំង និងប្រាក់ឧបត្ថម្ភបន្ថែមពី សម្តេច សាយ ឈុំ សម្តេច ហេង សំរិន ព្រមទាំងថ្នាក់ទាំងថ្នាក់ដឹកនាំ និងសប្បុរសជនជាច្រើនទៀត។ លោកពូបានបញ្ជាក់គោលជំហររបស់ខ្លួនបន្ថែមថា ពួកយើងមកចូលរួមដើម្បីលើកស្ទួយ និងអភិរក្សវប្បធម៌របស់ជាតិយើងស្របតាមសេចក្តីប្រកាសរបស់រដ្ឋាភិបាល គាត់បន្តថាមិនមានជំនួយឧបត្ថម្ភច្រើននោះទេ ប៉ុន្តែ **តទៅទំព័រទី ២០**



A crew member reaches for a water bottle as his team awaits their turn to compete in Water Festival boat races in Phnom Penh on Sunday afternoon. (Alex Consiglio)



People gather on the bank of the Tonle Sap to watch Water Festival boat races in Phnom Penh on Sunday afternoon. (Alex Consiglio)



**Continued from page 01**

# WIN, LOSE OR SINK, RACERS...

years after a stampede killed more than 350 people during the last night in 2010, and again last year due to low water levels.

In the first round of races on Sunday morning, Mr. Phally's team, SaravoanDechoSencheyBaromey from Phnom Penh's Daun Penh district, had fallen behind their opponent and failed to catch up, he said.

"I'm feeling a lot of regret because my boat lost the first round, but I will really fight to win," he said, adding that he hoped to make up for the initial loss during races over the coming days.

With 259 teams competing in various divisions-including 76 elite teams-the competition will culminate in final races on Tuesday afternoon.

For Khan Mab, 41, recovering from his team's loss would be even more difficult. As his team, Preah TinangRithyKIahan from Kandal province, reached the finish line, their boat quickly began to sink, leaving the 75 paddlers in a panic as they went down with it.

"I was really terrified. I thought I could die," he said. "I held onto the boat and swam a little and waited for the marines to come."

The rival team had veered into the path of his own and eventually struck the side of his boat, causing it to sink, he said. It was towed back to the side of the riverbed, where it spent the remainder of the day.

Mr. Mab said his team would not relent. "We will go home today, and tomorrow we will bring a smaller boat to compete," he said, adding that about 50 teammates could fit in the backup boat.

"This is our tradition. Our ancestors also did boat racing and we are the next generation, so we need to continue our ancestors' traditions," he added.

According to Touch Toeung from Takeo province, much of this year's festival remained true to tradition-at least until pop music acts took over on stages throughout the city in the evening.

"I've come to Water Festival since Sihanouk's regime," said the 75-year-old of then-Prince Norodom Sihanouk's rule starting in the 1950s. "I come to reflect on those memories."

Back then, he said, the main difference was the duration of the festival, which would stretch for seven days rather than three. "There are not many changes since I began watching. All the teams want to win to bring honor to their village."

And per tradition, King Norodom Sihamoni sat on Sunday where his father did for many festivals before-at the front of the central balcony over

**Continued to Page 25**

## បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីរពេទ្យ និងការគ្របដណ្ដប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ **បុព្វលាភរ៉ាប់រងគម្រោង $0**។**

### អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្ដប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784

**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

**UnitedHealthcare®**
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្ដូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

# CMAA to host 32nd Annual Celebration

**by KhmerPost USA**

សមាគមខ្មែរនឹងប្រារព្ធខួបប្រចាំឆ្នាំទី៣២ របស់សមាគមនៅថ្ងៃសៅរ៍ទី៣ធ្នូ វេលាម៉ោង ៦យប់ នៅភោជនីយដ្ឋាន "សំពៅមាស" នៅ ៤៥០ផ្លូវ"ឆែមស្ហ៊ឺត, ឡូវែល ម៉ាសាឈូសិត។ សំបុត្រចូលតម្លៃ $៥០,មួយកន្លែង។

សមាគមមានបំណងថ្លែងការកោតសសើររបស់ខ្លួន ចំពោះមនុស្សពិសេសពារូបក្នុងសហគមន៏ គឺលោក កូវិត គ្រីត ដោយសារលោកជាវិរបុរសសហគមន៏, លោក ជីម វិលដឺ លោកជាអ្នករួមចំណែកក្នុងការជួយរកផ្ទះសម្បែងក្នុងសហគមន៏, នឹងលោក" ម្ចាស់ហាងសំពៅមាស"ដែលជា "ពាណិជ្ជករជោគជ័យ"ក្នុងសហគមន៏។

ជាមួយគ្នានេះដែរសមាគមចង់បង្ហាញជូននូវប្រធានគណកម្មកានាយកថ្មីគឺលោក វីរៈ អ៊ុយ ផងដែរ។

The Cambodian Mutual Assistance Association of Greater Lowell (CMAA) will hold its 32nd annual celebration on Saturday December 3rd at Sompao Meas Hall in Lowell. The fundraising event will feature community recognitions, a five course meal, live entertainment by members of the youth programs and Angkor Dance Troupe.

Three award recipients will be honored by the CMAA during the event and they are the following: Kowith Kret for the Community Hero Award, Jim Wilde of the Merrimack Valley Housing Partnership for Community Partner Award, and the Sompao Meas Hall for Local Business Award.

CMAA, the oldest Cambodian non-profit organization in Lowell since 1984, has served the Cambodian immigrants and refugees whoneeded assistance and resources to resettle their new lives in Lowell. Last year alone, over 2,400 walk-in visits by over 800 distinct individuals have received assistance from CMAA.

Sovanna Pouv, CMAA Executive Director noted the importance of community support, "Over the past 31 years, CMAA has helped thousands of families and individuals right up until this very day. Without the support of our friends, family and community partners, we wouldn't be able to assist individuals to become citizens, vote, learn English and buy homes for the first time."

One of the successful partnerships is the collaboration with the Merrimack Valley Housing Part-nership, together they have educated and prepared nearly 700 Khmer speaking families about becomingthe home owner.

"This year CMAA celebrates 32 years of service to the Lowell community", said newly appointed Board President Virak Uy. "As we move forward, we will continue to honor our heritage and those who have sacrificed for us in the past, heal those who are still struggling every day to survive so that they can hope for a better future."

The event is on Saturday December 3rdat Sompao Meas Hall, 450 Chelmsford Street in Lowell at 6:00 p.m. Tickets are $50 and may be purchased by calling 978-454-6200 at the door.




គ្រូទាយនៅឡូវែល ដោយមើលឃើញនិងខាបព្រលឹង

Tarot Card
Spiritual
Palm
Crystal

$5 off for any Combination Reading

Available by appointment | walk-in welcome | Home Gatherings & Social Events |Group Rates

Sylvia Psychic & Spiritual Reading / 546 Rogers Street, Rt. 38, Lowell
978 937 0998

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

978-459-5000 or 800-308-3766
www.thomasinlowell.com

ប្រវត្តិក្រុងឡូវែល

# ពីតំបន់“កាណាល់ហាមីលតុន” ទៅ“មណ្ឌលជឿនលឿនអាមេរិកាំង

**ដោយ ឌីក ហាវ ប្រែសម្រួលដោយ ខ្មែរផុសស.រ.អា.**



Richard Howe

កាលពីប៉ុន្មានសប្តាហ៍មុន,គណក្រុមប្រឹក្សាក្រុងឡូវែលបានបោះឆ្នោតដាក់ឈ្មោះថ្មីឱ្យ "តំបន់កាណាលហាមីលតុន" ទៅជា"មណ្ឌលជឿនលឿនអាមេរិកាំង"ទៅវិញ។ ពាក្យ "ជឿន លឿន" គឺជាផ្លាកត្រឹមត្រូវបានត្រូវបំពាក់ឱ្យបំណែកតំបន់ដ៏ទូលំទូលាយនេះ ដែលធ្លាប់មានភាពជឿនលឿនមែននៅក្នុងប្រវត្តិសាស្ត្រ។

គ្រឿងម៉ាស៊ីនដែលបានត្រូវប្រើនៅរោងចក្រឡូវែលដំបូងបង្អស់ គឺធ្វើនៅ"វលថាំ" ប៉ុន្តែនៅបន្ទាប់ភ្លាមមកក្រុមហ៊ុនធ្វើម៉ាស៊ីននៅ "ម៉េរីម៉ាក" បានបង្កើត"ហាងធ្វើគ្រឿងចក្រ"សម្រាប់ប្រើខ្លួនឯង ក៏បានរីកដុះដាលក្នុងរោងចក្ររបស់ក្រុង។ ចុះឈ្មោះបង្កើតជាក្រុមហ៊ុនដាច់ពីគ្នានៅឆ្នាំ១៨៤៥ ហាងលក់ម៉ាស៊ីននៅឡូវែល បន្ទាប់មកផលិតបានម៉ាស៊ីនត្បាញសំឡី, ម៉ាស៊ីន បូមទឹក, នឹងបង្កើតក្បាលរថភ្លើងសម្រាប់គ្រុមហ៊ុនប្រើពាសពេញអាមេរិកទៀត។

មកដល់ឆ្នាំ១៨៦០ ឡូវែលបានក្លាយជាទីក្រុង ដែលធំបំផុតនៅ "ម៉ាសឈូសិត" ដែលមានប្រជាជន៣៦,០០០នាក់រស់នៅដែលប្រើកម្មករ ១៤,០០០នាក់ នៅក្នុងរោងចក្រតំបាញ៥២របស់ក្រុង។ ជារៀងរាល់អាទិត្យ រោងចក្រទាំងនោះ បានបង្វិលសំឡី៨០០,០០០ផោន ឱ្យទៅជាក្រណាត់កាត់ខោអាវប្រវែង២,៤លានយ៉ាដ។ ផ្លូវរថភ្លើងបានទៅជាសំខាន់ខ្លាំងឡើង សម្រាប់ដឹកនាំសំឡីចូលក្រុងនឹងសម្រាប់ដឹកនាំផលិតផលធ្វើហើយចេញពីទីក្រុងទៅកាន់ទីផ្សារ។

រោងចក្រធ្វើម៉ាស៊ីននៅឡូវែលស្ថិតនៅក្នុងចំណោមនៃរោងចក្រតំបូងគេ ដែលបានក៏សាងក្បាលរថភ្លើងប្រើកំដៅទឹក។ នៅដើមឆ្នាំ១៨៣០ ស្ថាបនិករបស់ក្រុងឡូវែលម្នាក់ឈ្មោះ ប៉ាទីក្រ ត្រេស៊ី ចាកសុន បានឮពីបច្ចេកទេសមធ្យោបាយដឹកនាំប្រើកំដៅទឹកថ្មីនៅប្រទេសអង់គ្លេស ក៏ទៅដឹកយកមួយមកជាគំរូម៉ាសីន សម្រាប់ធ្វើក្បាលរថភ្លើងខ្លួនឯង នៅក្នុង "ហាងធ្វើម៉ាស៊ីននៅឡូវែល"។ ក្បាលរដភ្លើងទី១ មានឈ្មោះថា "ប៉ាទ្រីក" ជូជាកិត្តិយសដល់ ប៉ាទ្រីក ត្រេស៊ី ចាកសុន។ ពីឆ្នាំ១៨៣៥ដល់ឆ្នាំ១៨៦០ "ហាងធ្វើម៉ាស៊ីននៅឡូវែល"ផលិតបាមក្បាលរថភ្លើងប្រើទឹកក្តៅចំនួន ១០០គ្រឿង។

មិនថាជាអ្នកធ្វើឱ្យជឿនលឿនខាងគ្រឿងម៉ាស៊ីនរោងចក្រតំបាញ, បង្កើនគុណភាពម៉ាស៊ីនបង្វិលទឹក, ឬក៏បង្កើតក្បាលរថភ្លើងដំបូងខ្លះៗនៅក្នុងស្រុកនោះទេ, "ហាងធ្វើម៉ាស៊ីននៅឡូវែល" គឺជាមជ្ឈមណ្ឌលនៃការជឿនលឿនមួយនៅអាមេរិកនាជំនាន់សតវត្សទី១៩នោះ។ ទីដីដែលគេបានសង់នាពេលនោះ គេបានស្គាល់ក្នុងឈ្មោះថា "តំបន់ជឿនលឿននៅកាណាល់ហាមីលតុន"។ ដោយសារតែទីក្រុងកំពុងងាកទៅស្វែងរកមើលអភិវឌ្ឍន៍ថ្មីឱ្យស្របនឹងភាពពិតនោះ យើងយល់ថា ជាការប្រសើខ្លាំងណាស់ដែល"ឱបអតីតកាលនៃតំបន់"ឱ្យជាប់ដោយសង្ឃឹមថា "ប្រវត្តិសាស្ត្រនោះនឹងកើតសារជាថ្មីដោយឯកឯង"៕




# Hamilton Canal District: A Center of American Innovation

**Richard Howe, Jr**

Several weeks ago, the Lowell City Council voted to rename the Hamilton Canal District the Hamilton Canal Innovation District. Innovation is an appropriate label to affix to this large parcel, for innovation is embedded in its history.

The machinery for Lowell's first mill was built in Waltham but the



Merrimack Manufacturing Company soon established its own machine shop to construct machinery for use in the city's expanding mills. Incorporated in 1845 as a separate company, the Lowell Machine Shop was soon producing cotton machinery, water turbines and even locomotives for companies across America.

By 1860, Lowell was the second largest city in Massachusetts with 36,000 residents with nearly 14,000 employed in the city's 52 textile mills. Each week, those mills turned 800,000 pounds of cotton into 2.4 million yards of cloth. Railroads became increasingly important to transport cotton to the city and finished goods from the city to markets. (Courtesy of ROC

The Lowell Machine Shop was one of the first in America to build steam locomotives. In the early 1830s, one of Lowell's founders, Patrick Tracy Jackson, heard of a new transportation technology used in England – the steam locomotive. Jackson purchased an English locomotive and had it shipped to Lowell where mechanics at the Lowell Machine Shop used it as a model to build their own locomotives. One of the first was called Patrick in honor of Patrick Tracy Jackson. From 1835 to the 1860s, the Lowell Machine Shop built 100 steam locomotives.

Whether it was advanced mill machinery, increasingly efficient water turbines, or some of the first locomotives built in this country, the Lowell Machine Shop was a center of innovation in 19th century America. The land it was built upon is now known as the Hamilton Canal Innovation District. As the city seeks to turn the vision for this new development into reality, we would be wise to embrace the site's past, and hope that history repeats itself.

# The Salvation Army Holiday Season Has Started

**by Soben Pin**

On November 3rd, I attended the Salvation Army of Greater Lowell's 24th Annual Christmas Castle Breakfast. It was a kick-off event that marked the beginning of the Holiday Season for The Salvation Army. What this means is that the Salvation Army has started taking applications for families who need help for Thanksgiving and Christmas. Every child deserves something for Christmas. Last year, over 600 families received help, 1,300 children received toys & clothing, and 3,000 senior citizens were visited and given a gift. All this was done by hundreds of volunteers and through donations.




Tom Golden Peter Gervais

At the breakfast, Peter Gervais, General Manager of Gervais Lincoln was honored for the Gervais Family's long history of helping the community, especially the Salvation Army. The event was moderated by State Representative Tom Golden, and complimented by three other speakers including: John Martin, General Sales Manager of Gervais Lincoln, Edward P. O'Neil, President of Corbett Development, and Michael Conway, President of Conway Insurance. It was a fun-filled and heartwarming event.

The Salvation Army Radiothon is on Saturday December 10th at 6am on 980AM WCAP, the annual event that fundraises through the auction items which were donated by individuals and businesses anything from sports tickets to a diamond ring. You may tune in to listen and call in to place your bid or make your pledge by texting 'RADIOTHON" TO 414-44.

# ជនជាតិ"ហម៉ុង"ម្នាក់ឡើងជាអភិបាលក្រុង"ឯកហ្គ្រោ"រដ្ឋកាលីហ្វ័រញ៉ា

**ប្រែសម្រួលដោយខ្មែរផុសស.រ.អា.**

ស្ទីវ លី Steve Ly អាមេរិកាំងដើមកំណើតជាជនជាតិ"ហម៉ុង"នឹងត្រូវធ្វើសច្ចាប្រណិធាននៅថ្ងៃទី១៤ធ្នូ ខាងមុខ នៅទីក្រុង "ឯកហ្គ្រោ" នៃរដ្ឋកាលីហ្វ័រញ៉ា ដើម្បីទទួលដំណែងជាអភិបាលក្រុងដែលមានពលរដ្ឋ១៦៧.000នាក់ ជាទីដំបូងបង្អស់របស់ប្រវត្តិសាស្ត្រជនជាតិ"ហម៉ុង"ដែលបានមករស់នៅសហរដ្ឋអាមេរិកនេះ។

គ្រួសារ ស្ទីវ ជាជនជាតិ "ហម៉ុង" រស់នៅជាជនជាតិភាគតិចរបស់ប្រទេសឡាវនិយាយភាសាខ្លួនឯងមានវប្បធម៌ប្រចាំជនជាតិ ប៉ុន្តែមិនមានប្រទេសទេ។ ជនជាតិ "ហម៉ុង" រស់នៅជាទាហ៊ានសម្ងាត់របស់សហរដ្ឋអាមេរិក ប្រយុទ្ធប្រឆាំងនឹងកុម្មុយនីស្តដែលរាតត្បាតនៅអាស៊ីអគ្នេយ៍។

ស្ទីវ លី បានមកដល់សហរដ្ឋអាមេរិក កាលពីជាង៣0ឆ្នាំមុន គេចផុតពីការគម្រាមកំហែងរបស់កុម្មុយនិស្ត នៅប្រទេសឡាវដែលខ្លួនរស់នៅ, ពេលនោះមានអាយុ៤ឆ្នាំ គ្រួសារគ្មានលុយហើយក៏មិនចេះភាសាអាមេរិកាំងថែមទៀត។ ជាទូទៅ ជនជាតិ "ហម៉ុង"នៅពេលមកដល់សហរដ្ឋអាមេរិក ច្រើនមករស់នៅជុំគ្នាជាសហគមន៍ជនជាតិធំនៅឯ"មេនីសុតា" នឹង "កាលីហ្វ័រញ៉ា"។

ស្ទីវ លី មុននឹងមកដល់ពេលកាន់សាលាក្រុង"ឯកហ្គ្រោ"នេះ មានតួនាទីជាអ្នកគ្រប់គ្រងកុមារ នៅមន្ទីឃុំឃាំងកុមារនឹងពេលយប់ធ្វើការនៅក្នុងសាលក្រុង"ឯកហ្គ្រោ"តែម្តង ។ ស្ទីវ បានក្លាយជាសកម្មជន"ហម៉ុង"នៅតំបន់របស់ខ្លួនចាប់តាំងពីចេញពីមហាវិទ្យាល័យ, ចំពេលតែចោទប្រកាន់ឧត្តមសេនីយ វ៉ាន់ ប៉ាវ ជាវីរបុរសជាតិរបស់ខ្លួនថា "បានឃុបឃិតដើម្បីទម្លាក់រដ្ឋា



ស្ទីវលី អភិបាលក្រុង

ភិបាលកុម្មុយនីស្តឡាវ ឆ្នាំ២00៧" ក៏រៀបចំតវ៉ាធ្វើបាតុកម្ម រហូតដល់បានរំដោះលោក វ៉ាន់ ប៉ាវ ពីការចោទប្រកាន់របស់រដ្ឋអាជ្ញាទាំងអស់បាន។ ស្ទីវ នឹងកាន់មុខងារថ្មី ជាអភិបាលក្រុងបន្ថែមពីមុខងារពីមុន បានប្រាក់ខែ៩.៦00ដុល្លាក្នុង១ឆ្នាំ ហើយនិយាយថា"ធ្វើជាអភិបាលក្រុងជាកាងារពេញម៉ោងតែបានប្រាក់ខែអ្នកធ្វើការពេលតិចម៉ោង" ស្ទីវ នឹងនៅតែធ្វើការដើម្បីគម្រោងបង្កើនការងារ៦,000បន្ថែមនៅក្នុងក្រុង,រកលុយសម្រាប់អភិវឌ្ឍន៏តាមចំណូលឱ្យបានសមរម្យពីកាស៊ីណូដែលត្រូវបង្កើត, នឹងកែរទម្រង់កុំឱ្យធ្វើដំណើរក្នុងក្រុងវ៉ាចង្អៀតពេក...៕

# Elk Grove makes history: Meet America's first Hmong mayor




The city of Elk Grove is making history with the election of the first Hmong mayor in the nation. Steve Ly was a refugee, who came to the United States as a child with no money and not knowing how to speak English.

Now, Ly is an American success story and about to be sworn in as mayor on Dec. 14.

By day, Ly is a juvenile hall counselor. "Eight hours a day, I come in and work with kids who have gotten in trouble," he said. Ly said he is "trying to make sure that they stay on the right track."

But at night, Ly is an Elk Grove city councilman. Next month, he assumes his historic role -- but one that he is downplaying.

**Mike Luery/KCRA**

Steve Ly smiles for KCRA on Thursday, Nov. 10, 2016. He is Elk Grove's mayor-elect and the first Hmong mayor in the country.

"It doesn't matter whether you came here 200 years ago or two months ago," Ly said. "I think what's important is that we -- as Americans -- bring a story."

Ly's story is an important chapter in American history.

It's the story of people escaping persecution. The Hmong were America's allies fighting against the Communists in the secret war in Laos. Ly's family fled the refugee camps of Southeast Asia and landed in America.

**Contiuned to Page 22**



# ACTIVE DAY® | SENIOR CARE®

**Under the same management as Lowell Elder Care**

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ -www.seniorcarectrs.com and www.activeday.com**

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្ដៅមួយដែលផ្ដល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យ មានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាស ដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺ គ្រប់គ្រាន់ បន្ទប់អានសៀវភៅបន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





## មណ្ឌលផ្ដល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្ដល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្ដៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ពិធីបុណ្យខ្មែរ និងព្រឹត្តិការណ៍សាសនា
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Open 7 Days a Week

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Observe Khmer Holidays & Religious Events
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

## តមកទំព័រទី ០៣ បោះឆ្នោតសាកលឆ្នាំ២០១៦...

គណបក្សប្រជាធិបតេយ្យ ហ៊ីឡារី គ្លីងតុន ដែលនៅលើបច្ចេក ទេស

ដដែលលោកទទួលជ័យជំនះជាថ្មីម្តងទៀត ដែលអង្គការសារព័ត៌មានខ្លាំងទាំងប៉ុន្មាន គ្មាននរណាទាយត្រូវថា"ឌុណាល ត្រុម" អាចឈ្នះបានឡើយ។ តើមានអភូតហេតុអ្វីដែលរំខានមិនឱ្យអង្គការសារព័ត៌មានទាយត្រូវដូចសព្វមួយដងយ៉ាងនេះ?

លទ្ធផលនៅក្នុងសេចក្តីថ្លែងការណ៍របស់ ត្រុម មានសារជាច្រើនដែលប៉ះអារម្មណ៏ម្ចាស់សន្លឹកឆ្នោត

**១-**យោងតាមបុព្វហេតុនៃវប្បធម៌បោះឆ្នោតមុនៗ -លោក ត្រុម មិនអាចជាប់ឆ្នោតបានទេ បើកាលណាមានអត្តចារឹកប្រើពាក្យអសុរសដាក់គូរបដិបក្សរបស់ខ្លួន ដូចជាហៅថា "ជនក្រខ្វក" "ជនសម្រាម" "ជនជាប់គុក"...-បើកាលណាប្រើពាក្យមិនសមរម្យ"នាងឯងមិនសមនឹងខ្ញុំតាមទេ" ឬមានភស្តុតាងថាបានប្រព្រឹត្តមិនគប្បីដាក់ស្ត្រីភេទ"ចែចង់ស្ទាបអង្អែល" -បើកាលណាមានបញ្ហាសង្គម ដូចជា "ប្រើកម្មករសំណង់ក្រោមតម្លៃទាបបំផុតក៏រឹតដោយច្បាប់" ដូចជា"មិនបង្ហាញវិក័យប័ត្រថា បានបង់ពន្ធជូនជាតិ" ការប្រើពាក្យមិនពិតរាប់មិនអស់បន្ទុះបង្អាប់គូរបដិបក្សរួចហើយ"ប្រកែកថាមិនបាននិយាយ"...ទាំងអស់នេះសុទ្ធតែជាបុព្វហេតុដែលអ្នកបោះឆ្នោតអាមេរិកាំងមិនដែលបោះឆ្នោតឱ្យបេក្ខជនរបៀបនេះទេ។

**២-**យោងតាមបុព្វហេតុសមត្ថភាព - លោក ឌុណាល ត្រុមមិនដែលធ្វើជាតំណាងរាស្ត្រជាអភិបាលរដ្ឋជាសមាជិកសភាតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាម្តងណាទេ ម្ល៉ោះហើយគ្មានបទពិសោធន៏ខាងនយោបាយខាងគ្រប់គ្រងនគរគ្រប់គ្រងប្រជាជាតិនឹងធ្វើច្បាប់ម្តងណាទេ។ បន្ថែមពីនេះទៀត ឌុណាល ត្រុម មិនដែលគ្រប់គ្រងក្នុងរដ្ឋាភិបាលនឹងគ្មានបទពិសោធន៏ខាងទំនាក់ទំនងកិច្ចការបរទេសអ្វីទាល់តែសោះលោក ឌុណាល ត្រុម ឡើងកាន់សេដ្ឋវិមាននៅឱកាសដែលប្រជាជាតិមានទំនាស់ដ៏តឹងតែងជាមួយ"រដ្ឋអ៊ីស្លាម",ជាមួយចិន, ជាមួយជនអន្តោប្រវេសន៏... ហើយពិសេសទៅទៀតនោះ លោក ឌុណាល ត្រុម ក៏មិន ដែលគ្រប់គ្រងវិស័យយោធារបស់សហរដ្ឋអាមេរិកទាល់តែសោះ... ដែលជាហេតុឱ្យគេឆ្ងល់ថា ហេតុអ្វីក៏អ្នកបោះឆ្នោតដ៏ច្រើនម្លឹងៗនាំគ្នាប្រថុយប្រថានអ្វីខ្លាំងម្លេះ? ដូចពេលបោះឆ្នោតមុនៗពលរដ្ឋមិនអាចបោះឆ្នោតឱ្យ ឌុណាល ត្រុម បានទេ។

**៣-**យោងតាមការគាំទ្ររបស់គណបក្សសាធារណរដ្ឋ -លោក ឌុណាល ត្រុម ឈរឈ្មោះបានតាមគោលការណ៏ច្បាប់គណបក្សមិនមែនដោយការគាំទ្រណាមួយទេ។ ឌុណាល ត្រុម ឈរឈ្មោះរួចហើយ ត្រូវប្រឈមមុខនឹងបេក្ខជនគណបក្សសាធារណរដ្ឋ១៥នាក់ទៀត ដែលយ៉ាងហោចណាស់ក៏មានចំនួនពាក់កណ្តាលដែរ ដែលមានបទពិសោធន៏ខាងនយោបាយខាងរដ្ឋបាលខាងកិច្ចការបរទេសខាងកិច្ចការយោធាច្បាស់លាស់ ជាង ឌុណាល ត្រុម ដូចជា ប៊ូស - សំតួរ៉ូមជាដើម។ នៅពេល ឌុណាល ជម្រុះអ្នកទាំង១៥ដោយពាក្យអាសុរសជាច្រើននឹងដោយប្រយោគមិនពិត ឬមើលងាយម្តងមួយៗធ្វើឱ្យបេក្ខជនដែលឈរឈ្មោះប្រជែងដកខ្លួនចេញទាំងអាម៉ាសពីសៃវេណជដែកពិភាក្សា រហូតដល់បានការតែងតាំងជាតំណាងគណបក្សសាធាររដ្ឋជា"បេក្ខជនប្រធានាធិបតី"នៅមហាសន្និបាទបានតែមិនមានការគាំទ្រពីតំណាងជាន់ខ្ពស់របស់គណបក្សទេ នេះគឺជារឿងចម្លែករបស់ ដណាល ត្រុម។ បន្ថែមពីនេះ ឌុណាល ត្រុម មិនប្រើ "ថវិកាឃោសនាបោះឆ្នោត"ពីសាធារណជនដែលធម្មតា បេក្ខជនតែងលុយពីមហាសេដ្ឋីនៃគណបក្សរបស់ខ្លួនដូចពេលមុនៗទេ គេឃើញអ្នកដែលខកខានមិនបានឱ្យលុយឃោសនានោះមានការខឹងសម្បាដោយត្រូវយកលុយនោះទៅ"បង់តាក់"ទៅវិញ រឹតតែបាត់បង់មិត្តមួយក្រុមទៀត។នៅលើលទ្ធផលផ្ទុយពីទម្លាប់របៀបនេះ អ្នកវិភាគជាច្រើននឹងខ្មែរផុសស.រ.អា. បានបញ្ចេញយោបល់ថាៈ

**ក-**ពលរដ្ឋអាមេរិកាំងមានការអាក់អន់ចិត្តយ៉ាងខ្លាំង ចំពោះនយោបាយ៨ឆ្នាំរបស់ "អូបាម៉ា" មកពីគណបក្សប្រជាធិបតេយ្យដែលមិនមិនត្រឹមតែមិនបានលើកដំកើងជីវភាពពលរដ្ឋថែមទាំងធ្វើឱ្យធ្លាក់ចុះស្តារឡើងមិនបាន -ពលរដ្ឋទាំងនោះក៏អន់ចិត្តនឹងសមាជិកថ្នាក់ដឹកនាំគណបក្សសាធារណរដ្ឋដូចគ្នាដែរ ដែលមិនហ៊ានវះកាត់ឱ្យដាច់ណាត់ប្តូចរន្តនយោបាយឱ្យជ្រះស្រឡះពីចរន្តចាស់គម្រិល។ ថ្វីត្បិតតែ ហ៊ីឡារី គ្លីងតុង មានប្រជាប្រិយភាពខ្លាំងក៏ដោយ នឹងនៅតែ "បន្តនយោបាយចាស់" របស់ បារ៉ាក់ អូបាម៉ា ដដែល -ម្យ៉ាងទៀតអ្នកនយោបាយខាងគណបក្សសាធារណរដ្ឋពីមុនៗមក ក៏មិនបានកែរទម្រង់សហរដ្ឋអាមេរិកឱ្យស៊ីជម្រៅបានតាំងតែពីជំនាន់ ឌុណាល រ៉េហ្គាន់ (១៩៨១ -៨៩) មកម្ល៉េះបាន។ ម្ល៉ោះហើយពួកវណ្ណៈកណ្តាលអាមេរិកាំង ដែលកាន់កាប់សន្លឹកឆ្នោតដ៏សន្ធឹកសន្ធាប់នោះ គេត្រូវតែប្តូរនយោបាយឱ្យផុតពីអតីតកាលឱ្យបាន គឺឱ្យឈ្នះលើគណបក្សប្រជាធិបតេយ្យនឹងឱ្យឯករាជ្យពីគណបក្សសាធារណរដ្ឋចេញ។ ឌុណាល ត្រុម ចេញមក "ចំពេលនឹងចំសេចក្តីត្រូវការ"របស់ម្ចាស់ឆ្នោតទាំងឡាយនោះដោយសារជា"កំពូលអ្នកមាន"ដែលគេជឿដោយឃើញនឹងភ្នែកថា មានសមត្ថភាពដឹកនាំសេដ្ឋកិច្ចបានដែលគេជឿថា នឹងខុសពីអ្នកឯទៀតៗ ដោយចារឹករឹងរូសធ្វើការដោយ"គ្មាននរណាទាយត្រូវជាមុន" ដែលគេជឿថា "អាមេរិកត្រូវតែត្រឡប់ទៅជាអស្ចារ្យម្តងទៀត"វិញដូចជំនាន់"រ៉េហ្គាន់"


រ៉ូណាល់ រីហ្គាន់

ជាមួយនឹងការដឹកនាំថ្មីស្រឡាងមួយ។

**ខ-**បច្ចេកទេសនៃការឃោសនា គឺយកពីបទពិសោធន៏នៃការដណ្តើមទីផ្សារសេដ្ឋកិច្ចពិដៃគូរប្រជែងគ្នា, ឌុណាល បាននិយាយពីបច្ចេកទេសនោះហើយថា"គេរំលោះគូរប្រជែងមួយម្តងៗ រួចហើយនៅសល់តែ ហ៊ីឡារី តែម្នាក់ឯងវាជាការងាយស្រួលបំផុត"។ ពីអ្នកឯទៀត នៃគណបក្សជាមួយគ្នាអ្នកទាំងនោះត្អូញត្អែពីការនិយាយបំប្លើសពីការពិតពីស្ថានភាពនយោបាយជាច្រើនដែលបានកើតឡើង តាមរយសម្តីរបស់ ឌុណាល ត្រុម ក្នុងរូបភាព គួរឱ្យឆ្អើមស្អុយរលួយ ឬក៏បរាជ័យដែលក្នុងទម្លាប់នឹងសីលធមិរបស់គូប្រជែងទាំងនោះមិនអាចតបតនឹង ឌុណាល ក្នុងវិធីសាស្ត្រដូចគ្នាវិញបាន ក្រៅតែពីការដកខ្លួនកុំឱ្យការតិះដៀលវាធ្វើឱ្យឈឺចាប់ខ្លាំងពេក។ ហ៊ីឡារី គ្លីងតុង ប្រឈមមុខនឹង ត្រុម ក៏រងសម្ពាតដូចគ្នាខំប្រឹងឆ្លើយតបតរតាមដោយប្រើពាក្យអាសុរសដូចគ្នា ក៏បាត់បង់ប្រជាប្រិយភាពដែលខ្លួនមិនអាចទ្រាំទ្របាន, ចំណែក ត្រុម វិញបាត់បង់ប្រជាប្រិយភាពដូចគ្នាតែពុំមានប្រតិកម្មអ្វីទាំងអស់ថែមទាំងរឹតតែផ្តើនទៅទៀត ពីព្រោះវាជាពាណិជ្ជកម្មដែលគេត្រូវយក"ភ្ញៀវ"ឱ្យបាន។ នៅពេលដែល ហ៊ីឡារី បញ្ឈប់ការតបតរដោយពាក្យអសុរសនៅ២សប្តាហ៏ចុងក្រោយពេលនោះហើយដែលសារធារណជនយល់ថា ហ៊ីឡារី ពិតជាខុសមែនហើយ! រឿង "អ៊ីមែលខុស ច្បាប់" ដែល "អេហ្វប៊ីអាយ" មិនមានចោទ ប្រកាន់អ្វីទៀតនោះ ក៏ ហ៊ីឡារី នៅតែខុសមិន អាចឈប់បានឡើយ។

**គ-**ចរន្តនយោបាយសហរដ្ឋអាមេរិកពេលនេះ គឺ"ចរន្តផ្លាស់ប្តូរ" រីឯ ហ៊ីឡារី គ្លីងតុន ជាបេក្ខជនដ៏ខ្លាំងម្នាក់មកឈរឈ្មោះនៅពេលនេះគឺជា"ចរន្តបន្ត" ដូច្នេះសម្រាប់អាមេរិកាំង "វណ្ណៈកណ្តាល"គឺជាការផ្តើនដែលតម្រូវឱ្យមាន "ការរើបម្រាស"។ គេទើបនឹងឃើញឧទាហរណ៏នៃ "ការរើបម្រាស"របៀបនេះ នៅចក្រភពអង់គ្លេសពេលឆ្នាំមុននេះសោះ, ប្រទេសអង់គ្លេសជាមហាអំណាចនៅអឺរ៉ុប ដែលបានផ្តួចផ្តើមបង្កើត "សហភាពអឺរ៉ុប"ឥឡូវរួមប្រជុំដោយប្រទេសចំនួន២១, ដោយស្ថានភាពសេដ្ឋកិច្ចដុនដាបមិនអាចងើបរួចភេរវករមកដាក់គ្រាប់បែកឱ្យផ្ទុះកណ្តាលក្រុង "ឡុងដុន" ពលរដ្ឋអស់សង្ឃឹមនឹងនៅក្នុងសម្ព័ន្ធភាពអឺរ៉ុបបានក៏បោះឆ្នោតប្រជាមតិ "ប្រឆាំងនឹងយោបល់រដ្ឋាភិបាល", បញ្ជាឱ្យដកខ្លួនចេញពី "សហភាពអឺរ៉ុប"ភ្លាមដែរ ដែលគេឱ្យឈ្មោះថា"ពរខេិត"រដ្ឋាភិបាលដែលគាំទ្រឱ្យ"នៅ" បានដួលរលំហើយជំនួសដោយរដ្ឋាភិបាលថ្មីមួយទៀតដែលមានភារកិច្ចធ្វើឱ្យចក្រភពអង់គ្លេស"អស្ចារ្យសារជាថ្មី"មកវិញ។ ត្រង់នេះ អូបាម៉ា មានយោបល់ថា "មិនដូចពរខេិតទេ មានចរន្ត២ដែលនាំឱ្យមានការព្រួយបារម្ភយ៉ាងនេះ គឺចរន្តសាធារណរដ្ឋ ឌុណាល ត្រុម នឹងចរន្តមួយទៀត ប៊ឺនី សិនឌើ ខាងគណបក្សប្រជាធិបតេយ្យដែលបង្កបានជាកម្លាំងថ្មីចង់ផ្លាស់ប្តូរនេះ។

លោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា នៅពេលជួបប្រាស្រ័យទាក់ទងដំបូងជាមួយប្រធានាធិបតីជាប់ឆ្នោត ឌុណាល ត្រុម បានឱ្យយោបល់ថា"សម្តីបេក្ខជនប្រធានាធិបតី មិនដូចគ្នានឹងសម្តីប្រធានាធិបតីទេ ដែលតែនិយាយហើយ មានអ្នកផ្សេងទៀតស្តាប់ឮ ហើយយកទៅអនុវត្តន៏ភ្លាម"។

## តើចរន្តបោះឆ្នោតនៅសង្កាត់លេខ១៨ម៉ា សាឈូសិតមានន័យយ៉ាងណា?




សហគមន៏ខ្មែរជាច្រើន នៅសង្កាត់លេខ១៨ មានការមិនទុកចិត្តចំពោះបេក្ខជន រ៉ាឌី ម៉ម ចាប់តាំងពីបោះឆ្នោតឆ្នាំ២០១៤ចប់ភ្លាមមកម្ល៉េះ, ខេមរា កៃ ក៏បានលេចចេញជាបេក្ខជន ដែលតំណាងឱ្យសហគមន៏ខ្មែរអ្នកមិនសប្បាយចិត្តទាំងនោះភ្លាមដែរ។ អ្នកដែលគាំទ្រខាងតំណាងរដ្ឋ រ៉ាឌី ម៉ម ចរន្តក្រុមស្បែកសនៅសភាបូស្តុន នៅ សាលាក្រុងនៅក្នុងគណបក្សប្រជាធិបតេយ្យនឹងមានអ្នកដែលចង់ឃើញមានវិនិយោគពីភ្នំពេញ មកកាន់ក្រុងឡូវែល **តទៅទំព័រទី ១៥**

ភូមិសាស្ត្រនយោបាយ

# ចិនដាក់ទណ្ឌកម្មលើកូរ៉េខាងជើង

**ដោយខ្មែរផុសស.រ.អា.**

គីម យ៉ង់អ៊ូន ប្រធានាធិបតីប្រទេសកូរ៉េខាងជើងបានផ្ញើរសារមួយមក ឌុណល ត្រម ប្រធានាធិបតីជាប់ឆ្នោតអាមេរិកាំងនៅថ្ងៃបន្ទាប់ពីជាប់ឆ្នោតមកមិនមែនជូនពរទេតែរំលឹកសហរដ្ឋអាមេរិកថា"កូរ៉េខាងជើងមានអាវុធបរមាណូដែលបានសាករួចហើយ ឱ្យអាមេរិកកុំភ្លេចនឹងធ្វើការចរចារនឹងខ្លួន"។ កូរ៉េខាងជើងចង់ធ្វើមហាអំណាចយោធាដោយចង់ខិតជិតអាមេរិកាំង បានត្រូវប្រទេសចិនប្រកាសដាក់ទណ្ឌកម្មសេដ្ឋកិច្ចជាលើកដំបូងនឹងគួរឱ្យចម្លែកនាថ្ងៃបន្ទាប់ភ្លាមមក។

ប្រធានាធិបតីនៃកូរ៉េខាងត្បូងលោកស្រី ប៉ាក់ គើនហ៊ី មានការព្រួយបារម្ភជាងគេ ដោយសារភាពគ្រោះថ្នាក់ដោយអាវុធប្រល័យលោកចម្ងាយខ្លីនេះ នៅក្នុងដែជនផ្តាច់ការបានធ្វើការតវ៉ាឱ្យបញ្ឈប់ការបង្កើតអាវុធបរមាណូនៅកូរ៉េខាងជើងនេះតាំងពីខែមិនាមកម្ល៉េះ ហើយអង្គការសហប្រជាជាតិក៏បានសម្រេចទាមទារឱ្យធ្វើការបញ្ឈប់ផលិតកាំជ្រួចនេះរួចហើយដែរ តែកូរ៉េខាងជើងមិនដែលសម្តែងការខ្វល់ខ្វាយនឹងសេចក្តីសម្រេចនោះទេ។

ជាលើកដំបូងបង្អស់នឹងគួរឱ្យចម្លែកប្រទេសចិនដែលនៅជិតគ្នានោះ បានបង្ហាញធ្មុងទៅកូរ៉េខាងជើងដែលតែងតែក្អេងក្អាងដោយកម្លាំងទ័ពដ៏ខ្លាំងក្លារបស់ខ្លួនដាក់កូរ៉េខាងត្បូងដែលនៅជាប់ព្រំដែនគ្នា, ដាក់ "ណេតូ" ដែលកំពុងជាប់ដៃនឹង "អាយស៊ីស"រដ្ឋមូស្លីមនៅតំបន់កណ្តាលខាងកើត, ដាក់សហរដ្ឋអាមេរិកដែលកំពុងជាប់ដៃធ្វើការបោះឆ្នោតប្រធានាធិបតី...ឥឡូវក៏បានជួបចិនដែលតែងតែស្ងៀមស្ងាត់មិនដែលលូកដៃទៅកកូរប្រទេសណាមួយនោះ ស្រាប់តែចេញមុខមុនគេដាក់ទណ្ឌកម្មសេដ្ឋកិច្ចដល់កូរ៉េខាជើង ដែលជាកុម្មុនិស្តដូចគ្នាតាមសេចក្តីសម្រេចចិត្តរបស់ អ.ស.ប. ដែលចិនជាសមាជិកក្រុមប្រឹក្សាសន្តិសុខដែរនោះ។

តើការដាក់ទណ្ឌកម្មសេដ្ឋកិច្ចនេះប៉ះពាល់ដល់ផលប្រយោជន៏អ្វីខ្លះទៅប្រទេសកូរ៉េខាងជើងឬទេ? មាន! កូរ៉េមិនអាចទីញនឹងលក់ផលិតផលរបស់ខ្លួន ទៅឱ្យប្រទេសដ៏ទៃបានទេ, ហើយក៏មិនអាចទៅទិញឥវ៉ាន់ពីប្រទេសក្រៅវិញបានដែរ ជារួម គឺការលក់នឹងទិញផលិតផលដែលថវិការអាចនឹងបង្វៀងទៅផ្គត់ផ្គង់ការផលិតអាវុធបរិមាណូបាន។ គ្រាន់តែប្រទេសចិនតែមួយអាចបញ្ឈប់ការទិញធ្យូងថ្មដែលមានតម្លៃ១ពាន់លានដុល្លាក្នុង១ឆ្នាំ ថែមទាំងមានការទិញឥវ៉ាន់ផ្សេងៗទៀតដែលមានតម្លៃប្រមាណ៥០០លានដុល្លាថែមផ្សេងទៀត។ តែទោះជាយ៉ាងណាក៏តែមិនឱ្យពលរដ្ឋកូរ៉េខាងជើងវេទនាអត់បាយនោះទេ ដរាបណាតែការដោះដូរទាំងឡាយមិនប៉ះពាល់ដល់ការបង្កើនចំនួន ឬគុណភាពអាវុធបរមាណូនឹងគ្រាប់កាំជ្រួចមីស៊ូលទេនោះ។



Chinese President Xi Jinping



លោកស្រីប្រធានាធិបតីកូរ៉េខាងត្បូង ប៉ាក់ គើនហ៊ី

ដោយសារកូរ៉េខាងត្បូងជាបក្សសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិកចិននឹងអាមេរិកបានធ្វើការយ៉ាងជិតស្និតដើម្បីពង្រឹងទណ្ឌកម្មលើកូរ៉េខាងជើងរឹតតែខ្លាំងឡើង កាលពីសប្តាហ៏មុននេះថែមទៀត។ ធ្វើយ៉ាងនេះចិននឹងបានចំណេញអត្ថប្រយោជន៏២យ៉ាងគឺ **១-**ចិនបង្ហាញថា ខ្លួនជាក៏រឹតមហាអំណាចក្នុងតំបន់ម្នាក់ទៅហើយ **២-**គឺជាការពង្រឹងឥទ្ធិពលលើប្រទេសទាំងឡាយដែលនៅជុំវិញសមុទ្រចិនកុំឱ្យវាយស្ទើក្នុងការតវ៉ារឿងកោះ"សប្រាតលី"ក្នុងសមុទ្រចិនតទៅទៀត។

ដែលចម្លែកនោះ ការដាក់ទណ្ឌកម្មទៅលើប្រទេសដ៏ទៃ គឺចិនមិនដែលធ្វើពីមុនមកនៅឡើយទេ នេះឱ្យសញ្ញាច្បាស់ក្រឡែតថា "ចិនលែងនៅជាខ្លាក្រដាស"ដូចមុនទៀតហើយ ចិនបានផ្តើមបង្ហាញឥរិយាបទឆ្លើយតបទាំងឡាយមាន"លំដាប់ថ្នាក់ជាអ្នកដឹកនាំគេ"៕







Kin Jung-Un North Korea




# តើប្រទេសកម្ពុជា នឹងទទួលផលវិបាកអ្វីខ្លះ ពីជម្លោះកោះនានា នៅសមុទ្រចិនខាងត្បូង ?

## ប្រទេសកម្ពុជាទទួលផលវិបាកពីការបាត់បង់អធិបតេយ្យភាពទៅលើផ្ទៃសមុទ្រ និងកោះ

ផលវិបាកដែលប្រទេសកម្ពុជាទទួលបានមកពីជម្លោះកោះនានានៅសមុទ្រចិនខាងត្បូង គឺត្រង់ចំណុច ដែលគ្រប់ៗ ប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ គេចេះថែរក្សា ការពារ តំបន់ផ្ទៃសមុទ្រ និងកោះឲ្យឋិតនៅក្រោមអធិបតេយ្យភាពរបស់ប្រទេសគេរៀងៗខ្លួន។ លើកលែងតែព្រះរាជាណាចក្រកម្ពុជាមួយទេ ដែលបានបោះបង់ចោលអធិបតេយ្យភាព ទៅលើផ្ទៃសមុទ្រ និងកោះ របស់ខ្លួនផ្ទាល់។

នេះជាក្តីសង្ឃឹមនិងជាឱកាសដ៏ពិសេសថ្លៃថ្លា ជំរុញឲ្យប្រទេសកម្ពុជាចេះការពារអធិបតេយ្យភាពទៅផ្ទៃសមុទ្រនិងកោះទាំង៦៤ នៅចំពេលដែលមានជម្លោះកោះនានានៅសមុទ្រចិនខាងត្បូង ដែលតុលាការអន្តរជាតិលើក «ច្បាប់សមុទ្រ» មកនិយាយមិនឈប់ឈរ។ បើប្រទេសកម្ពុជាមិនលើកបញ្ហាផ្ទៃសមុទ្រនិងកោះមកនិយាយក្នុងពេលនេះទេផ្ទៃសមុទ្រនិងកោះទាំង៦៤នោះត្រូវលាយសាបសូន្យ ដោយស្នាដៃអ្នកដឹកនាំព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះតែម្តង។

ផ្ទៃសមុទ្រនិងកោះផ្តល់ផលប្រយោជន៍ធំធេងណាស់ចំពោះប្រទេសជាតិ និងជនជាតិខ្មែរ ផ្តល់មកពីការនេសាទ ជាតំបន់អភិវឌ្ឍន៍សម្រាប់ទេសចរ និងការរីកចម្រើនខាងពាណិជ្ជកម្មតាមផ្លូវទឹក ។

នៅលើដីគោក ការដុតព្រៃ កាប់ឈើលក់ ព្រមទំាំងទន្លេ ស្ទឹង បឹង ក៏រីងស្ងួតដោយសារតែអស់ព្រៃឈើ។ ធាតុអាកាសប្តូរខុសពីធម្មតា ធ្វើឲ្យអ្នកស្រែចំការខ្វះទទួលរងគ្រោះវេទនាជួបប្រទះតែនឹងការក្រីក្រអត់ឃ្លានក្នុងគ្រួសារ ។

បើកម្ពុជាបាត់បង់ផ្ទៃសមុទ្រនិងកោះនោះទៀត តើអធិបតេយ្យភាពនៅគង់វង់បានឬទេចំពោះប្រទេសជាតិនិងជនជាតិខ្មែរ ? ។

យើងសុំរំលឹកឡើងវិញថា ប្រទេសកម្ពុជាក្លាយជាសមាជិកអាស៊ានក្នុងថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៩ ។ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ឬ អាស៊ាន (Association of Southeast Asian Nations: ASEAN) ជាអង្គការនយោបាយ និងសេដ្ឋកិច្ច នៃប្រទេសចំនួន ១០ នៅតំបន់អាស៊ីអាគ្នេយ៍។ អង្គការកម្រិតតំបន់នេះបង្កើតឡើងនៅថ្ងៃទី៨ ខែសីហាឆ្នាំ១៩៦៧។ ។

ប្រទេសទាំង៩នេះ គេការពារផ្ទៃសមុទ្រនិងកោះរបស់គេណាស់ ខុសពីប្រទេស១ទៀតនោះគឺប្រទេសកម្ពុជាមិនត្រឹមតែមិនចេះការពារទេ ថែមទាំងប្រគល់ទៅឲ្យយួនដោយខុសច្បាប់ និងបំផ្លាញមនសិការជាតិទៀតផង ។

កូនខ្មែរ ទាំងអស់នៅលើសកលលោក ឈរនៅលើសម្បជញ្ញៈនិងឧទ្ទៈដ៏ខ្ពង់ខ្ពស់ ដើម្បីទាមទារយកអធិបតេយ្យភាពនៅលើផ្ទៃសមុទ្រនិងកោះមកវិញ ។

គ្មានសាសន៍ណាមួយមកជួយការពារតំបន់សមុទ្រនិងកោះខ្មែរ ក្រៅពីសាសន៍ខ្មែរខ្លួនឯងនោះទេ។

## ជម្លោះទឹកសមុទ្រ និងកោះរវាង ប្រទេសចិន និងប្រទេស ហ្វីលីពិន

ដូច្នេះខ្មែរត្រូវតែចេះគិត ចេះពិចារណា ស្មោះត្រង់នឹងជនជាតិខ្មែរដូចគ្នា និងប្រទេសខ្លួនឯង ដូចប្រទេសហ្វីលីពិន (Philippines) ដែលគេចេះការពារផ្ទៃសមុទ្រ និងកោះរបស់គេនៅពេលមានជម្លោះជាមួយនឹងប្រទេសចិន (Chine) ។

ប្រទេសហ្វីលីពិន ខិតខំខ្នះខ្នែងធ្វើឲ្យអ្នកសង្កេតការណ៍ជាច្រើនបានរំពឹងទុកថា តុលាការអាជ្ញាកណ្តាលអន្តរជាតិ (Cour d'arbitrage internationale) នឹងគ្រប់គ្រងពាក្យបណ្តឹងរបស់ប្រទេសហ្វីលីពិន ។

តុលាការអាជ្ញាកណ្តាលអន្តរជាតិយល់ស្របយោងទៅតាមឯកសាររបស់ប្រទេសហ្វីលីពិនស្តីពី «ច្បាប់សមុទ្រ» នៅលើទឹកសមុទ្រភាគខាងលិចនៃប្រទេស ហ្វីលីពិន (1) ។

ចៅក្រមយល់ថាប្រទេសចិននឹងមិនទទួលស្គាល់នូវសេចក្តីសម្រេចនេះទេ ។

ប្រធានាធិបតីប្រទេសហ្វីលីពិនលោក Rodrigo Duterte នឹងដោះស្រាយទន់ភ្លន់ជាមួយនឹងប្រទេសចិនក្រោយពីសេចក្តីសម្រេចរបស់តុលាការ (2) ។

## ពិភពលោកនឹងរង្គោះរង្គើ

លោក Docteur Henry Kissinger សរសេរ នៅក្នុងខែកក្កដាឆ្នាំ ១៩៧១ ថា «នៅពេលដែលខ្ញុំទៅធ្វើទស្សនកិច្ចជាសម្ងាត់នៅទីក្រុងប៉េកាំង លោក ជូ អេង ឡាយ លើកយក "ទស្សនៈពិភពលោក" របស់លោក ម៉ៅ សេងទុង : «អ្វីៗ គ្រប់យ៉ាងនៅក្រោមមេឃនេះនឹងរង្គោះរង្គើ ក៏ប៉ុន្តែស្ថានភាពមានភាពប្រសើរល្អប្រពៃ» (៣) ។

នៅថ្ងៃអាទិត្យទី ៣១ ខែកក្កដាឆ្នាំ ២០១៦ អ្នកកាសែត អា ប៉េ Associated Press បានដកស្រង់ចេញពីសារព័ត៌មានចិន ស៊ីនហួរ: «នៅក្នុងក្រសួងការពារជាតិ ក្នុងឱកាសបុណ្យខួបលើកទី ៨៩ នៃការបង្កើតកងទ័ពរំដោះប្រជាជនចិន លោក Chang Wanquan រដ្ឋមន្ត្រីក្រសួងការពារជាតិមានប្រសាសន៍ថា ៖ "ប្រទេសចិនបានរំលឹកឡើងវិញនូវការប្តេជ្ញាចិត្ត ក្នុងការការពារអធិបតេយ្យភាពរបស់ខ្លួន នៅចំពេលដែលមានភាពតានតឹងជាថ្មី លើការទាមទារទឹកដីនិងដែនសមុទ្ររបស់ចិន នៅសមុទ្រចិនខាងត្បូង (4) ។

ប្រធានាធិបតីប្រទេសហ្វីលីពិន លោក Rodrigo Duterte អញ្ជើញទៅប្រទេសចិននៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៦ (5) ។

លោកនាយករដ្ឋមន្ត្រីប្រទេសម៉ាឡេស៊ី បានអញ្ជើញទៅធ្វើទស្សកិច្ចនៅទីក្រុងប៉េកាំង ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦ (6) ។

## មានការវិនិច្ឆ័យរបស់តុលាការអន្តរជាតិ ពីជម្លោះដែនសមុទ្រ និងកោះនៅតំបន់អាស៊ីអាគ្នេយ៍

លោក Vincent Herbert និងលោក Jean-rené Vanney មានប្រសាសន៍ថា សមុទ្រចិន ជាផ្នែកមួយនៃតំបន់អាស៊ីអាគ្នេយ៍ (7) ។

ជម្លោះអធិបតេយ្យភាពនៃកោះនៅក្នុងបណ្តាប្រទេសអាស៊ាន ដែលយើងបានកត់សម្គាល់នៅក្នុងការវិនិច្ឆ័យរបស់តុលាការអន្តរជាតិមាន ៖

១ - ប្រទេស ម៉ាឡេស៊ី ជាមួយនឹង ប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ២០០២ (8)

២ - ប្រទេសសិង្ហបុរី ជាមួយនឹងប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ២០០៨ (9) ។

នៅពេលដែលប្រតិភូសិង្ហបុរីលើកបញ្ហាកោះ PEDRA BRANCA/PULAU BATU PUTEH, MIDDLE ROCKS ET SOUTH LEDGE ប្រទេសម៉ាឡេស៊ីស្រាប់តែភ្ញាក់ខ្លួន ហើយប្រកែកថាកោះទាំងអស់នេះស្ថិតនៅក្រោមអធិបតេយ្យភាពរបស់ប្រទេសម៉ាឡេស៊ីទេ ។

ក៏ប៉ុន្តែប្រតិភូសិង្ហបុរីបានលើកសេចក្តីឡើងថា ប្រទេសម៉ាឡេស៊ីហាក់ដូចជាភ្លេច និងមិនបានបញ្ជាក់ថាកោះទាំងអស់នោះជាកោះរបស់ប្រទេសម៉ាឡេស៊ីទេ។ ពេលនោះ ប្រតិភូសិង្ហបុរី ក៏លើករឿងកាត់ក្តីព្រះវិហារក្នុងឆ្នាំ១៩៦២ ជាគំរូ មកបកស្រាយនៅមុខចៅក្រមតុលាការអន្តរជាតិ (10) ។

## គ្មានការវិនិច្ឆ័យរបស់តុលាការអន្តរជាតិ ពីជម្លោះដែនសមុទ្រ និងកោះនៅតំបន់អាស៊ីអាគ្នេយ៍

ពីឆ្នាំ១៩៧៩ ទៅឆ្នាំ១៩៨០ មានការប្រកាសឆ្លងឆ្លើយទៅវិញទៅមកពីរឿងកោះ ប៉ារ៉ាសែល (Paracels) និងនៅជុំវិញកោះ។ រហូតមកដល់ខែមេសា ទៅខែឧសភា ឆ្នាំ១៩៧៩ ទើបមានការជួបជុំជជែកនៅហាណូយរវាងប្រទេសចិន និងប្រទេសវៀតណាម ។

ប្រតិភូចិន បានប្រាប់ទៅប្រទេសវៀតណាមថា កោះទាំងអស់នោះជាកោះរបស់ចិនទេ ហើយឲ្យប្រទេសវៀតណាមទទួលស្គាល់អធិបតេយ្យភាពរបស់ចិនលើប្រជុំកោះនេះផង ។

តែការទាមទារនេះ ត្រូវប្រទេសវៀតណាមបានច្រានចោលចេញទាំងស្រុង (11) ។

ជម្លោះនៅលើសមុទ្រ និងជុំវិញកោះប៉ារ៉ាសែលមានរហូតមកដល់ឆ្នាំ ២០១៤។ លោក Bruno Philip សរសេរនៅក្នុងទស្សនាវដ្តី ឡឺម៉ុង (Le Monde) ភ្ជាប់ជាមួយរូបថតដែលគេឃើញកុប៉ាល់សមុទ្រចិនកំពុងបាញ់ទឹកទៅលើនាវាយាមល្បាតរបស់យួន នៅថ្ងៃ ទី៧ ខែឧសភា ឆ្នាំ២០១៤ (12) ។

## ទំហំផ្ទៃសមុទ្រ និងកោះរបស់ប្រទេសខ្មែរ

បើយើងក្រឡេកមើលទៅផែនទីភូមិសាស្ត្ររបស់លោក Vincent Herbert និងលោក Jean-rené Vanney យើងនឹងឃើញកោះរបស់ខ្មែរយើងទាំង៦៤ ជាពិសេសគឺកោះត្រល់ដែលស្ថិតនៅក្នុងឈូងសមុទ្រថៃ។

ក្នុងឆ្នាំ ១៨៦៩ មានអ្នកប្រាជ្ញបារាំងសែសខាងភូមិសាស្ត្រមួយឈ្មោះ Malte-Brun បានគូសផែនទី (Carte du Royaume de Siam, de la Cochinchine française et du Royaume du Cambodge) ផាត់ពណ៌ខៀវនៅចំប្រទេសកម្ពុជានិងកោះត្រល់ ចេញផ្សាយ មុនពេលដែលប្រទេសបារាំងមានអធិបតេយ្យភាព នៅចុងបូព៌ាប្រទេស (Extrême-Orient) ពីឆ្នាំ១៨៨៥ ទៅដល់ឆ្នាំ១៩៤៥ មកម្ល៉េះ (13) ។

## ការរំលោភ និងមិនគោរពពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១

ផលវិបាកដែលគ្មានអធិបតេយ្យភាពនៅលើផ្ទៃសមុទ្រនិងកោះរបស់ខ្មែរ ក៏ព្រោះតែរាជរដ្ឋាភិបាលមិនព្រមរំលាយសន្ធិសញ្ញា និងកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខារវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

បើយើងលើកយកប្រវត្តិសាស្ត្រពិភពលោកមកលាតត្រដាង យើងនឹងឃើញថា នាពេលដែលប្រទេសបារាំងមានអធិបតេយ្យភាព ក្នុងពេលដែលកងទ័ពណាស៊ីតាញ់ចំបាំងនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ ១៩៤៥ លោកឧត្តមសេនីយដឺហ្គោល ជាប្រធានអ្នកប្រយុទ្ធរបស់ប្រទេសបារាំង និងជាប្រធានគណៈកម្មាធិការជាតិ បានចេញដីកាមួយមាន១៣មាត្រា ធ្វើនៅទីក្រុងឡុងដ៍ ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៤៣។ ដីកានេះ បញ្ជាឲ្យលុបគ្រប់សន្ធិសញ្ញា និងច្បាប់ដែលរដ្ឋវីស៊ី (L'Etat de Vichy) ព្រមព្រៀងជាមួយនឹងកងទ័ពណាស៊ី ហើយនឹងឲ្យបោះបង់ចោលទាំងអស់ ។

លោក Jean Brethe de la Gressaye សាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់ខេត្តបរ័ដូ (Bordeaux) ក៏បានបញ្ជាក់ពីការលុបបំបាត់គ្រប់កិច្ចព្រមព្រៀង និងសន្ធិសញ្ញាណាដែលបានធ្វើជាមួយនឹងកងទ័ពណាស៊ីដែរ (14) ។

បន្ទាប់ពីចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ក្រោមសហប្រធាននៃប្រទេសបារាំង នាយករដ្ឋមន្ត្រីបច្ចុប្បន្ន(ហ៊ុន សែន) មិនបានលុបចោល សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយដែលបានចុះហត្ថលេខាជាមួយ និងសាធារណរដ្ឋសង្គមនិយមវៀតណាមទេ។

ជាបញ្ចប់ បើនាយករដ្ឋមន្ត្រីបច្ចុប្បន្ន(ហ៊ុន សែន) គោរពកិច្ចព្រមព្រៀងក្រុងប៉ារីស ២៣ តុលា ១៩៩១ ប្រទេសកម្ពុជានឹងបានទទួលអធិបតេយ្យភាពនៅលើផ្ទៃសមុទ្រ និងកោះទាំង៦៤ ជាមិនខាន ។

សាគូ សាមុត



នាវាចម្បាំងចិននៅដែនសមុទ្រចិនខាងត្បូង

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ

អាយុ ២២ ឆ្នាំឡើងទៅ

- មាសហ៊ែលស្តង់ដា

ផលប្រយោជន៍ទទួលបាន :

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# រំលឹកព្រឹត្តិការណ៍ព័ត៌មានពីថ្ងៃទី១ មិថុនា ដល់១ សីហា ឆ្នាំ២០១៦

Press Review

**ដោយ ហ្វ្រង់ស្វា ប៉ុងសូ**

**បកប្រែពីភាសាបារាំងដោយខ្មែរផុសស.រ.អា.**

**នយោបាយក្នុងប្រទេស**



ហ្វ្រង់ស្វា ប៉ុងសូ

**តពីលេខមុន**

**សុខាភិបាល**

*៤៣%ក្នុងចំណោមស្ត្រី៧២០នាក់មានជម្ងឺខ្វះឈាមក្រហម Anemie ដែលគេមិនដឹងថាមកពីបុព្វហេតុអ្វីពិតប្រាកដ (CD du 13.06.16)

* ពន្ធនាគារនៅក្រុងព្រះសីហនុ នឹងខេត្តពោធិសត្វដែលប្រគល់ទៅឱ្យក្រុមហ៊ុនឯកជនកាន់កាប់នឹងត្រូវសង់នៅលើដីឯកជន(CD du 29.06.16)

*"កណ្ដុរយន្ត"ដែលបង្កើតដោយសាកលវិទ្យាល័យ"វីឡាណូវ៉ា"រដ្ឋផេនស៊ីវេនាសហរដ្ឋអា-មេរិកមានតម្លៃពី៥ម៉ឺនដល់២០ម៉ឺន, មានខ្លះនឹងត្រូវប្រើយកទៅដោះមីន(CD du 04.06.16)។ ថ្ងៃ១៨មិថុនា"វិរកណ្ដុរ"ទាំងនោះ បានរំដោះដីចំនួន៨ហិកតានៅខេត្តសៀមរាប (CD du 20.06.16)

*ជម្ងឺឆ្លង"អេដ" បានកើនឡើងជិត២ដង ក្នុងរយៈពេល១០ឆ្នាំកន្លងមកចំនួននោះមាន៨២.៩៧០នាក់។ ផ្ទុយទៅវិញជម្ងឺនេះបានថយចុះនៅវៀតណាម-ម៉ាឡេស៊ី នឹងថៃឡង់។ មានតែ៣០% ភាគរយប៉ុណ្ណោះ ដែលទទួលថ្នាំ"Antiretro-viral" (CD du 21.07.16)

**សិទ្ធមនុស្ស**

*ថ្ងៃទី៣១ឧសភា មានបញ្ហាយ៉ាងតឹងតែងពីនាយករដ្ឋមន្ត្រីចំពោះមជ្ឈមណ្ឌលកិច្ចការសង្គមនៅព្រៃស្ពឺ ឱ្យកែទម្រង់ ឬក៏ត្រូវបិទទ្វារ។ នៅក្នុងមជ្ឈមណ្ឌលនោះ គេប្រមូលឃុំឃាំងជនអនាថាស្ត្រីពេស្យា ឬអ្នកញៀនអាភៀន,... គេឱ្យដឹងថានៅទីនោះមានការវាយធ្វើបាប, ចាប់រំលោភ (CD du 01.06.16)

*"លីកាដូ"បានបង្ហាញចំនួនអ្នកទោសនយោបាយមាន២៩នាក់ សម្រាប់ឆ្នាំ២០១៥ ដែលរដ្ឋាភិបាលបានប្រកែកមិនយល់ស្រប។ ប្រទេសកម្ពុជាស្ថិតនៅលំដាប់ទី១០៤ក្នុងចំណោមប្រទេស១៦៣ដែលមានសន្តិភាព, កាលពីឆ្នាំមុននៅក្នុងលំដាប់ទី១១១ (CD du 09.06.16)។ ពេលជាមួយគ្នានោះ តំណាងអចិន្ត្រៃយ៍ខ្មែរប្រចាំអ.ស.ប. បានថ្លែងនៅ "ហ្សឺណែវ" កាលពីថ្ងៃទី១៧ មិថុនាថា ប្រទេសកម្ពុជា គឺជាប្រទេសដែល "លទ្ធិប្រជាធិបតេយ្យលាតសន្ធឹងនឹងមានជម្រៅ", ហើយថា"រដ្ឋាភិបាលខ្មែរចូលរួមដោយគ្មានសំចៃក្នុងតួនាទីនៃច្បាប់, នៃសិទ្ធិមនុស្ស នឹងលទ្ធិប្រជាធិបតេយ្យ..." ហើយថាទៀត "អង្គការក្រៅរដ្ឋាភិបាលចំនួន៤៦៣៧ នៅធ្វើការក្នុងប្រទេស ដោយគ្មានការគៀបសង្កត់"...ហើយថា"ការបោះឆ្នោតលើកទី៤ ដឹកនាំដោយប្រទេសរបស់ខ្លួន, ត្រូវបានទទួលយកបានពីគ្រប់គណបក្ស"(CD du 18.06.16)

*ថ្ងៃទី១៨មិថុនា, នាយទាហ៊ានវៀតណាម៧នាក់ បានមកដល់ភ្នំពេញ ដើម្បីពន្យល់ឱ្យពួក"ម៉ុងតាញ៉ា"ដែលទទួលបានការស្នាក់អាស្រ័យនៅស្រុកខ្មែរ ឱ្យត្រឡប់ទៅស្រុកកំណើតវិញ។ ឆ្នាំមុន ជនភៀសខ្លួន៣០នាក់ បានត្រឡប់ទៅវៀតណាមវិញ (CD du09.16.16)។ ថ្ងៃទី១២កក្កដា បន្ទាប់ពីបានសិទ្ធជាជនភៀសខ្លួន២ឆ្នាំហើយនៅស្រុកខ្មែរ ពួក"ម៉ុងតាញ៉ា"១៦នាក់ ក្នុងនោះមានស្ត្រី៣នាក់ នឹងកុមារ៣នាក់ បានត្រូវត្រឡប់យ៉ាងអស់សង្ឃឹមទៅវៀតណាមវិញ។ វាស្មានៃជន២០០នាក់ទៀត ដែលសុំសិទ្ធជ្រកកោននយោបាយនៅស្រុកខ្មែរដែរនោះ មិនទាន់ប្រាកដប្រជានៅឡើយទេ។

**សាសនា**

គេបានឱ្យដឹងពីករណីរំលោភផ្លូវភេទជាច្រើនដោយព្រះសង្ឃ, មានម្នាក់ "ឆឹកពង" ហើយថតវីដេអូផ្សាយក្នុង"ហ្វេសប៊ុក", ម្នាក់ទៀតប្រើគ្រឿងញៀន (CD du 16.06.16)

**ផ្សេងៗ**

*រដ្ឋាភិបាលខ្មែរបានបង្កើតទិដ្ឋាការថ្មីមួយទៀត(ER)សម្រាប់អនកដែលបានចូលនិវត្តន៏ហើយចង់មករស់នៅស្រុកខ្មែរវិញ។

*ស៊ីដនីយ ឆាន់លី អ្នកនិពន្ធសៀវភៅ, សម្រាប់សម្ដែងក្នុងភាពយន្ត"La Dechirure" បានទទួលមរណភាពនៅញូយ៉ក កាលពីថ្ងៃ៩កក្កដា, ក្នុងអាយុ៨២ឆ្នាំ (CD du 11.07.16)

*សហព័ន្ធនៃក្រុមអ្នកទេសចរបានជ្រើសយកកម្ពុជាជាគោលដៅដ៏ល្អបំផុតប្រចាំឆ្នាំៈ សោភណ្ឌភាព នឹងសុវត្ថិភាព(CD du 16.06.16)។


យើងខ្ញុំយកចិត្តទុកដាក់ដើម្បីឲ្យលោកអ្នកញញឹម។
លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់!





លោកអ្នកទទួលបានអត្ថប្រយោជន៍ទាំងអស់របស់លោកអ្នកនៅក្នុងកម្មវិធីស្តង់ដារ MassHealth និងកម្មវិធី Medicare រួមទាំងសេវាកម្មជាច្រើនទៀត។

- លោកអ្នកទទួលបានសេវាកម្មទន្តពេទ្យដោយមិនបង់ប្រាក់ ដែលរួមមាន៖*
  - ពិគ្រោះយោបល់នៅការិយាល័យ និងសម្អាតធ្មេញ
  - ដាក់ក្រាសធ្មេញទាំងមូលនិងដោយផ្នែក
  - ប៉ះធ្មេញ
  - ដាំធ្មេញ
- ចំណាយបដិភាគ $0 សម្រាប់គ្រប់សេវាកម្ម
- ប័ណ្ណ លោកអ្នកមានសុខភាពល្អ សម្រាប់ទិញទំនិញពាក់ព័ន្ធនឹងសុខភាពដែលមិនមានវេជ្ជបញ្ជា (រហូតដល់ $140ក្នុងមួយឆ្នាំ / $35 ក្នុងមួយត្រីមាស)*
- សេវាកម្មដឹកសមាជិកទៅកាន់និងមកពីកន្លែងណាត់ជួប*
- អាចហៅទូរស័ព្ទទៅកាន់សមាជិកក្រុមការងារនៃគម្រោង SWH បាន 24/7

SWH
SENIOR WHOLE HEALTH®
Simple. Secure. Independent.

សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅ:
1-888-566-3526(ខ្សែទូរស័ព្ទឥតគិតថ្លៃ) TTY/TDD:711
www.seniorwholehealth.com/SNP
យើងខ្ញុំបើកដំណើរការចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 8 យប់ ប្រាំពីរ (7) ថ្ងៃក្នុងមួយសប្តាហ៍។

ប្រសិនបើលោកអ្នកមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធីស្តង់ដារ MassHealth ក៏ប៉ុន្តែមិនមានសេវាកម្មធានារ៉ាប់រងក្នុងកម្មវិធី Medicare ផ្នែក A និង/ឬក៏ផ្នែក B លោកអ្នកប្រហែលជា អាចចុះឈ្មោះនៅក្នុងកម្មវិធីជម្រើសថែទាំសុខភាពមនុស្សចាស់ MassHealth Senior Care Options (SCO) របស់យើងខ្ញុំបាន។
លោកអ្នកដែលឆ្លើយតបទៅនឹងលក្ខខណ្ឌខាងលើអាចចុះឈ្មោះបានគ្រប់ពេលវេលារៀងរាល់ឆ្នាំ។

* លក្ខខណ្ឌកំណត់អាចត្រូវបានអនុវត្ត

គម្រោងសុខភាពទាំងមូលរបស់មនុស្សចាស់ គឺជាគម្រោងថែទាំសុខភាព HMO SNP ដែលមានការសម្របសម្រួល និងកិច្ចសន្យាផ្តល់- ទទួលសេវាកម្មនៃកម្មវិធី Medicare និងកិច្ចសន្យាជាមួយ Commonwealth of Massachusetts/កម្មវិធី EOHHS MassHealth។ ការចុះឈ្មោះធ្វើឡើងដោយស្ម័គ្រចិត្ត និងអាស្រ័យទៅលើការបន្តកិច្ចសន្យាប្រចាំឆ្នាំ។ ព័ត៌មានអំពីអត្ថប្រយោជន៍នៅក្នុងឯកសារនេះ គឺជាសេចក្តីសង្ខេបមួយ មិនមែនជាសេចក្តីពិពណ៌នាលម្អិតអំពីអត្ថប្រយោជន៍ទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យគម្រោង។ លក្ខខណ្ឌកំណត់ ប្រាក់បដិភាគ ឬក៏លក្ខខណ្ឌកម្រិតផ្សេងៗទៀតអាចត្រូវបានអនុវត្ត។អត្ថប្រយោជន៍ រូបមន្ត បណ្តាញអ្នកផ្តល់សេវាកម្ម និងបណ្តាញឱសថស្ថាន អាចត្រូវបានផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករា នៃឆ្នាំនីមួយៗ។ លោកអ្នកត្រូវតែបន្តបង់បុព្វលាភផ្នែក B របស់លោកអ្នក ប្រសិនបើបុព្វលាភនោះមិនកំពុងត្រូវបានបង់ដោយភាគីណាមួយផ្សេងទៀតនៅឡើយទេ។ គម្រោងនេះត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានជំនួយវេជ្ជសាស្ត្រដែលទទួលបានទាំងពីរដ្ឋ និងកម្មវិធី Medicare។
H2224_2015_104kh Accepted 12/7/2014

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ការចាប់ខ្លួនទាក់ទងនឹងបណ្តាញព័ត៌មានសង្គមរារាំងសេរីភាពអ៊ីនធឺណិត

**ដោយខូលីន ម៉ីយន៍ | ថ្ងៃពុធ ទី១៦ខែវិច្ឆិកា ឆ្នាំ២០១៦**

របាយការណ៍ថ្មីមួយនិយាយថា សេរីភាពអ៊ីនធឺណិតបានធ្លាក់ចុះនៅប្រទេសកម្ពុជាកាលពីឆ្នាំកន្លងទៅដោយសារតែមានការចាប់ខ្លួនទាក់ទងនឹងការបង្ហោះសារតាមបណ្តាញព័ត៌មានសង្គម និងច្បាប់ស្តីពីទូរគមនាគមន៍ថ្មីដែលផ្តល់ការគ្រប់គ្រងដ៏ទូលំទូលាយរបស់រដ្ឋាភិបាលលើទូរស័ព្ទចល័ត និងក្រុមហ៊ុនអ៊ីនធឺណិត។

ការទទួលបានអ៊ីនធឺណិតបានលូតលាស់យ៉ាងឆាប់រហ័សក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ភាគច្រើនដោយសារតែមានស្មាតហ្វូនច្រើន ជានិន្នាការដែលបន្ធូរបន្ថយការក្តោបក្តាប់ព័ត៌មានរបស់គណបក្សប្រជាជនកម្ពុជាកាន់អំណាច ហើយធ្វើឱ្យប្រជាជនភាគច្រើនពឹងផ្អែកតិចតួចលើបណ្តាញព័ត៌មានប្រពៃណី។

អង្គការផ្ទះសេរីភាពមានមូលដ្ឋាននៅសហរដ្ឋអាមេរិកនិយាយក្នុងរបាយការណ៍ថ្មីរបស់ខ្លួនដែលមានចំណងជើងថា "បំបិទមាត់អ្នកនាំសារៈ អែពស៍ប្រាស្រ័យទាក់ទងការគំរាមកំហែង"ថា ប៉ុន្តែរដ្ឋាភិបាលបានចាត់វិធានការកាលពីឆ្នាំកន្លងទៅដើម្បីគ្រប់គ្រងកាន់តែខ្លាំងលើវិបសាយដោយបណ្តាលឱ្យធ្លាក់ចុះយ៉ាងគំហុកនូវសេរីភាពអ៊ិនធឺណិត។

របាយការណ៍ផ្តល់ពិន្ទុដល់កម្ពុជាចំនួន៥២ក្នុងបណ្តា១០០ពិន្ទុ ហើយចាត់ទុកថា "មានសេរីភាពខ្លះ" ដោយដាក់ឱ្យប្រទេសនេះនៅមុខប្រទេសវៀតណាម ដែលមានសេរីភាពអ៊ីនធឺណិតតិចតួចបំផុតនៅក្នុងអាស៊ីអាគ្នេយ៍ ហើយនៅពីក្រោយប្រទេសហ្វីលីពីន ដែលមានអ៊ិនធឺណិតបើកចំហបំផុតនៅក្នុងតំបន់។

របាយការណ៍និយាយថា "កម្ពុជាបានអនុម័តច្បាប់ស្តីពីទូរគមនាគមន៍ទូលំទូលាយពេកដែលធ្វើឱ្យឧស្សាហកម្មនេះស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ដោយធ្វើឱ្យខូចប្រយោជន៍ដល់ក្រុមហ៊ុនផ្គត់ផ្គង់សេវានិងសិទ្ធិឯកជនរបស់អ្នកប្រើប្រាស់។ ដោយឡែកនគរបាលកម្ពុជាបានចាប់ខ្លួនមនុស្សបីបួននាក់ ដោយសារតែពួកគេបង្ហោះសារតាមហ្វេសប៊ុក រួមមានការបង្ហោះមួយទាក់ទងនឹងជម្លោះព្រំដែនជាមួយវៀតណាម"។

លោក អ៊ុំ សំអាន តំណាងរាស្ត្របក្សប្រឆាំងដែលត្រូវគេចាប់ខ្លួនកាលពីខែមេសា ដោយសារតែបង្ហោះសារហ្វេសប៊ុករិះគន់ការងារព្រំដែនរបស់រដ្ឋាភិបាល គឺស្ថិតក្នុងចំណោមជនកម្ពុជាកាន់តែច្រើននាក់ដែលត្រូវជាប់ពន្ធនាគារ ដោយសារតែបង្ហោះសារតាមហ្វេសប៊ុកដែលចាត់ទុកថាជាបទល្មើសដោយរដ្ឋាភិបាល។

លោក អ៊ុក គីមសេង អនុរដ្ឋលេខាធិការក្រសួងព័ត៌មានបាននិយាយថា សារបង្ហោះតាមហ្វេសប៊ុកទាំងនោះតាមពិតជាបទល្មើស ហើយថា ក្រុមអង្គការក្រៅរដ្ឋាភិបាលនឹងមានប្រយោជន៍កាន់តែខ្លាំង ប្រសិនបើពួកគេជួយអប់រំពលរដ្ឋអំពីការប្រើប្រាស់អ៊ិនធឺណិតប្រកបដោយការទទួលខុសត្រូវ។

លោកបាននិយាយថា "ខ្ញុំមិនគិតថា គ្រាន់តែដោយសារតែមានមនុស្សពីរបីនាក់ត្រូវចាប់ខ្លួន... សេរីភាពត្រូវរឹតត្បិតនោះទេ។ វាមិនពិតទេ"។ លោកបាននិយាយបន្ថែមថា ការទទួលបានអ៊ិនធឺណិតកាន់តែច្រើននិងការមិនមានការពិនិត្យចាប់ពិរុទ្ធបង្ហាញឱ្យឃើញនូវការប្តេជ្ញារបស់រដ្ឋាភិបាលក្នុងសេរីភាពអ៊ិនធឺណិត។

លោកបាននិយាយថា "មិនមាននិយតកម្មឬការរឹតត្បិតទៅលើអ្នកប្រើប្រាស់អ៊ីនធឺណិតទេ។ គេអាចបើកនៅកន្លែងណាក៏បានដែរ"៕

# SOCIAL MEDIA ARRESTS STUNT WEB FREEDOM

**byColin Meyn | November 16, 2016**

Internet freedom has diminished in Cambodia over the past year due to arrests over social media posts and a new telecoms law that gives the government broad control over mobile phone and internet providers, a new report says.

Internet access has expanded rapidly in recent years, thanks largely to the spread of smartphones, a trend that has loosened the ruling CPP's grip on information and made much of the population less reliant on traditional media outlets.

But the government has taken steps over the past year to exert more control over the web, causing a steep decline in internet freedom, U.S.-based think tank Freedom House says in its new report "Silencing the Messenger: Communication Apps under Pressure."

The report gives Cambodia a score of 52 out of 100 and the label of "partly free," placing it well ahead of Vietnam, which has the least free internet in Southeast Asia, and well behind the Philippines, which has the most open internet in the region.

"Cambodia passed an overly broad telecommunications law that put the industry under government control, to the detriment of service providers and user privacy," the report says. "Separately, Cambodian police arrested several people for their Facebook posts, including one about a border dispute with Vietnam."

Opposition lawmaker Um Sam An, arrested in April over posts critical of the government's border work, is among an increasing number of Cambodians finding themselves behind bars for Facebook posts deemed criminal by the government.

OukKimseng, an undersecretary of state at the Information Ministry, said the posts were in fact criminal and that non-government groups would be far more helpful if they helped educate people about responsible internet use.

"I don't think just because a few people are arrested…freedom is being restricted. That is not true," he said, adding that expanding Internet access and the lack of state censorship showed the government's commitment to internet freedom.

"There are no regulations or restrictions on people using the internet," he said. "They can surf anywhere."

តមកពីទំព័រទី ១០ បោះឆ្នោតសាកលឆ្នាំ២០១៦...

-បន្ថែមពីនោះ នៅមានសហជីពគ្រូបង្រៀនដ៏សំខាន់មួយដែលមិនចង់ឃើញសាលា"ឆាទ័រស្គូល"រីកចំរើន គេបោះឆ្នោតឱ្យ "រ៉ាឌី ដែល"ប្រឆាំងនឹងឆាទ័រស្គូល"។ នៅមានចរន្តមួយទៀតដែលរួមគណបក្សធំទាំង២បាន គឺអ្នកដែលមិនស្គាល់សហគមន៍ខ្មែរច្បាស់លាស់,ខ្លាចសហគមន៍ខ្មែររួមគ្នាបានដោយសារតែរឿងនយោបាយស្រុកខ្មែរ, មានកម្លាំងច្រើនហើយឯករាជ្យតែខ្លួនឯង, អ្នកទាំងនោះគេបោះឆ្នោតឱ្យ "រ៉ាឌី ម៉ម ពីព្រោះមានមិត្តភ័ក្តច្រើនក្នុងចំណោមក្រុមស្បែកសដែលមិនចង់ឮរឿងស្រុកខ្មែរ។ លទ្ធផលគឺនៅសង្កាត់លេខ១៨មានអ្នកចុះឈ្មោះបោះឆ្នោតជាង១,២ម៉ឺននាក់ អ្នកចេញទៅបោះឆ្នោត បាន៥៣% (ធម្មតាបានតែ២០-៣០%ប៉ុណ្ណោះ) គេបានបោះឱ្យតំណាងរដ្ឋ "រ៉ាឌី ម៉ម ជិត៨ពាន់នាក់, បោះឱ្យ ខេមរា កៃ ជាង៣ពាន់នាក់។ រហូតមកដល់ថ្ងៃបោះឆ្នោតទៅហើយក្តីសហគមន៍ខ្មែររាប់ទាំង"ខ្មែរផុសស.រ.អា." ផង នៅតែជឿនៅឡើយថា ខេមរា កៃ អាចមានសង្ឃឹមនៅឡើយ ដោយខាងសហគមន៍ខ្មែរមានការគាំទ្រច្រើនពេក, តែលទ្ធផលបញ្ជាក់ផ្សេងទៅវិញ ការបោះឆ្នោតលើកនេះ"ចរន្តផុស"ខុសធម្មតាបានកើតគ្រប់កន្លែង។

សហគមន៍ខ្មែរនៅតែគេថា"ចេះតែបែកបាក់គ្នា"ដដែលដោយមានខ្មែរ២នាក់ឈរឈ្មោះប្រជែងគ្នាលើដំណែងតែមួយ។ នៅឡូវែលអ្នកជាប់នឹងអ្នកធ្លាក់ឆ្នោតទាំង២នាក់ មិនទាន់រករូបមន្តសម្រាប់បង្ហាញថា "មានការជានាគ្នាក្នុងសហគមន៍"នៅឡើយទេ, ម្ចាស់ឆ្នោតចង់ឃើញថា ក្នុងតួនាទីបង្រួបបង្រួមសហគមន៍ខ្មែរនោះ អ្នកទាំងពីរឡូវនេះដើរតួរជាអ្នកតំណាងក្រុមអ្នកឈ្នះនឹងអ្នកចាញ់បានហើយ តើមានគម្រោងយ៉ាងណាដែរដើម្បីកសាងសង្គមជាដើមកំណើតរបស់ខ្លួននោះ?



ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីឯកសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# ល្បឿននៃការចុះឈ្មោះបោះឆ្នោតធ្លាក់ចុះ ខណៈនៅសល់ពេលត្រឹមតែ១២ថ្ងៃទៀតប៉ុណ្ណោះ

**ដោយ គុច ណារ៉េន | ថ្ងៃព្រហស្បតិ៍ ទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦**

អ្នកនាំពាក្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) បានលើកឡើងកាលពីម្សិលមិញថា ក្រុមមន្ត្រីរៀបចំការបោះឆ្នោតបានធ្វើដំណើរទូទាំងប្រទេសអំឡុងពិធីបុណ្យអុំទូកក្នុងសប្តាហ៍នេះដើម្បីស៊ើបអង្កេតល្បឿននៃការចុះឈ្មោះបោះឆ្នោតដែលបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងពេលថ្មីៗ ប៉ុន្តែរកមិនឃើញបញ្ហាជាក់ស្តែងនោះឡើយ។

លោក ហង្ស ពុទ្ធា អ្នកនាំពាក្យគណៈកម្មាធិការនេះដែលបានចុះទៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាមបានមានប្រសាសន៍ថា "គ.ជ.ប. នឹងមិនពន្យារពេលកំណត់សម្រាប់ការចុះឈ្មោះនោះឡើយ។ ស្ទើរទាំងអស់នៃឃុំ-សង្កាត់ទាំងនេះ អ្នកភូមិមូលដ្ឋានភាគច្រើនបានចុះឈ្មោះរួចហើយ"។ ក្នុងចំណោមមន្ត្រីដែលបានចុះទៅតាមបណ្តាខេត្តទាំង២៥នៅទូទាំងប្រទេសមិនមាននរណារាយការណ៍អំពីបញ្ហាជាក់ស្តែងណាយមួយឡើយ។

ទាំងខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាមសុទ្ធតែមានសភាពយឺតយ៉ាវនៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ពោលគឺចំនួននៃអ្នកដែលបានចុះឈ្មោះរួចហើយនៅទ្រឹងត្រឹម៧០,១ភាគរយ និង៧០,៥ភាគរយ ដោយសុទ្ធតែធ្លាក់ចុះទាបជាងការចុះឈ្មោះបោះឆ្នោតជាមធ្យមទូទាំងប្រទេសដែលមានចំនួន៧៤.៤ភាគរយ។

នៅទូទាំងប្រទេស បន្ទាប់ពីមានភាពសកម្មនៅក្នុងរយៈពេលពីរខែដំបូង ការចុះឈ្មោះបោះឆ្នោតបានថយចុះគួរឱ្យកត់សម្គាល់នៅក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ ពីជាង១០០.០០០នាក់ក្នុងមួយថ្ងៃអំឡុង៤០ថ្ងៃដំបូង ចាប់តាំងពីពេលចុះឈ្មោះបោះឆ្នោតចាប់ផ្តើមនៅក្នុងខែកញ្ញា មកនៅត្រឹមតែប្រហែល៣០.០០០ នាក់កាលពីសប្តាហ៍មុន។

លោក ហង្ស ពុទ្ធា បានលើកឡើងទៀតថា អំឡុងពិធីបុណ្យអុំទូកក្នុងសប្តាហ៍នេះការចុះឈ្មោះមានសភាពកើនឡើងបន្តិច ពោលគឺមានការចុះឈ្មោះប្រហែល៥០.០០០នាក់ក្នុងមួយថ្ងៃនៅទូទាំងប្រទេស។

លោកបានថ្លែងថា "ថ្មីៗនេះមានការធ្លាក់ចុះយ៉ាងខ្លាំង ហើយថ្ងៃខ្លះមានអ្នកមកចុះឈ្មោះបោះឆ្នោតមិនដល់៣០.០០០នាក់ផង។ ប៉ុន្តែអំឡុងពិធីបុណ្យអុំទូករយៈពេលបីថ្ងៃនេះ កម្មករកាត់ដេរជាច្រើនបានត្រឡប់ទៅស្រុកកំណើត ហើយពួកគេបានចុះឈ្មោះនៅទីនោះតែម្តង"។

ទោះបីជាល្បឿននៃការចុះឈ្មោះអំឡុងពិធីបុណ្យនៅតែមានភាពសកម្មក៏ដោយ ក៏ការចុះឈ្មោះសរុបនឹងមិនឈានដល់៨០ភាគរយនោះឡើយ នៅត្រឹមថ្ងៃថ្ងៃទី២៩ខែវិច្ឆិកា ដែលជាថ្ងៃចុះឈ្មោះចុងក្រោយ។

ទោះជាយ៉ាងណាលោក ហង្ស ពុទ្ធា បានលើកឡើងថា លោកពេញចិត្តចំពោះការចុះឈ្មោះសរុបក្នុងពេលបច្ចុប្បន្ន។ អ្នកដែលនៅមិនទាន់បានចុះឈ្មោះជាច្រើនទៀតទំនងជាសុទ្ធតែធ្វើការនៅក្រៅប្រទេស។

លោកបានថ្លែងថា "យើងមិនសង្ឃឹមថានឹងអាចចុះឈ្មោះបាន១០០ភាគរយនោះឡើយ ប៉ុន្តែយ៉ាងហោចណាស់យើងមានអ្នកដែលបានចុះឈ្មោះបោះឆ្នោតជាង៧៤ភាគរយនៅទូទាំងប្រទេសដែរ"។

ខេត្តចំនួនពីរដែលមានសភាពយឺតយ៉ាវជាងគេនៅក្នុងដំណើរការចុះឈ្មោះបោះឆ្នោត គឺខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យដែលសុទ្ធតែមានព្រំដែនជាប់ប្រទេសថៃជាប្រទេសដែលពលករចំណាកស្រុកខ្មែរជាង១លាននាក់បានទៅធ្វើការនៅទីនោះ នេះបើយោងតាមការប៉ាន់ប្រមាណមួយចំនួន។ អ្នកដែលបានចុះឈ្មោះបោះឆ្នោតក្នុងខេត្តទាំងពីរនេះ មានតែ៦៣,៣ភាគរយប៉ុណ្ណោះ។

ទោះបីជាមានសំណើពីគណបក្សសង្គ្រោះជាតិឱ្យបង្កើតកន្លែងចុះឈ្មោះពិសេសនៅតាមបណ្តោយព្រំដែន ឬមធ្យោបាយផ្សេងដើម្បីបោះឆ្នោត

**តទៅទំព័រទី១៧**

# VOTER REGISTRATION LAGS WITH 12 DAYS REMAINING

**byKuchNaren | November 17, 2016**

Election officials toured the country during this week's Water Festival holiday to investigate a recent sharp drop-off in the pace of voter registrations, but no glaring issues were found, a National Election Committee (NEC) spokesman said on Wednesday.

"The NEC will not extend the deadline for registrations," said Hang Puthea, a spokesman for the committee who visited the provinces of TbongKhmum and Kompong Cham. "Most local residents in almost all of these communes have already registered."




None of the delegations to the country's 25 provinces reported any obvious problems, he said.

Both TbongKhmum and Kompong Cham are relative laggards in registrations, stuck at 70.1 and 70.5 percent of eligible voters registered, respectively, both falling below the national average of 74.4 percent.

Nationwide, after a brisk first two months, registrations have slowed significantly in recent weeks, from more than 100,000 a day during the first 40 days since the start of registration in September to about 30,000 last week.

This week's Water Festival holiday caused a slight uptick in registrations, Mr. Puthea said, to about 50,000 registrations a day across the country.

"It was a very bad decline lately, and some days there were less than 30,000 voters registered," he said. "But during the three days of the Water Festival, many garment workers returned to their home provinces and they registered there."

Even if the holiday pace was maintained, total registrations would not reach 80 percent by the November 29 deadline.

Mr. Puthea, nevertheless, said he was satisfied with current totals. The bulk of the remaining unregistered voters were likely working abroad, he said.

"We don't believe that we will be able to register 100 percent, but we at least have more than 74 percent of voters registered across the country," he said.

The two slowest provinces for registrations are Battambang and BanteayMeanchey, both along the border with Thailand, which hosts more than 1 million Cambodian migrant workers according to some estimates. Just 63.3 percent of voters have been registered in both provinces.

Workers abroad cannot register or vote unless they return to their home communes, despite requests by the CNRP to have special registration centers set up along the border or other channels to cast ballots from abroad.

George Edgar, the ambassador in Cambodia for the E.U., which together with Japan has funded the new computerized voter registration system, said he was confident that any issues were being dealt with appropriately.

"We have followed the voter registration process closely, and congratulate the National Election Committee on their work so far," he said in an email.

(Additional reporting by Michael Dickison)

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# មន្ត្រីព្រមានអ្នកតវ៉ាថា សាលារាជធានីឃ្លាំមើលសកម្មភាពតវ៉ារបស់ពួកគេគ្រប់ពេលវេលា

ដោយ សេក ឧត្តម ។ ថ្ងៃអង្គារ ទី១ ខែវិច្ឆិកា ឆ្នាំ២០១៦

បើទោះជាអ្នកតវ៉ាយុទ្ធនាការ "ថ្ងៃច័ន្ទពណ៌ខ្មៅ" មួយក្រុមតូចមិនត្រូវបានរំខានអំឡុងការតវ៉ារយៈពេលខ្លីនៅក្នុងតំបន់របស់ពួកគេកាលពីម្សិលមិញក៏ដោយ ក៏អភិបាលរងរាជធានីបានព្រមានថា អាជ្ញាធរនៅតែឃ្លាំមើលពួកគេជានិច្ចដើម្បីប្រមូលភស្តុតាងដែលអាចប្រើនៅពេលក្រោយនៅក្នុងតុលាការ ។

យុទ្ធនាការដែលបានឈានចូលដល់សប្តាហ៍ទី២៦ហើយនេះ ត្រូវបានធ្វើឡើងជាការតបតទៅនឹងការចាប់ខ្លួនមន្ត្រីបួនរូបមកពីសមាគមសិទ្ធិមនុស្សអាដហុក និងមន្ត្រីរៀបចំការបោះឆ្នោតមួយរូប ដែលធ្លាប់បម្រើការនៅអង្គការមិនមែនរដ្ឋាភិបាល ។ ចាប់តាំងពីពេលនោះមកយុទ្ធនាការនេះបានភ្ជាប់បញ្ហាផ្សេងៗទៀត រួមទាំងការអំពាវនាវឱ្យមានការស៊ើបអង្កេតពេញលេញលើការធ្វើឃាតលោក កែម ឡី អ្នកវិភាគនយោបាយ និងការទាមទារឱ្យដោះលែងអ្នកស្រី ទេព វន្នី សកម្មជនសិទ្ធិដីធ្លីជាដើម ។

បន្ទាប់ពីសកម្មជនប្រហែល៣០នាក់បានប្រមូលផ្តុំគ្នានៅតំបន់បឹងកក់ដែលញាំញីដោយការបណ្តេញចេញនៅម៉ោងប្រហែល៩ព្រឹកថ្ងៃម្សិលមិញសម្រាប់ការតវ៉ាថ្មីបំផុតនោះ លោក ឃួង ស្រេង អភិបាលរងរាជធានីបានមានប្រសាសន៍ថា អាជ្ញាធរបានឃ្លាំមើលការតវ៉ានេះ ។

លោកបានមានប្រសាសន៍ថា "យើងមិនមែនព្រះរាជអាជ្ញាទេ ដូច្នេះយើងមិនអាចដឹងថា តើពួកគេបានប្រព្រឹត្តបទល្មើសឬក៏អត់ឡើយ មានតែព្រះរាជអាជ្ញាប៉ុណ្ណោះ ។ ប៉ុន្តែរាល់ថ្ងៃយើងបានកត់ត្រាអំពីសកម្មភាពរបស់ពួកគេ" ។

កាលពីមុន មន្ត្រីរដ្ឋាភិបាលបានលើកឡើងថា សកម្មភាពនៃការចូលរួមក្នុងការតវ៉ាយុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅគឺជាបទឧក្រិដ្ឋ ដោយចាត់ទុកយុទ្ធនាការនេះជា "ការបះបោរក្នុងទីក្រុង" និង "បដិវត្តន៍ពណ៌" ។

អ្នកស្រី បូវ សុភា សកម្មជនម្នាក់ដែលត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល៦ថ្ងៃពីបទ "ជេរប្រមាថ" ក្រុមមន្ត្រីអំឡុងពិធីដាក់បណ្តាសានៅការតវ៉ានៃយុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅកាលពីខែសីហាបាននិយាយថា អាជ្ញាធរគួរស្វែងរកឧក្រិដ្ឋជនពិត ។

អ្នកស្រីបាននិយាយថា "តើការងាររបស់សាលារាជធានីចាំតែកត់ត្រាសកម្មភាពរបស់ពួកយើងឬ? ពួកគេគួរតែទៅកត់ត្រាការចែកចាយគ្រឿងញៀន ឬការបាញ់បោះអនាធិបតេយ្យវិញប្រសើរជាង" ។

សកម្មជនជាច្រើននាក់មានវត្តមាននៅតាមទីតាំងនានាសម្រាប់ការតវ៉ានៃយុទ្ធនាការថ្ងៃច័ន្ទពណ៌ខ្មៅលើកដំបូងកាលពីថ្ងៃទី៩ ខែឧសភា ដែលបណ្តាលឱ្យមានការចាប់ខ្លួនមនុស្សប្រាំបីនាក់ ។ ការចាប់ខ្លួនបន្ថែមទៀតក្នុងសប្តាហ៍ជាបន្តបន្ទាប់ឃើញថា បានថយចុះ ខណៈក្រុមដែលបានធ្វើយុទ្ធនាការបានដកថយ ។ សប្តាហ៍ខ្លះមិនមានការតវ៉ាជាសាធារណៈទេ ។

លោក ចាន់ ពុទ្ធិស័ក្តិ សកម្មជនមួយរូបទៀតនៅតំបន់បឹងកក់បាននិយាយថា អ្នកដឹកនាំការតវ៉ាមានជម្រើសតិចតួចប៉ុណ្ណោះ ក្រៅតែពីធ្វើយុទ្ធនាការនៅជិតផ្ទះរបស់ខ្លួន ។ លោកបាននិយាយថា "អ្នកភូមិមួយចំនួនខ្លាចអាជ្ញាធរ ។ ដូច្នេះហើយយើងបានសម្រេចធ្វើការតវ៉ានៅក្នុងសហគមន៍" ៕ **សារុន**

## តមកទំព័រទី ១៦ ល្បឿននៃការចុះឈ្មោះបោះឆ្នោត...

ពីក្រៅប្រទេសក៏ដោយក្តីតែពលករដែលធ្វើការនៅក្រៅប្រទេសមិនអាចចុះឈ្មោះ ឬបោះឆ្នោតបានឡើយ លុះត្រាតែត្រឡប់មកស្រុកកំណើតរបស់ពួកគេវិញ ។

លោក ចច អេដហ្គា (George Edgar) ឯកអគ្គរដ្ឋទូតប្រចាំប្រទេសកម្ពុជារបស់សហភាពអឺរ៉ុបដែលបានសហការជាមួយប្រទេសជប៉ុននៅក្នុងការផ្តល់មូលនិធិសម្រាប់ប្រព័ន្ធចុះឈ្មោះបោះឆ្នោតថ្មីតាមប្រព័ន្ធកុំព្យូទ័របានលើកឡើងថា លោកមានទំនុកចិត្តថា បញ្ហានីមួយៗនឹងត្រូវបានដោះស្រាយប្រកបដោយភាពត្រឹមត្រូវ ។

លោកបានលើកឡើងតាមរយៈអ៊ីម៉េលថា "យើងបានតាមដានដំណើរការចុះឈ្មោះបោះឆ្នោតយ៉ាងយកចិត្តទុកដាក់ ហើយសូមអបអរសាទរដល់ការងាររបស់គណៈកម្មាធិការរៀបចំការបោះឆ្នោតរហូតមកទល់ពេលនេះ" ៕

ស៊ុយ ឈាង(រាយការណ៍បន្ថែមដោយ Michael Dickison)

# GOVERNMENT IS WATCHING YOU, OFFICIAL TELLS PROTESTERS

**by Sek Odom | November 1, 2016**

Though a small group of "Black Monday" protesters went undisturbed during a brief protest in their neighborhood on Monday, Phnom Penh's deputy governor warned that authorities were still monitoring them in order to compile evidence that could later be used in court.

The campaign, which limped into its 26th week, was launched in reaction to the arrest of four officers from rights group Adhoc and an election official who previously worked at the NGO.



BovSophea, center, speaks into a bullhorn during the latest 'Black Monday' protest in Phnom Penh's BoengKak community on Monday. (SivChanna/The Cambodia Daily)

It has since dovetailed with other issues, including calls for a full investigation into the murder of political analyst Kem Ley and the release of land rights activist TepVanny.

After about 30 activists gathered in the eviction-hit BoengKak neighborhood at about 9 a.m. on Monday for the latest demonstration, deputy municipal governor KhuongSreng said authorities were monitoring the protest.

"We are not the prosecutors, so we can't find out if they have committed a crime or not-that's the prosecutor," he said. "However, every day we are keeping record of their activities."

Government officials have previously said that taking part in a Black Monday protest was a crime in itself, equating the campaign to an "urban rebellion" and "color revolution."

BovSophea, an activist who was sentenced to six days in prison for "insulting" officials during a cursing ceremony at a Black Monday protest in August, said authorities should be looking for real criminals.

"What is it in City Hall's job that means they need to record our activities? They should go to record drug dealings or anarchic shootings," Ms. Sophea said.

Dozens of activists turned out in various locations for the first Black Monday protest on May 9, leading to eight arrests. More arrests in ensuing weeks saw the number dwindle as the groups that launched the campaign backed away. Some weeks there have been no public protests.

Chan Puthisak, another BoengKak activist, said protest leaders were left with little choice but to keep the campaign close to home.

"Some residents are scared of the authorities," he said. "So we decided to hold it in the community."

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# លោក កឹម សុខា: ប្រជាពលរដ្ឋជាអ្នកការពារព្រំដែនមិនមែនកំផែងទេ?

**ដោយ ឃួន ណារិម | ថ្ងៃច័ន្ទ ទី២១ខែវិច្ឆិកា ឆ្នាំ២០១៦**

ដោយលើកឡើងពីការសន្យារបស់លោក ដូណាល់ ត្រាំ ប្រធានាធិបតីអាមេរិកទើបជាប់ឆ្នោតថា នឹងសាងសង់កំផែងនៅតាមព្រំដែនជាមួយប្រទេសម៉ិកស៊ិកនោះ លោក កឹម សុខា អនុប្រធានគណបក្សប្រឆាំងមានប្រសាសន៍ថា ប្រទេសកម្ពុជាមិនអាចមានប្រាក់សាងសង់ហេដ្ឋារចនាសម្ព័ន្ធបែបនោះទេ ប៉ុន្តែនៅតែផ្តោតលើការការពារព្រំដែនជាមួយវៀតណាមដដែល។

លោក កឹម សុខា បានថ្លែងកាលពីម្សិលមិញទៅកាន់សកម្មជនយុវជនរាប់រយនាក់នៅទីស្នាក់ការកណ្តាលគណបក្សសង្គ្រោះជាតិក្នុងរាជធានីភ្នំពេញ?កន្លែងដែលលោកបានប្រាប់ពួកគេឱ្យផ្តោតទៅលើការធ្វើយុទ្ធនាការរបស់ខ្លួនសម្រាប់ការបោះឆ្នោតនៅពេលខាងមុខអំពីផែនការរបស់គណបក្សសង្គ្រោះជាតិដើម្បីពង្រឹងការការពារនៅតាមព្រំដែន។ គណបក្សសង្គ្រោះជាតិបានធ្វើយុទ្ធនាការប្រឆាំងការធ្វើអន្តោប្រវេសន៍ខុសច្បាប់របស់ជនជាតិវៀតណាម?និងការលុកលុយរបស់វៀតណាមចូលក្នុងប្រទេសកម្ពុជាជាយូរមកហើយ។

លោក កឹម សុខា បានមានប្រសាសន៍ថា "យើងត្រូវអភិវឌ្ឍព្រំដែនដោយការឱ្យមានប្រជាជនច្រើនរស់នៅតាមព្រំដែន។ ទី១សាងសង់ផ្លូវនៅតាមព្រំដែន។ទី២ ផ្សារវត្តអារាមការងាររោងចក្រនិងការធ្វើកសិកម្ម"។

ប្រធានស្តីទីគណបក្សសង្គ្រោះជាតិរូបនេះបានមានប្រសាសន៍ថា យុទ្ធនាការមុនៗរបស់គណបក្សប្រឆាំងដែលរិះគន់កិច្ចការរបស់រដ្ឋាភិបាលដែលនិយាយការពារព្រំដែនដោយផ្តោតលើការបន្តលុកលុយរបស់វៀតណាមនោះ មិនបានផ្តល់ដំណោះស្រាយក្នុងន័យស្ថាបនាឡើយ។

លោកបានថ្លែងថា "យើងបានវាយប្រហារពួកគេ ប៉ុន្តែយើងមិនមានអនុសាសន៍ថ្មីទេ ដូច្នេះយើងមិនអាចស្វែងរកការបង្រួបបង្រួមជាតិបានឡើយ"។

គណបក្សសង្គ្រោះជាតិបានដឹកនាំការធ្វើដំណើរមុនៗទៅកាន់តំបន់ដែលមានវិវាទនៅតាមព្រំដែនវៀតណាមកាលពីពាក់កណ្តាលឆ្នាំ២០១៥ ដោយជំរុញឱ្យរដ្ឋាភិបាលចេញកំណត់ទូតទៅក្រុងហាណូយសុំឱ្យវៀតណាមផ្អាកការសាងសង់ ឬដក ថយចេញពីតំបន់ព្រំដែនដែលមានទំនាស់នេះ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបំបិទសំឡេងយុទ្ធនាការនេះដោយបញ្ជាឱ្យចាប់ខ្លួនលោក ហុង សុខហួរ សមាជិកព្រឹទ្ធសភាគណបក្សប្រឆាំង កាលពីខែសីហាឆ្នាំមុន ដោយប្រកាសថា នរណាដែលអះអាងថារដ្ឋាភិបាលប្រើប្រាស់ផែនទីមិនត្រឹមត្រូវដើម្បីកំណត់ព្រំដែននោះនឹងប្រឈមជោគវាសនាស្រដៀងគ្នានេះ។

ប៉ុន្តែបញ្ហានេះមិនបានស្ងប់ស្ងាត់ទេ ហើយលោក វ៉ា គឹមហុង រដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែនបានសារភាពដោយត្រង់គួរឱ្យកត់សម្គាល់មួយកាលពីសប្តាហ៍មុនថា? ប្រទេសកម្ពុជាគ្មានពុំនឹងក្នុងការរារាំងវៀតណាមមិនឱ្យសាងសង់អ្វីយ៉ាងហោចណាស់មួយនៅក្នុង"តំបន់ស" ដែលប្រទេសទាំងពីរបានយល់ព្រមមិនធ្វើអ្វីរហូតដល់ប្រទេសទាំងពីរយល់ព្រមលើខ្សែបន្ទាត់ព្រំដែនរួចរាល់។

លោក វ៉ា គឹមហុង បាននិយាយកាលពីសប្តាហ៍មុនអំពីប៉ុស្តិ៍យាមនៅតាមព្រំដែនវៀតណាមដែលកំពុងសាងសង់នៅក្នុងតំបន់សក្នុងខេត្តរតនគិរីថា "យើងបានស្នើឱ្យពួកគេបញ្ឈប់ ប៉ុន្តែពួកគេមិនស្តាប់យើងទេ"។

លោករដ្ឋមន្ត្រីសួរថា "សូមប្រាប់ខ្ញុំមកមើល

**តទៅទំព័រទី ២១**



សកម្មជនយុវជនគណបក្សសង្គ្រោះជាតិលើកដៃគាំទ្រអំឡុងពិធីសំណេះសំណាលក្រោមអធិបតីភាព លោក កឹម សុខា អនុប្រធានគណបក្សប្រឆាំងនៅទីស្នាក់ការកណ្តាលគណបក្សក្នុងរាជធានីភ្នំពេញ កាលពី ម្សិលមិញ។ Facebook

# KEM SOKHA SAYS PEOPLE, NOT WALL, MUST PROTECT BORDERS

**byKhuonNarim | November 21, 2016**

Invoking U.S. President-elect Donald Trump's pledge to build a wall on the border with Mexico, deputy opposition leader KemSokha said Cambodia could not afford such infrastructure, but still must focus on securing the border with Vietnam.

Mr. Sokha was speaking on Sunday to hundreds of youth activists at the CNRP's Phnom Penh headquarters, where he told them to focus their campaigning for upcoming elections on the CNRP's plan to strengthen border protection. The CNRP has long campaigned against illegal Vietnamese immigration and Vietnamese incursions into Cambodia.

Deputy opposition leader Kem Sokha, center, claps along with senior lawmaker TioulongSaumura, left, during a gathering with youth activists at the CNRP's Phnom Penh headquarters on Sunday, in a photograph posted to Mr. Sokha's Facebook page.

"We have to develop the border by getting a lot of people to live along the border. First, build boundary roads along the border; second, markets, pagodas, jobs, factories and agriculture farming," Mr. Sokha said.

The acting CNRP president said the opposition's previous campaigns criticizing the government's work defending the border-focusing on ongoing Vietnamese incursions-had failed to offer constructive solutions.

"We have attacked them, but we don't have new recommendations, so we could not find national reunification," he said.

The CNRP led various trips to disputed areas along the Vietnamese border in the middle of last year, prompting the government to release diplomatic notes to Hanoi asking Vietnam to halt construction or pull back from contested border sites.

Prime Minister Hun Sen largely silenced the campaign by ordering the arrest of opposition Senator Hong Sok Hour in August last year and announcing that anyone claiming that the government was using the wrong maps to define the border would face a similar fate.

However, the issue has not gone away, and Border Affairs Minister VarKimhong made the remarkably frank admission last month that Cambodia was helpless in stopping Vietnam from building in at least one "white zone," areas that both countries have agreed to stay out of until they agree on the border line.

"We asked them to stop, but they did

**Continued to Page 21**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# នគរបាលប្រឆាំងការជួញដូរមនុស្សចាប់ខ្លួនជនជាតិអូស្ត្រាលីម្នាក់ដែលបើកគ្លីនិកផ្តល់សេវាពពោះជំនួស

**ដោយ ផាន់ ស៊ូមី | ថ្ងៃច័ន្ទ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦**

ក្រុមមន្ត្រីបានឱ្យដឹងកាលពីម្សិលមិញថា មិនដល់មួយខែផង បន្ទាប់ពីមានការប្រកាសបម្រាមលើការពពោះជំនួសជនជាតិអូស្ត្រាលីម្នាក់ និងគិលានុបដ្ឋាកកម្ពុជា ព្រមទាំងមន្ត្រីក្រសួងពាណិជ្ជកម្មត្រូវបាននគរបាលប្រឆាំងការជួញដូរមនុស្សចាប់ខ្លួននៅក្នុងរាជធានីភ្នំពេញកាលពីថ្ងៃសុក្រពីបទបើកគ្លីនិកផ្តល់សេវាពពោះជំនួស។

លោក កែវ ធា នាយការិយាល័យប្រឆាំងការជួញដូរមនុស្សរាជធានីបានលើកឡើងថា អ្នកស្រី ទាមមយ Davis-Charles អាយុ៤៩ឆ្នាំជាជនជាតិអូស្ត្រាលីដែលត្រូវបានចុះបញ្ជីជាប្រធានគ្លីនិកសម្រាកព្យាបាល Fertility Solutions PGD ត្រូវបានឃាត់ខ្លួននៅតាមបណ្តោយមហាវិថីរុស្ស៊ី ខណៈលោកស្រីកំពុងធ្វើដំណើរទៅកាន់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បន្ទាប់ពីត្រូវបានឃ្លាំមើលអស់រយៈពេល១០ខែ។

លោកបានលើកឡើងទៀតថា ជនជាតិខ្មែរពីរនាក់ឈ្មោះ ពេញ រិទ្ធី អាយុ២៨ឆ្នាំ ជាមន្ត្រីនៅក្រសួងពាណិជ្ជកម្ម និងឈ្មោះ សំរិទ្ធចាន់ចរិយា អាយុ៣៥ឆ្នាំជាគិលានុបដ្ឋាកនៅមន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ ត្រូវបានឃាត់ខ្លួននៅពេលក្បាលព្រលប់នៅទីតាំងដាច់ដោយឡែកពីគ្នាក្នុងរាជធានី។

លោក កែវ ធា បានមានប្រសាសន៍ថា"នៅក្នុងករណីនេះយើងបានធ្វើការស៊ើបអង្កេតភ្លាមព្រោះយើងដឹងថា មានមេខ្លោងបញ្ចុះបញ្ចូលស្ត្រីឱ្យយល់ព្រមធ្វើជាអ្នកពពោះជំនួស"។ លោកបានបន្ថែមថា អ្នកស្រី ទាមមយ Davis-Charles ក៏ជាប់សង្ស័យថាក្លែងបន្លំឯកសារផងដែរ ប៉ុន្តែលោកបានបដិសេធមិនរៀបរាប់លម្អិតនោះឡើយ។

លោកបានថ្លែងទាក់ទិននឹងជំនួញពពោះជំនួសថា "វាដូចការងារដែលអាជ្ញាធររបស់យើងធ្វើលើករណីនានា ដែលមេខ្លោងបញ្ចុះបញ្ចូលស្ត្រីឱ្យទៅធ្វើការនៅក្នុងប្រទេសចិនដែរ"។

អ្នកស្រី ទាមមយ Davis-Charles ដែលយកថ្លៃសេវាពីអតិថិជនរបស់ខ្លួនប្រហែល៥០.០០០ដុល្លារបានផ្លាស់អាជីវកម្មរបស់ខ្លួនពីប្រទេសថៃមកកម្ពុជាកាលពីឆ្នាំមុន បន្ទាប់ពីរដ្ឋាភិបាលយោធាបិទគ្លីនិកពពោះជំនួសនៅក្នុងប្រទេសនេះ។

លោកបានមានប្រសាសន៍ថា "គាត់ធ្លាប់បានផ្តល់សេវាពពោះជំនួសជាច្រើនមកហើយក្នុងប្រទេសថៃ។ ពេលប្រទេសថៃបិទសេវានេះ គាត់បានផ្លាស់ប្តូរមកកម្ពុជាវិញម្តង"។

នាយការិយាល័យរូបនេះបានឱ្យដឹងទៀតថា ម្តាយដែលពពោះជំនួសចំនួន៥នាក់បានផ្តល់កំណើតឱ្យកូនចំនួន៦នាក់ក្នុងប្រទេសកម្ពុជាក្នុងឆ្នាំនេះ បន្ទាប់ពីទទួលបានប្រាក់ចន្លោះពី ១០.០០០ ដុល្លារ ដល់១២.០០០ដុល្លារតាមរយៈគ្លីនិករបស់



ក្រុមមន្ត្រីសាកសួរអ្នកស្រី Tammy Davis-Charles ក្នុងក្រុងភ្នំពេញកាលពីថ្ងៃអាទិត្យ ក្នុងរូបថតដែលផ្តល់ឱ្យដោយនគរបាល។

អ្នកស្រី ទាមមយ Davis-Charles ដែលក៏បានរៀបចំឱ្យម្តាយ២០នាក់ផ្សេងទៀតពពោះជំនួសដោយឥឡូវកំពុងមានផ្ទៃពោះទៅហើយផងដែរ។

លោកបានមានប្រសាសន៍ថា "គាត់បាននិយាយថា គាត់ជួយពលរដ្ឋខ្មែរក្រីក្រ គាត់បានបញ្ចុះបញ្ចូលពួកគេឱ្យពពោះជំនួស ហើយប្រាប់ពួកគេថា គ្មានផលប៉ះពាល់ទេ"។ កិច្ចប្រជុំដែលមានការចូលរួមដោយអាជ្ញាធរមកពីអង្គភាពប្រឆាំងការជួញដូរមនុស្សក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល ស្ថានទូតអូស្ត្រាលី និងម្តាយពពោះជំនួសដែលឥឡូវកំពុងមានផ្ទៃពោះនោះ នឹងធ្វើឡើងនៅថ្ងៃព្រហស្បតិ៍ដើម្បីគិតគូថា តើនឹងត្រូវធ្វើអ្វីបន្ទាប់មកទៀត។

លោកបានថ្លែងថា "យើងបានគិតគូរអំពីបញ្ហាប្រឈមដែលអាចកើតមាននៅពេលក្រោយ។ យើងគិតគូរអំពីពួកគាត់ និងបានរៀបចំរួចហើយសម្រាប់ពួកគាត់ផង"។ លោកបានបន្ថែមថា តួនាទីជាក់លាក់ និងការទទួលខុសត្រូវនឹងត្រូវសម្រេចនៅក្នុងកិច្ចប្រជុំនេះ។ អ្នកស្រី ទាមមយ

**តទៅទំព័រទី២២**

# AUSTRALIAN FOUNDER OF SURROGACY FIRM ARRESTED AFTER BAN

byPhan Soumy | November 21, 2016

Less than a month after a ban was announced on surrogate pregnancies, an Australian and Cambodian nurse and Commerce Ministry official were arrested by anti-human trafficking police in Phnom Penh on Friday evening for operating a surrogacy clinic, officials said on Sunday.

Keo Thea, chief of the city's anti-human trafficking bureau, said that Australian national Tammy Davis-Charles, 49, who is listed as director of the Fertility Solutions PGD clinic, was detained on Russian Boulevard while she was traveling toward Phnom Penh International Airport after being monitored for 10 months.

Two Cambodian nationals, Penh Rithy, 28, an officer at the Commerce Ministry, and SamrithchanChariya, 35, a nurse at the Phnom Penh Referral Hospital, were detained at separate locations in the capital earlier in the evening, he said.

"In this case, we conducted a primary investigation because we knew that there are ringleaders persuading women to be surrogates," Mr. Thea said, adding that Ms. David-Charles was also suspected of faking documents, although he declined to divulge details.

"It's like the work that our authorities do on cases where ringleaders persuade women to go to China," he said of the surrogacy trade.

Ms. Davis-Charles, who charges clients around $50,000 for her services, moved her business from Thailand to Cambodia last year after the military junta shut down surrogacy clinics in the country, he said.

"She has done many in Thailand," he said. "When Thailand closed it down, she came to do it in Cambodia."

Five surrogate mothers have given birth to six children in Cambodia this year after receiving payments from between $10,000 to $12,000 through Ms. Davis-Charles' company, which had also made arrangements for about 20 surrogate mothers who are still pregnant, Mr. Thea said.

"She said she helped poor Cambodians," Mr. Thea said. "She persuaded them to do the surrogacy and told them that there is no harm."

A meeting involving authorities from the anti-human trafficking unit, the justice and health ministries, the Australian Embassy and pregnant surrogate mothers would be held on Thursday to figure out what to do next, Mr. Thea said.

"We have thought about the risks that could happen afterward. We have thought about them and already prepared for them," he said, adding that specific duties and responsibilities would be decided during the meeting.

Ms. Davis-Charles is set to be sent to the Phnom Penh Municipal Court today while the two Cambodians were questioned at the court on Sunday and would return today, he said.

The Fertility Solutions PGD website contains numerous positive testimonials from clients, including one from February in which a couple named Duncan and Erin are quoted as saying, "Thank goodness for the internet. And thank you to the universe for sending us Tammy."

The arrests come after Health Minister Mam Bunheng announced a ban on surrogacy-part of a wider proclamation officially released by the ministry-to representatives of

**Continued to Page 22**




## តមកពីទំព័រទី ០៤ ព្រះរាជពិធីបុណ្យអុំទូក -អកអំបុក...

ពួកគាត់ទាំងអស់គ្នាបានលះបង់ពេលវេលាធ្វើស្រែចំការបោះបង់ចោលការប្រកបរបរនានានៅស្រុកកំណើតដើម្បីមកចូលរួមនៅរាជធានីភ្នំពេញដោយមិនខ្លាចនឿយហត់ ។ លោកពូក៏បានសសើដល់សាលារាជធានីភ្នំពេញដែលបានរៀបចំពិធីបុណ្យនេះយ៉ាងល្អប្រសើរ និងមានសណ្ដាប់ធ្នាប់ល្អដោយមិនមានការឈ្លោះទាស់ទែងនានាគួរឱ្យកត់សម្គាល់។ ប្អូនប្រុសរតនាដែលជាកីឡាករប្រណាំងទូកព្រះទីនាំងសារាយអណ្តែតចង្ហាន់ហុយ មកពីស្រុកបរិបូណ៌ វត្តបរិបូណ៌ខេត្តកំពង់ឆ្នាំងប្អូនមានវ័យខ្ទង់ម្ភៃឆ្នាំជាងបានសម្តែងក្តីសប្បាយរីករាយយ៉ាងខ្លាំងប្អូនថាការមកប្រកួតសំខាន់ចង់បានជ័យលាភី ព្រមទាំងការឧបត្ថម្ភផ្សេងៗមានដូចជាសំលៀកបំពាក់ជាដើម ហើយប្អូនមកប្រកួតដោយស្ម័គ្រចិត្ត និងមានការយល់ព្រមពីក្រុមគ្រួសាររបស់ប្អូន ។ ឆ្លៀតពេលកំពុងសំចតទូកអ្នកទស្សនាខ្លះបានទិញអំពៅសាងបោះពីលើច្រាំងទៅឱ្យកីឡាករទូកដើម្បីជំនួយកំលាំងក្នុងស្មារតីសាមគ្គីគ្នាអ្នកទស្សនាយ៉ាងច្រើនកុះករបានចូលរួមទស្សនាផ្តល់កំលាំងចិត្តយ៉ាងខ្លាំងដល់កីឡាករប្រណាំងទូកនាឱកាសនោះ។

ក្នុងការប្រកួតក្នុងឆ្នាំនេះទូកដែលមានល្បឿនលឿនជាងគេបានទៅទូកឈ្មោះ "សារ៉ាយតេជោសែនជ័យ "មកពីខេត្តកណ្តាលដោយប្រើថេរវេលាប្រកួតក្នុងរយៈពេលបីថ្ងៃ២៨នាទី៣០.៦០វិនាទី។

រីឯផ្នែកសោភណ័ស្អាតដាច់គេបានទៅលើទូកងចំនួនបី គឺទូកទីមួយឈ្មោះថា "តេជះសែនជ័យរស្មីមេគង្គ" ទូកមកពីរាជធានីភ្នំពេញទីពីទូកឈ្មោះ" គងពិសីមហាសែនតេជះ "មកពីខេត្តកំពង់ស្ពឺ និងទូកទីបីមានឈ្មោះ" ព្រះទីនាំងព្រះគោសែនជ័យ "មកពីខេត្តកំពត។ ក្នុងឆ្នាំ២០១៦នេះមានទូកងចូលរួមប្រណាំងសរុបចំនួន ២៥៧ទូកក្នុងនោះរួមមានកីឡាករចំណុះសរុបចំនួន១៧,៧៣៦នាក់។ កាលពីថ្ងៃទី១១ ខែវិច្ឆិកា នេះមានឧបទ្ទវហេតុប៉ះទង្គិចគ្នារវាងទូកទេសចរណ៍ឈ្មោះ Cruiseco Adventure បានបើកមកបុកទូកងមួយគ្រឿងឈ្មោះ "រស្មីស្រីស្រស់ដាញ់ទិព្វ" មកពីវត្តអម្ពវ័ន រាជធានីភ្នំពេញដែលកំពុងត្រៀមមុនការប្រកួតមកដល់បណ្តាលឱ្យចំណុះទូកពីរនាក់បានស្លាប់បាត់បង់ជីវិត ។

ដួងព្រះចន្ទ្រាបានរះយ៉ាងត្រចះត្រចង់លើផ្ទៃទន្លេសាប នៅក្នុងព្រះរាជវាំង នៅតាមទីវត្តអារ៉ាមនានា និងនៅតាមគេហដ្ឋាននីមួយៗបានរៀបចំពិធីសែនព្រេនទៅតាមប្រពៃណីពីបុរាណកាលមក មានអំបុក ដូងខ្ចី ចេកទុំ ផ្កាភ្ញី និងបំភ្លឺដោយប្រទីបទានធូបថ្វាយព្រះខែ៕

**ពិទូ ពិន**



## តមកទំព័រទី ១៨ លោក កឹម សុខាៈ ប្រជាពលរដ្ឋជា...

បើពួកគេមិនឈប់ តើយើងអាចធ្វើអ្វីបាន តើអ្នកចង់ឱ្យកម្ពុជាចាប់ផ្តើមសង្គ្រាមជាមួយវៀតណាមដើម្បីបញ្ឈប់ការសាងសង់ឬ?"។

ដោយចង្អុលបង្ហាញទៅនឹងហេតុពិតដែលថាប្រជាជនថៃ និងវៀតណាមជាច្រើនរស់បានល្អប្រសើរតាមបណ្តោយព្រំដែននៃប្រទេសរបស់ពួកគេនោះលោក កឹម សុខា បានមានប្រសាសន៍កាលពីម្សិលមិញថា មានមធ្យោបាយដែលមានប្រសិទ្ធភាពជាងនេះសម្រាប់កម្ពុជាក្នុងការការប្រទេសយើងនឹងការពារព្រំដែនយើងមិនមានប្រាក់សាងសង់កំផែងដូចលោកដូណាល់ត្រាំឡើយ។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សកាន់អំណាចបានមានប្រសាសន៍ថា ការលើកឡើងរបស់លោក កឹម សុខា ជំរុញឱ្យមានការរស់នៅកាន់តែប្រសើរនៅតាមបណ្តោយព្រំដែននោះគឺមិនសមហេតុសមផលឡើយ ហើយថាគណបក្សប្រជាជនកម្ពុជាបានអនុវត្តផែនការផ្សេងៗទៀតរួចហើយ។



លោក កឹម សុខា អនុប្រធានបក្សប្រឆាំង ទះដៃជាមួយលោកស្រី ជូឡុង ស៊ូមូរ៉ា តំណាងរាស្រ្ត អំឡុងការជួបជុំសកម្មជនយុវជន នៅទីស្នាក់ការគណបក្សសង្គ្រោះជាតិក្នុងក្រុងភ្នំពេញកាលពីថ្ងៃអាទិត្យក្នុងរូបថតដែលបង្ហោះតាមទំព័រហ្វេសប៊ុករបស់លោក កឹម សុខា។

ពារទឹកដីរបស់ខ្លួន ប្រសិនបើមានការប្រើប្រាស់ធនធានត្រឹមត្រូវសម្រាប់កិច្ចខិតខំប្រឹងប្រែងនេះ។

លោក កឹម សុខា បានមានប្រសាសន៍ថា "ហេតុអ្វីបានជាប្រជាជនរបស់ពួកគេជាច្រើនរស់នៅតាមព្រំដែន ពួកគេទទួលបានការជំរុញទឹកចិត្ត មានទឹកគ្រប់គ្រាន់ ការបង្កើតការងារ និងការផ្តល់ប្រាក់កម្ចីដោយគ្មានការប្រាក់"។

លោកបានបន្ថែមថា "យើងត្រូវផ្តល់អ្នកបច្ចេកទេសកសិកម្ម។ ទី២ ផ្តល់ទុនដោយគ្មានការប្រាក់ ឬផ្តល់ទុនដោយមានការប្រាក់ទាប។ ទី៣ ត្រូវធ្វើឱ្យប្រាកដថា ស្វែងរកទីផ្សារសម្រាប់អ្នកដែលរស់នៅតាមបណ្តោយព្រំដែន"។

លោក កឹម សុខា បន្ថែមថា ទោះយ៉ាងណាការសាងសង់របាំងជាក់ស្តែងនៅតាមព្រំដែនពិតជាមិនអាចទៅរួចទេដោយលោកសំដៅដល់ការសន្យារបស់លោកដូណាល់ត្រាំថានឹងសាងសង់កំផែង"ដែលមិនអាចជ្រៀតចូលបាន ហើយស្រស់ស្អាត" ដើម្បីកុំឱ្យជនអន្តោប្រវេសន៍មិុកស៊ិកូខុសច្បាប់ចូលក្នុងសហរដ្ឋអាមេរិក។

លោក កឹម សុខា បានមានប្រសាសន៍ថា "គណបក្សសង្គ្រោះជាតិមានគោលនយោបាយរួចហើយ គឺថានៅពេលយើងឈ្នះឆ្នោតដឹកនាំ

លោកបានថ្លែងថា"វាជាសម្តីរបស់អ្នកបោកប្រាស់។ តើរដ្ឋាភិបាលណាក្នុងពិភពលោកផ្តល់ប្រាក់កម្ចីឱ្យប្រជាជនដោយមិនយកការប្រាក់នោះ។ វាជាល្បែងនៃការធ្វើយុទ្ធនាការ។ ការនិយាយពីបញ្ហាទាំងនេះវាងាយស្រួលទេ"។

លោក សុខ ឥសាន បានថ្លែងថា ផ្នែកផ្សេងទៀតនៃផែនការព្រំដែនរបស់លោក កឹម សុខា ឆ្លុះបញ្ចាំងឱ្យឃើញពីផែនការរបស់គណបក្សប្រជាជនកម្ពុជាដែលបានធ្វើការរួចទៅហើយដើម្បីប្រែក្លាយតំបន់ដែលហែកហួរដោយសង្គ្រាមទៅជាទីប្រជុំជនព្រំដែនដែលអាចរស់នៅបាន។

លោកបានមានប្រសាសន៍ថា "យើងបានប្រែក្លាយខ្សែបន្ទាត់ដែនដែលជាសមរភូមិសង្គ្រាមពីមុន ទៅជាតំបន់អភិវឌ្ឍន៍ដោយមានទីផ្សារនិងសុខដុមនីយកម្មរវាងប្រជាជននិងប្រជាជនរវាងប្រទេសនិងប្រទេស ដូច្នេះគាត់បាននិយាយពីផែនការនេះតាមគណបក្សប្រជាជនកម្ពុជា"។

លោក អ៊ូ វីរៈ អ្នកវិភាគនយោបាយដែលបានរិះគន់គណបក្សសង្គ្រោះជាតិចំពោះការពឹងផ្អែកលើការប្រើវោហារសាស្ត្រប្រឆាំងវៀតណាមដើម្បីទទួលបានគាំទ្រនោះ?បានមានប្រសាសន៍ថា បញ្ហាព្រំដែនគឺជាកង្វល់ដ៏ធំរបស់ប្រជាពលរដ្ឋ ប៉ុន្តែចាំបាច់ត្រូវពិភាក្សានៅក្នុងមធ្យោបាយដែលមិនបញ្ឆេះវោហារសាស្ត្រប្រឆាំងវៀតណាមដែលបានរាលដាលរួចទៅហើយនោះ"។

លោក អ៊ូ វីរៈ បានថ្លែងថា "ខ្ញុំគិតថាព្រំដែនគឺជាបញ្ហាដ៏មានប្រសិទ្ធភាព វាជាបញ្ហាមួយក្នុងចំណោមបញ្ហាដែលគណបក្សប្រជាជនកម្ពុជាលំបាកដោះស្រាយពីព្រោះគណបក្សប្រជាជនមិនព្រមពិភាក្សាអំពីប្រវត្តិសាស្ត្រ"។

លោកបាននិយាយដល់គណបក្សសង្គ្រោះជាតិថា "បញ្ហាទាំងអស់អាស្រ័យលើថា តើពួកគេលើកឡើងពីបញ្ហានេះដូចម្តេច និងពីយុទ្ធនាការកន្លងមកដែលពួកគេមានការប្រកាន់ជាតិសាសន៍ខ្លាំងនៅក្នុងការលើកឡើងរបស់ខ្លួននិងបញ្ហាមួយចំនួនដែលពួកគេបាននិយាយដូច្នេះវាគ្រោះថ្នាក់ណាស់"។

លោកបន្ថែមថា "ប៉ុន្តែពេលពួកគេលើកឡើងពីបញ្ហាការពារព្រំដែន វាហួសពីព្រំដែនព្រោះពួកគេមិនមានសំណើរឹងមាំ ឬសមហេតុផលពីរបៀបដែលត្រូវដោះស្រាយឡើយ"៕

**សារុន(រាយការណ៍បន្ថែមដោយ** Colin Meyn)

Continued from page 18

# Minister Backs Legal ...

not listen to us," Mr. Kimhong said of a Vietnamese border guard office that was being built in a white zone in Ratanakkiri province.

"Please tell me: If they don't stop, what can we do?" the minister asked. "Do you want Cambodia to start a war with Vietnam to stop the construction?"

Mr. Sokha said on Sunday that there were more effective ways for Cambodia to defend its land if proper resources were devoted to the efforts, pointing to the fact that many Thai and Vietnamese citizens live relatively well along their country's borders.

"Why do a lot of their people live on the border? They get encouragement, enough water, job creation, loans without interest rates," Mr. Sokha said.

"We have to provide agricultural technicians. Second, provide capital free of interest rates or given at low interest rates. Third, make sure to find a market for whoever lives along the border," he added.

Building a physical barrier along the border, however, was out of the question, Mr. Sokha added, referencing the promise from Mr. Trump to build a "impenetrable and beautiful" wall to keep illegal Mexican immigrants out of the U.S.

"Our National Rescue Party already has a policy: When we win the election to lead the country we will protect the border-we don't have money to build a wall like Mr. Trump," Mr. Sokha said.

Ruling party spokesman SokEysan said that some of Mr. Sokha's suggestions for encouraging better lives along the border were absurd, and that the CPP had already been implementing others.

"It is the speech of a cheater. Does any government in the world give loans to people without charging an interest rate?" he said. "It is the gamble of campaigning. It is easy to say such things."

Mr. Eysan said that other parts of Mr. Sokha's border plans mirrored those of the CPP, which had already worked to turn war-torn areas into livable border towns.

"We worked to change the border line that was a war field before to become a developed area with markets and harmonization between people and people and country and country, so he said this after the CPP," he said.

OuVirak, a political analyst who has criticized the CNRP for falling back on anti-Vietnamese rhetoric to gain support, said the border issue was a major concern of the people, but needed to be discussed in a way that did not fuel already widespread anti-Vietnamese sentiment.

"I think the border is an effective issue. It's one of those issues that the CPP finds very difficult to shake off because the CPP refuses to discuss the history," Mr. Virak said.

"It all depends on how they raise the issue, and from past campaigns they have been pretty racist in their remarks and the things they said, so that's dangerous," he said of the CNRP.

"But also, while they raise the issue of a secure border, it went too far in the sense that they didn't have a concrete or reasonable proposal for how to deal with it."

**(Additional reporting by Colin Meyn)**

តមកពីទំព័រទី ១៩ នគរបាលប្រឆាំងការជួញដូរមនុស្ស...

Davis-Charles នឹងត្រូវបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃនេះ រីឯជនជាតិខ្មែរពីរនាក់ត្រូវបានសាកសួរនៅសាលាដំបូងកាលពីម្សិលមិញ ហើយនឹងត្រឡប់មកវិញនៅថ្ងៃនេះ។

គេហទំព័ររបស់មន្ទីរសម្រាកព្យាបាល Fertility Solutions PGD នេះមានសក្ខីកម្មវិជ្ជមានមួយចំនួនពីអតិថិជនក្នុងនោះមានមួយចុះកាលបរិច្ឆេទនៅខែកុម្ភៈ ដែលប្តីប្រពន្ធមួយគូឈ្មោះ ឌុនចាន និង រ៉ែន ត្រូវបានដកស្រង់សម្តីមកថា "អរគុណព្រះជាម្ចាស់ហើយដែលប្រទានគេហទំព័រនេះហើយសូមអរគុណដល់ពិភពលោកហើយដែលបញ្ជូនទាមមយមកឱ្យយើង"។

ការចាប់ខ្លួនទាំងនេះកើតមានឡើងបន្ទាប់ពីលោក ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាលបានប្រកាសបម្រាមលើការពពោះជំនួសដែលជាផ្នែកនៃសេចក្តីប្រកាសទូទៅចេញជាផ្លូវការដោយក្រសួងទៅកាន់តំណាងសហគមន៍វេជ្ជសាស្ត្រកម្ពុជាកាលពីថ្ងៃទី៣១ខែតុលា។

សេចក្តីសម្រេចនោះធ្វើឡើងបន្ទាប់ពីលោក អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អំពាវនាវសុំឱ្យចេញច្បាប់ហាមមិនឱ្យមានការពពោះជំនួស។ ក្រសួងសុខាភិបាលបានបញ្ជាក់ជាក់លាក់ថា បម្រាមក្នុងពេលបច្ចុប្បន្ននៅតែអនុវត្ត រហូតដល់ច្បាប់គ្រប់គ្រងប្រតិបត្តិការនេះចូលជាធរមាន។

លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌បានលើកឡើងថា ច្បាប់នេះដែលបង្កើតឡើងដើម្បីការពារអ្នកពពោះជំនួសជនជាតិខ្មែរ និងទារកកំពុងតែតាក់តែងប៉ុន្តែ លោកមិនដឹងថាពេលណានឹងរួចរាល់នោះឡើយ។

លោកបានមានប្រសាសន៍ថា "គេកំពុងតែសិក្សា និងរៀនសូត្របទពិសោធន៍ពីប្រទេសផ្សេងៗដែលបានតាក់តែងច្បាប់នេះរួចហើយ ហើយថា តើពួកគេអនុវត្តបែបម៉េច ហើយថាតើយើងគួរតាក់តែងយ៉ាងដូចម្តេចដើម្បីឱ្យស្របតាមបរិបទកម្ពុជា"។

លោក Sam Everingham ប្រធានអង្គការតស៊ូមតិ Families Through Surrogacy ដែលមានមូលដ្ឋាននៅប្រទេសអូស្ត្រាលីបានអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជាធានា "សុវត្ថិភាពជូនទារកទើបកើត និងឪពុកម្តាយថ្មីរបស់ពួកគេ"។

លោកបានលើកឡើងតាមអ៊ីម៉ែលថា "នេះជាសារមួយបញ្ជាក់យ៉ាងច្បាស់ពីអាជ្ញាធរកម្ពុជាថា ពួកគេកំពុងអនុវត្តយ៉ាងតឹងរ៉ឹងលើសេចក្តីប្រកាសក្នុងពេលថ្មីៗស្តីអំពីបម្រាមលើការរៀបចំសេវាពពោះជំនួស"។

លោកបានបន្ថែមថា "ជាអកុសលការចាប់ខ្លួនអ្នកស្រី Tammy Davis-Charles និងអ្នកផ្សេងៗទៀត នឹងធ្វើឱ្យអ្នកពពោះជំនួសដែលអ្នកស្រីជួល និងអ្នកដែលចង់ក្លាយជាឪពុកម្តាយជាច្រើននៅក្នុងបញ្ជីរបស់អ្នកស្រីមានការព្រួយបារម្ភយ៉ាងខ្លាំង ក្នុងនោះភាគច្រើននៃអ្នកទាំងនេះគឺជាជនជាតិអូស្ត្រាលី"។

លោកបានមានប្រសាសន៍បន្ថែមទៀតថា "អ្នកពពោះជំនួសជនជាតិខ្មែរប្រហែលជាព្រួយបារម្ភចំពោះសុវត្ថិភាពផ្ទាល់ខ្លួន និងដោះស្រាយបញ្ហាដោយខ្លួនឯង។រដ្ឋាភិបាលកម្ពុជាត្រូវតែផ្តល់ការធានាភ្លាមៗចំពោះអ្នកពពោះជំនួសដែលកំពុងមានផ្ទៃពោះថា ពួកគេនឹងមិនត្រូវបានផ្តន្ទាទោសនោះឡើយ"៕

**ស៊ុយឈាង (រាយការណ៍បន្ថែមដោយ George Wright)**

Continued from page 19

# AUSTRALIAN FOUNDER OF....

Cambodia's medical community on October 31.

That decisions came shortly after Justice Minister AngVongVathana called for a law banning surrogate pregnancies. The Health Ministry has clarified that the current ban will remain in place until a law regulating the practice comes into force.

Justice Ministry spokesman Chin Malin said on Sunday that the law, meant mainly to protect the Cambodian surrogates and children, was being prepared, but he was unsure when it would be ready.

"They are studying and learning from experiences from other countries that have prepared this law and how they enforce them and we are going to see how we should prepare it to align with the context of Cambodia," he said.

Sam Everingham, director of Australia-based advocacy group Families Through Surrogacy, called on the Cambodian government to guarantee "the safe exit of newborns and their new parents."

"This is a clear message from the Cambodian authorities that they are serious about their recent announcement of a ban on surrogacy arrangements," Mr. Everingham said in an email.

"Unfortunately, the arrests of Ms Charles and others will be very worrying for the surrogates she has employed and the many intended parents on her books-most of those being Australians," he said.

"Cambodian surrogates may be concerned for their own safety and take matters into their own hands. The Cambodian government must immediately provide reassurance to pregnant surrogates that they will not be prosecuted."

(Additional reporting by George Wright)

Continued from page 08

# Elk Grove makes history:...

The Hmong people are an ethnic group with their own language and culture -- but without a country. Most of them hail from Laos, but they fled to the U.S. when the Communists took over and now Minnesota and California have the largest Hmong communities in the country.

"I happen to be of Hmong decent, yes," Ly said. "Thirty-plus years ago, I came here as a refugee as a 4-year-old. And I was very fortunate to take advantage of a free public education. And I was very fortunate to attend UC Davis."

After college, he became active in the Hmong community.

Back in 2007, when General VangPao, a hero in the Hmong community was falsely accused of plotting to overthrow the Communist government of Laos, Ly served as a rally organizer. In the end, Pao was vindicated when the U.S. Attorney's Office dropped all the charges against him.

**That was then.**

But now, Ly said he wants to make sure Elk Grove is properly compensated if state and federal authorities approve the controversial Wilton Rancheria Resort and Casino.

"The jurisdiction of the city council is not that of bringing a casino in," Ly said. "It was to make sure that the constituents of the city of Elk Grove get their fair share in the event that it did come."

Ly said he's focused on bringing jobs to Elk Grove and to help ease traffic congestion.

"The council has done a tremendous job this past year alone," Ly said. "We've identified and brought in about 6,000 jobs -- but there's still a lot of work to do."

As Elk Grove Mayor-elect, Ly will make only $9,600 a year, which explains why he'll continue to work two jobs.

As one city hall insider told KCRA, "Being mayor is a full time job with part time pay."




តមកពីទំព័រទី ០២

# ពិណបញ្ចពណិ( សមាគមអង្គរសម្តែង...)

របាំទី៤ ជារបាំប្រពៃណី មានឈ្មោះថា "ពិណ បញ្ចពណិ" ដែលនិយាយពី"ស្នេហា" ពី"តណ្ហា"នាឋានសួគ៌ប្រកបដោយលំអនៃសួនបុប្ផា នឹងទេពអប្សរតែក៏ជាប្រភពនៃជម្លោះរបស់មនុស្សសត្វដែរ។ នៅពេលដែលបុរសពីរនាក់ស្រឡាញ់ស្ត្រីតែមួយតែមិនអាចទទួលសេចក្តីស្រឡាញ់តបវិញបាននោះ ក៏ផ្តើមមានកំហឹងដាក់គ្នាទៅវិញទៅមកយកជម្លោះជាមធ្យោបាយ ហើយក៏បំផ្លាញសួនច្បារក្នុងឋានសួគ៌ខ្ទេចខ្ទីអស់ ។ វៀជីនា ប្រាក់ ជានាថការីដ៏ល្បីឈ្មោះរបស់សមាគមអង្គរបានក្លាយជាតួ"ទេពអប្សរសួគ៌ា"លេងឧបករណ៍ពិណដែលបញ្ចេញមហិទ្ធិរិទ្ធបញ្ចពណិឬព្រហ្មវិហារធម៌ទាំង៥ ដើម្បីរម្ងាប់ជម្លោះដោយ"តណ្ហានឹងស្នេហា"ប្រកបដោយប្រសិទ្ធភាព។ ភាពជានាគ្នាបានត្រឡប់មកវិញ ជាមួយគ្នានឹងភាពរីករាយ ព្រមទាំងសោភណ្ឌភាពក៏បានកើត


ក្រុមភ្លេងសាកលវិទ្យាល័យ យូម៉ាសឡូវែល


បណ្ឌិត ហង្ស រិទ្ធីរ៉ាវុឌ្ឍ








ក្រុមអ្នកសិល្បករសម្តែងដោយសមាគមអង្គរ

ឡើងវិញដែរ នៅឋានសួគ៌ា។ ក្នុងរូបភាពជា"សិល្បទេវះ"មួយទៀតដែលផ្ទាប់ជាមួយអតីតកាល ដោយការប្រើរបាំប្រពៃណីជាយាននាំសារ, រឿង"ពិណបញ្ចពណិ"ក៏ជារឿងស្របនឹងជាធម្មជាតិរបស់មនុស្សសម័យថ្មីបានដែរ។ បណ្ឌិតខាងដូរ្យតន្ត្រី ហង្ស ឬទ្ធីរាយុទ្ធ ដែលបានតែងរឿងដកស្រង់ពីរឿងលើថ្មអង្គរវត្តជាថ្មីម្តងទៀត បានចងភ្ជាប់សាច់រឿងទៅនឹងសម្លេងនៃគ្រឿងភ្លេងបូរាណ មានពិណ ទ្រ គង សម្ភោ ស្គរធំ ឈឹង ព្រមទាំងសម្លេងអ្នកច្រៀង...តែម្តងនេះមិនមែនត្រឹមតែសិល្បៈដ៏ល្អប្រណិតប៉ុណ្ណោះទេ តែសិល្បករចេះដង្ហួចនាំយក"ព្រលឹង"ឱ្យទស្សនិកជនស្ថិតក្នុង"ព្រលឹងថ្មអង្គរ"បានមួយរយៈយ៉ាងជ្រាលជ្រៅ។

ដោយសារស្នាដៃថែរក្សារបាំបូរាណជាវប្បធម៌ខ្មែរនៅឡូវែល"សមាគមអង្គរ"បានទទួលការកោតសសើរឆ្លងស្ថាប័នវប្បធម៌រដ្ឋឆ្លងស្ថាប័នវប្បធម៌ជាតិ រហូតដល់មានការកោតសសើរកំពូលពីវិមានប្រធានាធិបតីអាមេរិកាំងទៀតផង។ លោក ធីម ធូ ស្ថាបនិកដ៏សិ្វតស្វាញម្នាក់នៃសមាគមអង្គររួមដៃគ្នាជាមួយនឹងក្រុមប្រឹក្សាភិបាលប្រធានប្រតិបត្តិរួមគ្នានឹងគ្រូសិល្បបូរាណនឹងសិល្បនាថកម្ម( អាមេរិកនឹងកម្ពុជា) ហើយជាពិសេសរួមជាមួយសិល្បករស្រីប្រុសដ៏មានចំណេះខ្ពង់ខ្ពស់, ដែលបានជឿលើការថែទាំវប្បធម៌ដ៏រុងរឿងរបស់សហគមន៍ខ្មែរមិនបានបញ្ឈប់អភិវឌ្ឍន៍នៃវប្បធម៌អតីតកាលខ្មែរតែត្រឹមនេះទេ អង្គការមួយនេះ កំពុងធ្វើដំណើររបស់ខ្លួនឆ្ពោះទៅកាន់ការ ថែរក្សា "កេរដំណែលនៃវប្បធម៌មនុស្សជាតិ" ពីព្រោះតែស្រឡាញ់ភាពអស្ចារ្យនៃអ្វីដែលខ្លួនប្រឹងប្រែងធ្វើ, ពីព្រោះតែមានការលើកទឹកចិត្តរីតតែត្រឹមត្រូវ,នឹងពីព្រោះ"សិល្បទេវះ"នេះកំពុងអណ្តែតក្នុងបរិដ្ឋានប្រកបដោយ"សេរីភាព"ពេញលេញ៕

# បុណ្យឯករាជ្យជាតិ_កំណត់ប្រវត្តិសាស្ត្រ

**ដកស្រង់និងបកប្រែពីភាសាបារាំងពីសៀវភៅ**
"Les Cles du Cambodge"
**ដោយខ្មែរផុសស.រ.អា.**

**ឆ្នាំ១៩៤៦** *ថ្ងៃ៤មករា- ចុះហត្ថលេខាព្រមព្រៀងខ្មែរ-បារាំង បញ្ចប់របប "អាណាព្យាបាល" -ឯករាជ្យរដ្ឋបាល, តែនៅរក្សាទីប្រឹក្សាក្រសួងធំ៧នឹងនៅគ្រប់គ្រងក្រសួងកងទ័ពនឹងការបរទេស។ កម្ពុជានៅជាសមាជិកសហព័ន្ធបារាំង។

*ថ្ងៃទី១កញ្ញា-បោះឆ្នោតទី១សម្រាប់ "សភាធម្មនុញ្ញ"-គណបក្សប្រជាធិបតេយ្យបានឆ្នោតភាគច្រើនដាច់ខាត

*ថ្ងៃទី១៧វិច្ឆិការ- ដំណោះស្រាយបារាំង-សៀមប្រគល់ដីដែលកាត់យកដោយរដ្ឋបាល"តូក្យូ" ឱ្យទៅសៀមនាឆ្នាំ១៧៤១-ត្រឡប់មកឱ្យកម្ពុជាវិញ ដូចកិច្ចព្រមព្រាងបារាំង-សៀមកាលពីឆ្នាំ១៩៣៧មកវិញ។

**ឆ្នាំ១៩៤៧** *ថ្ងៃ៦ឧសភា- ខ្មែរអនុម័ត "រដ្ឋធម្មនុញ្ញថ្មី"- ហើយក្លាយទៅជា "ព្រះរាជាណាចក្រកម្ពុជាអាស្រ័យធម្មនុញ្ញ"

***ថ្ងៃទី១១កក្កដា-** មេដឹកនាំគណបក្សប្រជាធិបតេយ្យទ្រង់ ស៊ីសុវត្ថិ យុត្តិវង្ស បានត្រូវសុគតដោយមិនដឹងហេតុ

*ថ្ងៃ២១ធ្នូ- បោះឆ្នោតសភាជាតិក្រោមរដ្ឋធម្មនុញ្ញថ្មី- គណបក្សប្រជាធិបតេយ្យទទួលបានអាសនៈភាគច្រើនដាច់ខាត

ឆ្នាំ១៩៤៨៖ថ្ងៃទី២មករា- រដ្ឋាភិបាលទី១ក្រោមរដ្ឋធម្មនុញ្ញថ្មី លោក ជាម វិម ជានាយករដ្ឋមន្ត្រី

*១៥សីហា- រដ្ឋាភិបាលថ្មីទី២ លោក ប៉ែន នុត ជានាយករដ្ឋមន្ត្រី

**ឆ្នាំ១៩៤៩** ថ្ងៃទី១២កុម្ភៈ- រដ្ឋាភិបាលលោក យ៉ែម សំបូរ

*ថ្ងៃទី១៨កញ្ញា- សម្តេច នរោត្តម ស៊ីហនុ ជាព្រះប្រមុខរដ្ឋ ទ្រង់រំលាយសភាជាតិ ដោយសន្យាថា"ឱ្យមានការបោះឆ្នោតនៅខែវិច្ឆិការ"

*ថ្ងៃទី២០កញ្ញា- រដ្ឋាភិបាលថ្មី លោក អៀវ កើស ទទួលខុសត្រូវនៅចំពោះព្រះភក្ត្រព្រះមហាក្សត្រ

*ថ្ងៃទី២៩តុលា- រដ្ឋាភិបាល លោក យ៉ែម សំបូរ

*ថ្ងៃទី៨វិច្ឆិការ- ចុះហត្ថលេខាខ្មែរ-បារាំងព្រមព្រៀង"កម្ពុជាជាប្រទេសឯករាជ្យផ្ជាប់ទៅនឹងសហព័ន្ធបារាំង -កម្ពុជាមិនបោះបង់សិទ្ធរបស់ខ្លួនលើ "កូសាំងស៊ីន"ទេ

**ឆ្នាំ១៩៥០** ថ្ងៃទី១៤មករា- លោកអតីតនាយករដ្ឋមន្ត្រី អៀវ កើស មេដឹកនាំគណបក្សប្រជាធិបតេយ្យត្រូវគេលបសម្លាប់

*ថ្ងៃទី៣ឧសភា-មានការរំដើបរំជួលរបស់ពួកខ្មែរកុម្មុយនិស្ត ខ្មែរឥស្សរៈ សម្តេចសីហនុមកកាន់រដ្ឋាភិបាល ក្នុងតំណែងជានាយករដ្ឋមន្ត្រី


សម្តេចសីហនុ ឡើងគ្រងរាជនៅថ្ងៃ ២៣ មេសា ឆ្នាំ១៩៤១

**ឆ្នាំ១៩៥១** *ថ្ងៃទី១មិថុនា-រដ្ឋាភិបាល ទ្រង់ស៊ីសុវត្ថិ មុនីពង្ស

*ថ្ងៃទី៣មិនា-រដ្ឋាភិបាល លោក អ៊ុំ ឈាងស៊ុន

*ថ្ងៃទី១៣តុលា- រដ្ឋាភិបាល លោក ហ៊ុយ កន្ធុល

*ថ្ងៃ១៩តុលា- លោក អតីតនាយករដ្ឋមន្ត្រី សឺង ង៉ុកថាន់(ឆ្នាំ១៩៤៥) ត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីជាប់ឃុំឃាំងនៅប្រទេសបារាំងតាំងពីឆ្នាំ១៩៤៥

**ឆ្នាំ១៩៥២** ខែមករា-ខែមិថុនា មានការបះបោរជាច្រើនកន្លែងមានក្រុមកុម្មុយនិស្ត, ក្រុមឥស្សរៈដែលលោក សឺង ង៉ុកថាន់ ចូលរួម (ទាំង២ក្រុមក្លាយទៅជានៅក្រៅច្បាប់) នឹងក្រុមបក្សប្រជាធិបតេយ្យនាំគ្នាប្រឆាំងនឹងរបប ស៊ីហនុ នឹងការគ្រប់គ្រងរបស់បារាំង។

*ថ្ងៃទី១៦មិថុនា-រដ្ឋាភិបាល នរោត្តម សីហនុ

**ឆ្នាំ១៩៥៣** *ថ្ងៃទី១៤មករា-សាឡុត ស ត្រឡប់ពីស្រុកបារាំងវិញ

*ថ្ងៃទី១១មករា-ន.ស៊ីហនុ សុំអំណាចពិសេសពីសភាជាតិ

*ថ្ងៃទី១៣មករា-សម្តេច ន.ស៊ីហនុ រំលាយសភាជាតិជាលើកទី២, ប្រកាសភាពអាសន្នក្នុងប្រទេស,ចាប់ខ្លួនតំណាងរាស្ត្រគណបក្សប្រជាធិបតេយ្យ ៩ រូប, ដោយចោទថា ចូលដៃនឹងពួកវៀតមិញ នឹង ឥស្សរៈ។

*ថ្ងៃទី២៤មករា-រដ្ឋាភិបាលសម្តេចន.ស៊ីហនុ

*ថ្ងៃទី៩កុម្ភៈ- ផ្តើម "រាជបូជនីយកិច្ចដើម្បីឯករាជ្យ"ដាក់រាជ-ប្រគល់រាជបល្លង្គថ្វាយព្រះបិតាសោយរាជ្យបន្តរួចយាងចេញទៅប្រទេសបារាំង

*ថ្ងៃទី២៥មិនា- ជួបជាមួយប្រធានាធិបតីបារាំង"វ៉ាំងសង់ អូរីយ៉ូល" មិនបានលទ្ធផលទេ

*ថ្ងៃទី១៣មេសា- ន.ស៊ីហនុ ចេញដំណើរពីបារាំងទៅ កាណាដា, អាមេរិក រួចទៅ ជប៉ុនដើម្បីរកការគាំទ្រ

*ថ្ងៃទី១៩មេសា- ន.សីហនុ ធ្វើបទសម្ភាសន៍ជាមួយ"ញូយ៉ក‌ថាម" ធ្វើឱ្យបារាំងបារម្ភណ៏ចំពោះស្ថានភាពដែលនៅឥណ្ឌូចិន បារាំងកំពុងទទួលការវាយបកមកវិញ។

*ថ្ងៃ២៧មេសា- ក្រឹត្យថ្មីមួយបានបង្ហាញពីភាពតំណាងរបស់បារាំងនៅក្នុងប្រជុំប្រទេសឥណ្ឌូចិន-តំណាងបារាំង"ហ្សង់ រីស្ទ័ររូឈី" ឡើងជា "Haut commissaire de la republique"

*ថ្ងៃ១២មិថុនា-ន.ស៊ីហនុ និរទ្ទេសខ្លួនទៅសៀមរាប ប្រកាសឆន្ទៈ "ទាមទារឯករាជ្យឱ្យកម្ពុជាទាល់តែបាន"

*ថ្ងៃ១៤មិថុនា-ន.ស៊ីហនុ ទៅដល់បាងកកព្រះអង្គអន់ព្រះទ័យនឹងការទទួលមិនសមរម្យរបស់"វិបុលសង្គ្រាម"

*ថ្ងៃទី២៦ មិថុនា- នៅបាត់ដំបង ន.ស៊ីហនុប្រកាសហៅរាស្ត្រទូទាំងប្រទេសឱ្យក្រោកឈរមនុស្ស២០ម៉ឺននាក់ ឆ្លើយតបនឹងការប្រកាសនេះ

*ថ្ងៃទី៣កក្កដា-បារាំងប្រកាសថា ត្រៀមខ្លួនជាស្រេចសម្រាប់"ផ្តល់ឯករាជ្យនឹងអធិបតីភាពដល់កម្ពុជា"

*ថ្ងៃទី២៩កក្កដា-រដ្ឋាភិបាល ន.ស៊ីហនុ

*ខែសីហា- សាឡូត ស នឹងយូន សឿន ទៅចូលទីបញ្ជាការរណសិរ្សរំដោះជាតិខាងកើតខេត្តកំពុងចាម ដើម្បីធ្វើសង្គ្រាមវាយឆ្មក់

*ថ្ងៃទី២៥សីហា-ប្ដើមកិច្ចចរចាបរាំង-ខ្មែរ

*ថ្ងៃទី២៩សីហា ដល់ ១៧តុលា-ផ្ទេរសមត្ថភាព តុលាការ, ប៉ូលិស, នឹងយោធា

*ថ្ងៃទី៧វិច្ឆិកា- ផ្ទេរសមត្ថភាពចុងក្រោយខាងកិច្ចការការពារជាតិ

*ថ្ងៃទី៩វិច្ឆិការ១៩៥៣- សម្តេច នរោត្តម សីហនុ ប្រកាស"ឯករាជ្យជាតិកម្ពុជា" ជាថ្ងៃដែលប្រជាជាតិប្រារព្ធរហូតដល់សព្វថ្ងៃនេះ៕



## ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ
**អត្ថន័យពាក្យថា ឯករាជ្យ**

**បុណ្យឯករាជ្យ** ជាបុណ្យជាតិ ដែលកម្ពុជាបានធ្វើរៀងរាល់ឆ្នាំ **នៅថ្ងៃ៩វិច្ឆិកា។** បារាំងបានធ្វើអាណានិគមនិយមលើប្រទេសកម្ពុជា ពីឆ្នាំ១៨៦៣ដល់ឆ្នាំ១៩៥៣ អស់៩០ឆ្នាំ បានទទួលឯករាជ្យនៅថ្ងៃ៩វិច្ឆិកា១៩៥៣។ ទោះបីខ្មែរនៅក្រោមអាណានិគមបារាំង មិនអាចចាត់ចែងវាសនាខ្លួនបាន ប៉ុន្តែបានទទួលផលប្រយោជន៍មួយដ៏សំខាន់ គឺទប់ចលនាថៃនិងវៀតណាម ដែលតែងតែចូលមកឈ្លានពានប្រទេសកម្ពុជា ដោយរំលោភយកទឹកដីខ្មែរជានិច្ច។ ពាក្យថា **ឯករាជ្យ** គឺភាពនៃរដ្ឋឬប្រទេស ដែលមានសិទ្ធិនិងសេរីភាពពេញបរិបូណ៌ ក្នុងការគ្រប់គ្រងខ្លួនឯង ពុំចំណុះប្រទេសដទៃ។ ប្រទេសទាំងឡាយក្នុងលោកចង់មានអំណាចចាត់ចែងវាសនាខ្លួនតាមបំណងរបស់ខ្លួន។

ពេលនេះ រំលឹកឯករាជ្យពីបារាំង ប៉ុន្តែសព្វថ្ងៃនេះ គេនៅតែមានសេចក្តីសង្ស័យថា កម្ពុជានៅក្រោមការត្រួតត្រារបស់វៀតណាមដោយអាថ៌កំបាំង ព្រោះចាប់ពីការប្រកាសដកទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ គេជឿថា វៀតណាមបានបង្កប់ខ្លួននូវអ្នកជំនាញការគ្រប់ផ្នែក គ្រប់ក្រសួង ជួយគណបក្សប្រជាជនកម្ពុជា ដែលជាកូនចៅរបស់ខ្លួនប្រឆាំងនឹងចលនាតស៊ូខ្មែរ ពេលដែលខ្មែររួបរួមគ្នា។ តាំងពីឆ្នាំ១៩៧៩ រហូតឆ្នាំ២០១៦នេះ មាន៣៨ឆ្នាំ អ្នកជំនាញការវៀតណាម និង ចារកិច្ចវៀតណាម ចេះអក្សរនិងភាសាខ្មែរច្បាស់លាស់ ហើយបើកូនវៀតណាមកើតនៅឆ្នាំ១៩៧៩ កូននោះមានអាយុ៣៨ឆ្នាំហើយ ចេះអក្សរនិងភាសាខ្មែរច្បាស់លាស់។ ក្រសួងអន្តោប្រវេសន៍ពុំបានអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់នូវអន្តោប្រវេសន៍វៀតណាមដែលចូលមកកម្ពុជាពីឆ្នាំ១៩៧៩។ ដូច្នេះ កម្ពុជាមិនទាន់ឯករាជ្យទេ នៅក្រោមអំណាចវៀតណាមដោយកំបាំងមុខ។

ប្រទេសដែលមិនឯករាជ្យ គឺប្រទេសដែលមានគេត្រួតត្រា ដូចសព្វថ្ងៃ គេសង្ស័យថា វៀតណាមនៅតែមានអំណាចលើបក្សប្រជាជនកម្ពុជាធ្វើឲ្យខ្មែរបាក់បែកសាមគ្គីគ្នាពុំមានឯកភាពជាតិ ដោយបំណងមិនល្អរបស់បរទេស។គណបក្សប្រជាជនគប្បីរកមធ្យោបាយដកខ្លួនចេញពីឥទ្ធិពលរបស់វៀតណាម ហើយខ្មែរនិងខ្មែរគប្បីនិយាយគ្នាដោះស្រាយបញ្ហាជាតិខ្លួនដោយសន្តិវិធីឈរលើមូលដ្ឋានប្រយោជន៍ជាតិ។ ការបាក់បែកគ្នាគ្មានចំណេញអ្វីសោះដល់ជាតិ មានតែធ្វើឲ្យជាតិដល់នូវសេចក្តីវិនាសអន្តរាយ៕

វត្តខ្មែរកាណាដា,ថ្ងៃ១០វិច្ឆិកា២០១៦;www.hoksavann.org;savannhok@yahoo.com

Continued from page 04

# WIN, LOSE OR SINK, RACERS...

looking the river and the races.

About 2 million people are expected to attend this year's festival, according to City Hall spokesman Mean Chanyada-a stark contrast to the turnout of the 2014 festivities, when the city said less than 100,000 attended in the first two days.

Arriving from Takeo province with four friends to take part in her first Water Festival, 16-year-old Nak Net said she had long awaited the day she could take part in the tradition.

"I wanted to come here a few times already, but I couldn't find any-one to go with," she said. "I heard people who had been before saying that they were very happy here, so I wanted to feel like them."

While Net had not actually watched any boat races on Sunday, just being amid the buzz of the action was worth the trip, she said.

"I can hear them cheering and it makes me so happy."

RELATED COVERAGE

Thousands Watch as Annual Boat Racing Kicks Off in Kandal



TAKHMAO CITY, Kandal province - Tens of thousands of eager spectators lined the riverbanks of the TonleBassac here over the weekend for the first boat races of the year, a precursor to the Water Festival and a return to normalcy after the races were canceled last year.

October 17, 2016

**Races Raise Excitement for Return of Water Festival**


# ជ្រើសរើសបុគ្គលិក

**កាសែតខ្មែរផុសស.រ.អាត្រូវការជ្រើសរើសបុគ្គលិកផ្នែក លក់ពាណិជ្ជកម្ម ចំនួន២នាក់**

បេក្ខជនត្រូវមានលក្ខណៈដូចខាងក្រោម :

-រៀននៅមហាវិទ្យាល័យយ៉ាងហោចឆ្នាំទី៣
-មានជំនាញខាងផ្នែក Business ឬ Marketing
-ត្រូវចេះប្រាស្រ័យជាមួយភ្ញៀវពាណិជ្ជកម្មតាមប្រព័ន្ធទូរស័ព្ទ និងជួបផ្ទាល់
-( ត្រូវចេះ Typing), សរសេរ E-mail ប្រើ Internet និង Facebook (បើចេះWebsite កាន់តែល្អ )
-ត្រូវចេះធ្វើការជាមួយសហការីនៅក្នុង Office
-ត្រូវចេះនិយាយ សរសេរភាសាខ្មែរ និងអង់គ្លេស
-ត្រូវការមួយអាទិត្យ១៥ម៉ោង
-ត្រូវមាន License បើកបរ និងរថយន្ត
- Pay មួយម៉ោង $9.30 បូកនឹងរង្វាន់

**សូមទាក់ទងមក សូជាតិ ចាន់ info@khmerpost.us**

# រកអ្នកធ្វើការ

ខ្មែរផុសស.រ.អា រកបុគ្គលិកចេះនិយាយនឹងសរសេរភាសាខ្មែរច្បាស់លាស់ យល់ភាសាអង់គ្លេស សម្រាប់ការងារជាអ្នកសរសេរព័ត៌មាន។

សូមទូរស័ព្ទមកសូបិន **978-656 8141**



**KhmerPost USA, LLC**
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
ការីនិពន្ធ Staff Writers:
អ្នកនិពន្ធកិត្តិយស **Contributing Writers:**
Kayla Chan, Richard Howe Jr, Photographer/Videographer: Ra Yin
ច្នៃសោភ័ណភាពកាសែត **Design Artist**
Heng Chhunleng
ជំនួយការរដ្ឋបាល Office Coordnator
Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA





**CONWAY**
**INSURANCE AGENCY**

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។

**យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :**

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខឹខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
**សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង**



# ៣ ជំហ៊ានកម្ចាត់មុន លើផ្ទៃមុខអ្នកគ្មានសល់ ត្រឹមរយៈពេល ១យប់

អារម្មណ៏ស្រស់ស្រាយក្រោយភ្ញាក់ពីគេង នាពេលព្រឹកព្រលឹម បន្ទាប់ពីបានសម្រាកយ៉ាងស្កប់ស្កល់ ធ្វើឱ្យអ្នកមានអារម្មណ៏សប្បាយរីករាយសសម្រាប់ថ្ងៃថ្មីរបស់អ្នក។ ប៉ុន្តែប្រសិនបើអ្នកឈរសម្លឹងមើលក្នុងកញ្ចក់ឃើញផ្ទៃមុខរបស់អ្នកពោរពេញទៅដោយមុនក្រហមក្តៅ និងប៉ោងឡើងពេលនោះអារម្មណ៏កំពុងតែល្អនឹងត្រូវបំផ្លាញអស់។

តើអ្នកអាចអត់ទ្រាំនឹងវាបណ្តោយវាឱ្យសះស្បើយទៅវិញដោយឯកឯង ឬរិះរកវិធីណាមួយកម្ចាត់វា?

អនុវត្តតាម៣ជំហ៊ានខាងក្រោមមុនពេលចូលគេង និងលាងសម្អាតផ្ទៃមុខនឹងទឹកត្រជាក់នៅពេលព្រឹកៈ

**ជំហ៊ានទី ១** កម្ចាត់បញ្ហារលាកស្បែក

ប្រើដុំទឹកកកម៉ាស្សាថ្នមៗត្រង់កន្លែងកើតមុនរយៈពេល ៥នាទី បន្ទាប់មកជូតសម្អាតផ្ទៃមុខអ្នកនឹងកន្សែងស្អាត។

**ជំហ៊ានទី ២** បញ្ឈប់ការឆ្លងមេរោគ

នេះជាជំហ៊ានសំខាន់បំផុត ដើម្បីកម្ចាត់មេរោគ និងបាក់តេរី។ គ្រាន់តែលាយទឹកក្រូចឆ្មាស្រស់ជាមួយនឹងទឹកឃ្មុំសុទ្ធក្នុងបរិមាណស្មើគ្នារួចលាបលើមុនរបស់អ្នក។ រង់ចាំរយៈពេល២០នាទី បន្ទាប់មកប្រើសំឡីជូតសម្អាតវាចេញ។

**ជំហ៊ានទី ៣** កម្ចាត់ស្លាមមុន

ដូចដែលអ្នកធ្លាប់បានដឹងហើយថា នៅពេលមុនជាសះស្បើយ វាតែងតែបន្សល់ទុកនូវស្លាកស្នាម និងស្នាមអុចខ្មៅ។ នេះដោយសារតែមុនបានបំផ្លាញស្បែក និងសារធាតុចិញ្ចឹមនៅជុំវិញវា។ ដើម្បីបំបាត់ស្លាកស្នាមនេះបានអ្នកគ្រាន់តែយកស្លឹកជីអង្កាម ២-៣ សន្លឹកមក-បុកឱ្យម៉ត់។ រួចបន្ថែមសាច់ប្រទាលកន្ទុយក្រពើ ១ស្លាបព្រាបាយចូល និងលាបវាលើមុនរបស់អ្នក ហើយរក្សាវាទុករយៈពេលពេញមួយយប់៕

# ដាំរុក្ខជាតិទាំងនេះ អ្នកនឹងលង់លក់ ក្នុងដំណេកបានយ៉ាងស្រួល












អ្នកប្រហែលជាគិតថា បញ្ហាដំណេក គឺជារឿងតូចតាច ហើយតែងតែមើលរំលង រហូតពេលខ្លះ អ្នកគ្រាន់តែញ៉ាំថ្នាំងងុយគេង ក៏គិតថាវាអាចដោះស្រាយបានហើយ។ ប៉ុន្តែអ្នកកំពុងតែគិតខុស ហើយធ្វើបាបខ្លួនឯងហើយ។ មជ្ឈមណ្ឌលគ្រប់គ្រង និងការពារជំងឺ (Center for Disease Control and Prevention) បានអះអាងថា មនុស្សជាច្រើន បានចំណាយលុយច្រើនសន្ធឹកសន្ធាប់ ដើម្បីដោះស្រាយបញ្ហាគេងមិនលក់។ បើអ្នកមិនចង់ប្រើថ្នាំពេទ្យ ការញ៉ាំចេកឬតែចេក ក៏អាចដោះស្រាយបានផងដែរ។ ក្រៅពីនេះ ដើមរុក្ខជាតិទាំងបួនខាងក្រោមនេះ ប្រហែលជាអាចជួយអ្នកបាន។រុក្ខជាតិទាំងបួននេះ អ្នកអាចដាំមួយណាក៏បាន ហើយបើបានពីរបី គឺរឹតតែល្អ ពីព្រោះ វាអាច :

- កាត់បន្ថយស្ត្រេស
- បង្កើនខ្យល់អាកាស បរិសុទ្ធ
- ធ្វើឱ្យអារម្មណ៏ស្រស់ស្រាយ
- ជួយឱ្យគេងលក់ស្រួល
- មានក្លិនល្អក្នុងផ្ទះ
- កាត់បន្ថយការឈឺក្បាល និងជំងឺគ្រុនក្តៅ។

រុក្ខជាតិទាំងនោះ គឺ :

១. ដើមពស់

២. ដើមផ្កាម្លិះ

៣.ប្រទាលកន្ទុយក្រពើ

៤. ដើមផ្កាឡាវែនដឺ។

# ត្រីចៀនបន្លែជូរអែម

ថ្ងៃនេះយើងខ្ញុំសូមបង្ហាញនូវវិធីធ្វើម្ហូបមួយមុខទៀតដល់ស្ត្រីមេផ្ទះគ្រប់រូប ដែលម្ហូបនេះមានឈ្មោះថា ត្រីចៀនបន្លែជូរអែម ។ នេះជាអហារមួយប្រភេទដែលមានរស់ជាតិជូរអែម ព្រោះការធ្វើម្ហូបនេះត្រូវផ្សំឡើងពីគ្រឿងផ្សំជាច្រើនរួមទាំងបន្លែផងដែរ ។



**គ្រឿងផ្សំ :**

- ចំនួនត្រីសមល្មមនឹងតម្រូវការរបស់អ្នក
- ទឹកត្រីមួយស្លាព្រា
- ម្ទេះប្លោកមួយផ្លែ
- ប៉េងប៉ោះទុំមួយផ្លែ
- ដំឡូងបារាំងមួយដុំ
- ការ៉ុតមួយផ្លែ
- ម្សៅអំពិលទុំមួយស្លាព្រា
- អំបិលមួយស្លាព្រាកាហ្វេ
- ស្ករសពីរស្លាព្រាកាហ្វេ
- ប៊ីចេងមួយស្លាព្រាកាហ្វេ
- ប្រេងឆាមួយស្លាព្រា

**វិធីធ្វើ:**

១. ធ្វើត្រី រួចលាងទឹកឱ្យស្អាត បន្ទាប់មកយកត្រីទៅចៀនឱ្យគ្រាមដួសដាក់ចានទុកមួយដាច់ដោយឡែក។ **២.** ម្ទេះប្លោកពុះជាពីរឆ្កៀលយកសរសៃ និងគ្រាប់លាងទឹកឱ្យស្អាត ដើម្បីកុំឱ្យហិរពេក បន្ទាប់មកធ្វើការជិតវាជាបញ្ឆិត។ ដំឡូងបារាំងកោសសំបកឱ្យស្អាតបន្ទាប់មកគាស់វាជាដុំៗតូច។ ការ៉ុតត្រូវជិតសំបក និងលាងទឹកឱ្យស្អាតចិតបញ្ឆិត។ ធ្វើការលាងប៉េងប៉ោះឱ្យស្អាតបន្ទាប់មកចិតវាជារាងបញ្ឆិត។ **៣.** លាយទឹកម្សៅជាមួយ និងអំបិល, ស្ករស, ប៊ីចេងកូរចូលគ្នាឱ្យសព្វទុកមួយឡែកសិន។ **៤.** ដាក់ខ្លាញ់ឱ្យក្តៅបន្ទាប់មកចាក់បន្លែចូលឆាត្រឡប់ឱ្យឆ្អិនបន្លែ បន្ទាប់មកចាក់ទឹកម្សៅចូលឆាមួយត្រលប់ដួសស្រោចពីលើត្រីដែលដួសដាក់ចានជាការស្រេច។


Red Rose
ភោជនីយដ្ឋាន កូលាបក្រហម
RESTAURANT
ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់
Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851
អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!
Mon-Sun
8am -8pm


បាយសាច់ជ្រូកពងទាចៀន


គុយទាវអូរឬស្សី


មីកន្ធាំង


បបរគ្រឿង

* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់
(978) 452-5400



MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
•សេចក្តីអន្តរាយដល់បុគ្គល
•ច្បាប់ធានារ៉ាប់រង
•សំណងបុគ្គល
•ការរំលោភបទព្រហ្មទណ្ឌ
•ពិការភាពដោយសន្តិសុខសង្គម
•គ្រោះថ្នាក់ចរាចរណ៍
•បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
•គ្រោះថ្នាក់នៅការដ្ឋាន
•ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
•បំណុលអចលទ្រព្យ
•បណ្តឹងវិវាទទូទៅ
•បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

# សិក្ខាសាលានៅវត្តពោធិវង្ស ក្រុងប៉ារីស ថ្ងៃសៅរ៍ ទី០៨ ខែតុលា ឆ្នាំ២០១៦




លោក **សាគូ សាម៉ុត** បង្ហាញផលអាក្រក់ពីការគ្រប់គ្រងដោយអាជ្ញាធរសព្វថ្ងៃ៖ការបោះបង្គោលព្រំដែនតាមព្រំដែនខ្មែរ-យួន,ការបំផ្លាញបឹងទន្លេសាប,ការបំផ្លាញព្រៃឡង់,កង្វះការងារក្នុងស្រុក។ យុវជនខ្មែរជាង១លាននាក់ចាកចេញពីប្រទេសទៅធ្វើការនៅបរទេស អ្នកទាំងអស់នេះជាពលករដ៏សំខាន់សំរាប់សេដ្ឋកិច្ច តែផ្ទុយទៅវិញនៅក្នុងស្រុកគ្មានការងារធ្វើគ្រប់គ្រាន់ទេ គឺជាបញ្ហាសង្គម




បឹងទន្លេសាបផ្ទៃ៣០០០គម²នៅរដូវប្រាំង ជាបឹងដ៏ធំ ជាមណ្ឌលជីវបរិដ្ឋាន៖ មច្ឆាជាតិ២រយប្រភេទ-សត្វស្លាប២រយប្រភេទ-ទិន្នផលនេសាទត្រី១០តោន/គម² (មកដល់ទសវត្ស៧០)





**បឹងទន្លេសាប**បាននិងកំពុងបំផ្លិចបំផ្លាញដោយសារមនុស្ស។យួននៅកម្ពុជាជាង១លាននាក់ភាគច្រើនមកតាំងទីរស់នៅលើបឹងកំពុងបំផ្លិចបំផ្លាញបរិដ្ឋានបឹង




ផែនទីឥណ្ឌូចិនបង្ហាញពីព្រែកស្បូវស្រុកកោះធំ-ភូមិថ្មពាដុំស្រុកបូរីជលសារ កំពុងមានបញ្ហាដោយសារយួនធ្វើប៉ុស្តិនិងបង្ខិតព្រំដែន




ព្រៃឡង់(ព្រៃយើង)មានផ្ទៃ៥២៥០គម²ជាព្រៃធំបំផុតនៅអាស៊ីអាគ្នេយ៍ដីគោក មានព្រៃឈើដ៏ប្រណីតនិងជាជំរកសត្វព្រៃ។ **ពួយ** ជនជាតិភាគតិចរាប់សែននាក់រស់ដោយសារអនុផលព្រៃឈើនេះ។





**ព្រៃឡង់**បានកាប់យកឈើបំផ្លិចបំផ្លាញ។មកដល់ឆ្នាំ២០១១ការបំផ្លាញព្រៃឈើធ្វើលើដីសម្បទានមានជាង២លានហិកតាដែលឈ្មួញទទួលអាជ្ញាប័ណ្ណពីរដ្ឋ។



លោក **ចាយ សិរីវុឌ្ឍន៍** បង្ហាញផែនទីកម្ពុជាតម្កល់ទុកនៅអសបដែលលោកទទួលបានពីបណ្ណាល័យ អ.ស.ប នៅឆ្នាំ១៩៨៥។ នេះជាផែនទីមួយប្រភេទដែលសម្តេច ន.សីហនុ បានតម្កល់ទុកនៅអ.ស.បនៅខែមីនា១៩៦៤ លោកក៏បានបង្ហាញពីអធិបតេយ្យភាពកម្ពុជាលើខ្លង់រាបបាតសមុទ្រខ្មែរ ជាពិសេសលើកោះខ្មែរទាំង៦៤ ឋិតនៅក្នុងឈូងសមុទ្រថៃទៀតផង។




ផែនទីតម្កល់ទុកនៅ អ.ស.ប ខ្នាត១លើ១លាន មានបោះត្រា MAP COLLECTION UNITED NATIONS LIBRARY



ORDONNONS:

FAIT EN NOTRE PALAIS ROYAL A PHNOM PENH, LE 30 DECEMBRE 1957.

ក្រឹត្យព្រះបាទ នរោត្តម សុរាម្រិតថ្ងៃទី៣០ខែធ្នូ១៩៥៧ ស្តីពីខ្លង់រាបបាតសមុទ្រខ្មែរ



លោក **ហេង គីម** និយាយពីបញ្ហាយួននៅស្រុកខ្មែរ ដោយរំលឹកពីសិក្ខាសាលាឆ្នាំ២០១៥ដែលលោកបានធ្លើរចមកហើយ“**ភ័យសម័យថ្មី(ស្របច្បាប់)**” ការប្រើប្រជាធិបតេយ្យបោះឆ្នោត➤យួនមានចំនួនច្រើនឡើងៗកាន់កាតខ្មែរនឹងបោះឆ្នោតឱ្យពួកយួន ឬបក្សបំរើយួន➤ពួកយួនឈ្នះឆ្នោតកាន់អំណាចស្របច្បាប់➤យើងត្រូវខាឃាំងល្បិចបោកនេះ។



ភិក្ខុ **ឃិន ភេន** មានសង្ឃដីកាជួយរកដំណោះស្រាយ៖ ស្នើជនរួមជាតិធ្វើលិខិតថ្វាយព្រះមហាក្សត្រ, ជូនទៅតំណាងរាស្ត្រ,ជូនទៅប្រទេសហត្ថលេខីកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ ពីគ្រោះថ្នាក់ទាំងនេះ។



ភិក្ខុ **ពេជ្រ សាម៉ុន** ចៅអធិការវត្តពោធិវង្ស បានជួយខ្នះខ្នែងថតចម្លងអត្ថបទសិក្ខាសាលាចែកជូនអស់លោកដែលបានអញ្ជើញមកចូលរួមក្នុងសិក្ខាសាលានេះ។ មានឯកសារជាប់នៅដៃអ្នកចូលរួមអាចតាមដានអត្ថាធិប្បាយរបស់វាគ្មិន។



ភិក្ខុ **សេង សុវណ្ណារា** អតីតចៅអធិការវត្តសាមគ្គីក្រុងភ្នំពេញមានសង្ឃដីកាថាបញ្ហាយួននៅស្រុកខ្មែរជាបញ្ហាចំបង“អាត្មាបានទៅភូមិថ្មពជុំ យួនវាកាន់កាប់ទៅហើយ” ខ្មែរចេញចូលមិនបានទេ។



លោកស្រី **ឌុក សេដ្ឋា** ស្នើឱ្យតាមដានការបោះបង្គោលព្រំដែនឱ្យជាប់ជានិច្ចនិងគិតគូរបញ្ហាសិទ្ធិមនុស្ស ត្រូវហ៊ានរៀបចំសំណុំរឿងផ្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ។ តំណាងរាស្ត្រខ្មែរ រដ្ឋាភិបាលសព្វថ្ងៃមិនបានធ្វើការងារបំរើរាស្ត្រឡើយ។



លោក **ស៊ាន ម៉ាសារ៉ាង** បានរំលឹកពីស្នាដៃលោកស៊ានប៉េងសែ ជាស្នាដៃបច្ចេកទេសរបស់“គណៈកម្មធិការព្រំដែនកម្ពុជា”ដែលអនុញ្ញាតឱ្យយើងទាំងអស់គ្នាយល់ដឹងពីបញ្ហាព្រំដែនរបស់ប្រទេសកម្ពុជាសព្វថ្ងៃនេះ។



លោក **ហម ប៊ុនឆាយ** បានរៀបរាប់ពីបារាំងបានភ្ជាប់កូសាំងស៊ីនទៅអណ្ណាមដោយមានការតវ៉ាពីប្រតិភូខ្មែរនិងពីលោកGaston Deferre។ លោកបាននិយាយផែនទីIGN តែការបោះបង្គោលព្រំដែនធ្វើតាមសន្ធិសញ្ញាឆ្នាំ១៩៨៥។



លោក **សុខ សុផាត** បានចែកមុខងារពាផ្នែក៖ក្រុមបច្ចេកទេស,អ្នកនយោបាយ,ប្រជារាស្ត្រ។ប្រជារាស្ត្រ អ្នករស់ទីកន្លែងជាអ្នកតស៊ូជួរមុខគួរគប្បីទទួលការគាំទ្រផ្តល់មធ្យោបាយឱ្យបានច្រើន ត្រូវធ្វើយ៉ាងណាឱ្យរាស្ត្រនៅខាងយើង



លោក **ឆាយ ឌៀរី** និយាយពីកោះខ្មែរនៅមុខកែប៖ កោះទន្សាយ,កោះស្វាយ,កោះត្បាល់..និងមានពួកយួនប្តូរឈ្មោះជាខ្មែរកាន់ការសំខាន់ៗណាស់នៅស្រុកខ្មែរ អ្នកទាំងនេះបង្កគ្រោះថ្នាក់ដល់ជីវិតស្រុកខ្មែរ។



អ្នកចូលរួមជិត១រយនាក់ ដែលមួយចំនួនមានសមាគមរៀងៗខ្លួន បានខំតាមដានយ៉ាងយកចិត្តទុកដាក់ពីការអធិប្បាយស្តីពីបច្ចុប្បន្នភាពកម្ពុជារបស់វាគ្មិនទាំងពីរ។



ឯកសារជាប់នៅដៃ អ្នកចូលរួមកំពុងផ្ទៀង ឈ្មោះកោះខ្មែរទាំង៦៤ឋិតនៅឈូងសមុទ្រថៃ ដែលអានដោយលោក សាគូ សាម៉ុត។



លោក សាគូ សាម៉ុត និយាយពីភូមិសាស្ត្រប្រទេសកម្ពុជា និង

➤ ខ្នាតផែនទី៖ ១លើ១០០ពាន់, ១លើ៥០ពាន់, ១លើ១លាន

➤ ប្រភេទផែនទី៖ BONNE, U.T.M, GPS (GLOBAL POSITIONNING SYSTEM)

# ដឹងអត់ថាហេតុអ្វីបានជាគេមិនឱ្យលេបថ្នាំជាមួយគ្រឿងស្រវឹង?

បើសិនជាអ្នកជាមនុស្សម្នាក់ដែលមិនបានយកចិត្តទុកដាក់ទៅលើការចៀសវាងការប្រើគ្រឿងស្រវឹងនៅពេលប្រើថ្នាំសង្កូវទេ អ្នកត្រូវតែយល់ដឹងផងថា វាអាចនឹងប៉ះពាល់ដល់ក្រពះបាន។ មិនត្រឹមតែប៉ុណ្ណោះ ការញ៉ាំគ្រឿងស្រវឹងជាមួយថ្នាំអាចបន្ថយប្រសិទ្ធភាពរបស់ថ្នាំដែលជាហេតុនាំឱ្យថ្នាំនោះប្រើទៅគ្មានប្រសិទ្ធភាព។ ការញ៉ាំគ្រឿងស្រវឹងជាមួយថ្នាំមានឥទ្ធិពលមិនល្អខុសៗគ្នាជាច្រើនអាស្រ័យទៅតាមប្រភេទរបស់ថ្នាំ របៀបដែលវាធ្វើការ និងកម្រិតនៃការប្រើប្រាស់។ ដូច្នេះបើសិនជាថ្នាំ និងគ្រឿងស្រវឹងធ្វើការក្នុងរាងកាយក្នុងរបៀបស្រដៀងគ្នា វាអាចបង្កើនឥទ្ធិពលរបស់ថ្នាំនោះបាន តែបើសិនជាធ្វើការផ្ទុយគ្នាវិញ វាអាចកាត់បន្ថយប្រសិទ្ធភាពថ្នាំនោះបាន។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗរបស់អ្នកដែលអ្នកមិនគួរណាប្រើជាមួយគ្រឿងស្រវឹងឡើយ។ ថ្នាំប្រភេទទឹកសេរ៉ូក្អក និងថ្នាំបន្ទន់លាមកមានជាតិអាល់កុល១០ភាគរយហើយ។ ដូច្នេះបើសិនជាអ្នកប្រើថ្នាំទាំងនេះជាមួយគ្រឿងស្រវឹងទៀត វានឹងបង្កើនចំនួនជាតិអាលកុលក្នុងរាងកាយនឹងបន្ថយឥទ្ធិពលថ្នាំបាន។ គ្រឿងស្រវឹងពេលប្រើជាមួយថ្នាំបំបាត់ការឈឺចាប់ប្រហែលជាធ្វើឱ្យប្រឈមកាន់តែខ្លាំងនឹងការខូចផ្លូវក្រពះពោះវៀនបាន។ រោគសញ្ញារបស់វាមានដូចជា ឈឺក្នុងក្រពះ ក្អួត ចង្អោជាដើម។បើសិនជាអ្នកប្រើថ្នាំផ្សះ ឬថ្នាំព្យាបាលជំងឺទឹកនោមផ្អែម និងជំងឺអេដស៏ជាមួយគ្រឿងស្រវឹងវាប្រហែលជាអាចកាត់បន្ថយឥទ្ធិពលរបស់ថ្នាំបាន។ ជាមួយគ្នានេះដែរ វាអាចនាំឱ្យមានផលវិបាកដល់សុខភាពនានាច្រើនទៀតដូចជា សន្លឹម វិលមុខ ចលនាដៃជើតខូចខាតមានបញ្ហាដល់ការចងចាំ ចង្អោ ឈឺក្រពះ ឬក្អួត។ សញ្ញាទាំងអស់នេះអាចកើតឡើងក្រោយពីញ៉ាំគ្រឿងស្រវឹងតែបន្តិចប៉ុណ្ណោះ៕





fallonhealth

**រកអ្នកធ្វើការ ចេះភាសាខ្មែរ តំណាងសហគមន៍ខផែទំសុខភាព តំបន់ឡូវែល**

Sr. Care (SCO) Community Representative Lowell Area – Khmer Language a must

**ណេវីឃែរ** (Navicare)**ជាអ្វី:**

ហ្វាលលនហែល (Fallon Health) គឺជាអ្នកផ្តល់ដំណោះស្រាយដឹកមុខគេ ខាងផ្នែករក្សាសុខភាពមនុស្សចាស់, ដូចជា ណេវីឃែរ ដែរ ដែលផ្តល់ផលចំណេញ មែឌីឃែរល្អ (Medicare Advantage), ផែនការតម្រូវការពិសេស (Special Needs Plan) នឹងជម្រើសកម្មវិធីថែទាំមនុស្សចាស់ (Senior Care Option)។ ណេវីឃែ មានបញ្ចូលការថែទាំមនុស្សពេញវ័យ ចាប់ពីអាយុ៦៥ឆ្នាំ នឹងច្រើនជាងដែលមានសិទ្ធិ២យ៉ាង ទទួលមេឌីឃែ (Medicare) ផង នឹងប័ណ្ណធានាសុខភាព ម៉ាសាឈូសិតស្តង់ដា (Mass Health) ផង។ ក្រុមអ្នកថែទាំមឋមផ្ទាល់ខ្លួន គ្រប់គ្រងនឹងទាក់ទង សមាជិកថែរសុខភាព ណេវីឃែ ដោយធ្វើការជាមួយសមាជិកម្នាក់ៗ, សមាជិកនៃគ្រួសារ, នឹងអ្នកផ្តល់សេវាសុខភាព ដើម្បីធានាបាននូវលទ្ធផលល្អប្រសើរបំផុត។

តំណែងនេះត្រូវឱ្យ ទាក់ទងទៅខាងក្រៅ សម្រេចបំណងទទួលបាននូវភ្ញៀវផ្ទាល់ខ្លួន -លក់ផលិតផល -ទៅដល់គោលដៅដែលចេញទៅទាក់ទងគេសម្រាប់កម្មវិធីណេវីឃែ។ គ្រប់គ្រងដែនតំបន់នឹងបញ្ជីគណនីដើមនៃក្រុមភ្ញៀវ, ផ្តល់នូវការតាមដានយ៉ាងទៀងទាត់ នឹងយកឈ្នះនូវរនាំងជាមួយករណីនិមួយៗ ដើម្បីឱ្យបានជាភ្ញៀវ។ យើងរង់ចាំអ្នកនៅតំបន់ឡូវែលនឹងចេះភាសាខ្មែរ។

**បទពិសោធន៍ :**

-មានបទពិសោធន៏ចាប់ពីពឆ្នាំ នៅក្នុងមណ្ឌលសុខភាព ឬនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងដែលរឹងមាំណាមួយ
-មានបទពិសោធន៏ច្បាស់លាស់ក្នុងកិច្ចការអតិថិជន ប្រឈមមុខតួនាទីផ្នែកលក់ ជំនាន់អ្នកដឹកនាំជាន់ខ្ពស់ខាងសេវាអតិថិជន នឹងបរិដ្ឋាននៃការលក់
-មានចំណេះដឹងខាងសេវាមេឌីឃែ (Medicare) ខាងមេដឌីខេដ (Medicaid) នឹងផលិតផលធានារ៉ាប់រង កាន់តែប្រសើរ
-មានប័ណ្ណបើកបរនៅរដ្ឋម៉ាសាឈូសិត អាខប្រើបាន នឹងមានរថយន្តសម្រាប់ការងារទីផ្សារ ការងារទៅជួបភ្ញៀវដល់ផ្ទះ

សូមទាក់ទងមក:
Lisa RosenKrantz
Sr. Recruiter Talent Acquisition Fallon Health
Lisa.rosenkrantz@fallonhealth.org
**508-368-9663**

# Read us online at www.khmerpost.us

KhmerPost USA is the only Cambodian newspaper that has the highest circulation and is most read in the Cambodian communities in the Greater Merrimack Valley, Boston and beyond. It provides important news and information to a market that is often isolated from the larger community due to a language barrier. This includes the national and international news, and the practical local information concerning health, education, politics, businesses and community involvement.

**Publication Frequency**
24 times a year. Prints on every other Friday

**General Information**
Circulations: 10,000 free copies per month
Distributions:

- 60 locations in Lowell, MA (3,000 copies per issue)
- 25 Locations in Lynn and Revere, MA (500 copies per issue)
- 25 Locations in Cranston & Providence, RI (1,000 copies per Issue)

## 2016 & 2017 Publication Dates

- December 2nd & 16th, 2016 — January 6th & 20th, 2017
- February 3rd & 17th, 2017 — March 10th & 24th, 2017
- April 7th & 21st , 2017 — May 5th & 19th, 2017
- June 9th, & 23rd, 2017 — July 7th & 21st, 2017
- August 4th & 9th, 2017 — September 8th & 22nd, 2017
- October 6th & 20th, 2017 — November 3rd & 17th, 2017
- December 8th & 22nd , 2017

* all ad materials are due one due one week prior to the publishing date.

## Advertising Rates

| Ad Size | 1 issue | 3 month 5% off | 6 month 7.5% off | 12 month 10% off |
|---|---|---|---|---|
| full | 460.00 | 2,622.00 | 5,106.00 | 9,936.00 |
| 1/2 | 310.00 | 1,674.00 | 3,441.00 | 6,696.00 |
| 1/4 | 165.00 | 940.50 | 1,831.50 | 3,564.00 |
| 1/8 | 90.00 | 513.00 | 999.00 | 1,944.00 |







## Ads Sizes & Dimensions

| | |
|---|---|
| 1 Full page inside | (13"x10") |
| 1/2 page color | (6.5"x10") |
| 1/4 page color | (6.5"x5") |
| 1/8 page color | (3.25"x5") |

**Office:** 45 Merrimack Street. Suite 218A. Lowell, MA 01852
**Tel:** 978.677.7163. **Cell:** 978. 656.8141. Fax: 978.677.7092
Email: sobenpin@khmerpost.us | www.khmerpost.us

**New ! We accept credit Cards :** VISA MasterCard AMERICAN EXPRESS

Schedules and Rate revision and effective September 1st, 2015

# ឧទ្យានជាតិបុទុមសាគរ



ឧទ្យានជាតិបុទុមសាគរមានទីតាំងស្ថិតនៅទឹកដីខេត្តកោះកុងមានព្រំប្រទល់ផ្លូវជាតិលេខ ៤៨ ពីចំណុចឃុំអណ្តូងទឹក រហូតទៅដល់ឃុំត្រពាំងរូង ក្រៅពីនោះគឺមានព្រំប្រទល់ជាប់មាត់សមុទ្រទាំងអស់ ។

ឧទ្យាននេះមានផ្ទៃដី១៨៣.៤០៨ ហិកតា ខាងជើងជាប់នឹងព្រែកត្រពាំងរូង ក្នុងឃុំត្រពាំងរូង ខាងកើតជាប់ផ្លូវជាតិលេខ៤៨ ខាងត្បូង និងខាងលិចជាប់ព្រំប្រទល់ទឹកសមុទ្រ ។ ឧទ្យានជាតិនេះជាតំបន់ធម្មជាតិ និងជាដែនជម្រកសត្វព្រៃ និងមច្ឆជាតិគ្រប់ប្រភេទ ។ ក្រៅពីជាកន្លែងសម្បូរដំណាំហូបផ្លែច្រើនមុខឧទ្យានជាតិជាប់សមុទ្រមាន ឆ្នេរខ្សាច់ម៉ដ្ឋលាតសន្ធឹងធំល្វឹងល្វើយសម្បូរទៅដោយព្រៃកោងកាងយ៉ាងក្រាស់ក្រែល ។ នៅក្នុងតំបន់នោះក៏មានប្រជាជនរហូតដល់ទៅ២៤ភូមិសុទ្ធសឹងតែប្រជានេសាទសមុទ្រទាំងអស់ ។

កត្តាទាំងអស់ខាងលើនេះ វាក៏ជាកន្លែងអំណោយផលយ៉ាងគាប់ប្រសើរក្នុងការទាក់ទាញភ្ញៀវទេសចរទាំងឡាយចង់ទៅទស្សនាកម្សាន្តជាពិសេសនោះដោយតំបន់នោះ ជាតំបន់សមុទ្រ គេអាចជិះទូកអូប័រទៅលេងកម្សាន្តនៅកោះស្តេច ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីឧទ្យានជាតិនេះ ។ ប៉ុន្តែគួរឱ្យសោកស្តាយដោយក្នុងតំបន់មិនទាន់មានហេដ្ឋារចនាសម្ព័ន្ធរៀចបំបានស្រួលនៅឡើយ វាក៏មិនទាន់អាចទទួលភ្ញៀវទេសចរទៅកម្សាន្តបាននោះដែរ ។ បុទុមសាគរត្រូវបានកំណត់ជាឧទ្យានជាតិបុទុមសាគរដោយព្រះករុណាព្រះបាទនរោត្តម សីហនុ នៅថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ៕







